# ការបម្រើព្រះជាម្ចាស់ និងមនុស្សជាតិ

## កេរដំណែល Shaykh Muhammad al-Ghazali




IIIT Books-In-Brief Series

# ការបម្រើព្រះជាម្ចាស់ និង មនុស្សជាតិ ៖ កេរដំណែល

Shaykh Muhammad al-Ghazali

Benaouda Bensaid

សង្ខេបដោយ Wanda Krause

@វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ ឆ្នាំ២០២៤

វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ(IIIT)
P.O. BOx 669
Herndon, VA 20172, USA
www.iiit.org

IIIT London Office
P.O. Box 126
Richmond, Surrey
TW9 2UD, UK
www.iiituk.com

សៀវភៅនេះស្ថិតក្នុងការរក្សាកម្មសិទ្ធិ។ កម្មវត្ថុនៃការលើកលែង និងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងជាសមូហភាពដែលពាក់ព័ន្ធមិនអាចផលិតឡើងវិញនូវផ្នែកណាមួយនៃសៀវភៅនេះ  អាចធ្វើទៅបាននោះឡើយ បើសិនជាមិនមានការសរសេរលាយលក្ខណ៍អក្សរនៃការអនុញ្ញាតពីអ្នកបោះពុម្ពផ្សាយ។

ទស្សនៈ និងគំនិតដែលបានបង្ហាញក្នុងសៀវភៅនេះគឺជាគំនិតរបស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈ របស់អ្នកបោះពុម្ពឡើយ។

979-8-89193-328-6

*កំណត់រចនាបថអក្សរដោយ Sideek Ali*
*រចនាក្របសៀវភៅដោយ  Shiraz Khan*

## ប្រភេទសៀវភៅសង្ខេបរបស់វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ(IIIT)

សៀវភៅ IIIT Books-In-Brief Series គឺជាការប្រមូលផ្តុំដ៏មានតម្លៃនៃសៀវភៅ ដែលបានបោះពុម្ពផ្សាយសំខាន់ៗ របស់វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តជាតិ(IIIT) ដែលបានសរសេរ រៀបចំឡើងជាទម្រង់សង្ខេបខ្លី ខ្លឹម ដើម្បីផ្តល់ឱ្យមិត្តអ្នកអាន នូវការយល់ដឹងអំពីស្នូលនៃខ្លឹមសារសំខាន់ៗ នៃស្នាដៃសៀវភៅច្បាប់ដើមតែម្តង។ រៀបចំឡើងក្នុងទម្រង់ខ្លី ងាយស្រួលអានសន្សំសំចៃពេលវេលា សេចក្តីសង្ខេប នៃបណ្តាសៀវភៅទាំងនេះបានផ្តល់នូវភាពខ្លឹមនៃការបង្រួមខ្លឹមសា ឲ្យកាន់តែខ្លី និងសរសេរដោយប្រុងប្រយ័ត្នបំផុតពីសៀវភៅដើមដែលមានពិពណ៌នាច្រើនជាងនេះ ដែលយើងខ្ញុំសង្ឃឹមថាមិត្តអ្នកអាននឹងស្វែងយល់បន្ថែមពីបណ្តាសៀវភៅដើមពេញទំព័រដែលមិនទាន់បានសង្ខេបជាបន្ត។

**នៅក្នុងការបម្រើព្រះជាម្ចាស់ និងមនុស្សជាតិ កេរដំណែលរបស់ Shaykh Muhammad al-Ghazali** វាគឺជាបទពិសោធន៍ទៅលើគំរូដាក់វ៉ះShaykh Muhammad al-Ghazali។ ស្នាដៃនេះបង្ហាញទិដ្ឋភាពពីជីវិតរបស់ Shaykh al-Ghazali អំពីការអប់រំ អាជីព បញ្ញាញាណ វិជ្ជាជីវៈ និងការរួមចំណែកលើការដាក់វ៉ះ និងសង្គម ក៏ដូចជាចរិតលក្ខណៈផ្ទាល់ខ្លួន។ វាក៏បង្ហាញពីរបៀបដែល Al-Ghazali ដែលជាសាសនវិទូដែលមានការយល់ដឹងយ៉ាងស៊ីជម្រៅអំពីទស្សនវិជ្ជា ថាមវន្ត និងឥទ្ធិពលនៃសាសនាអ៊ីស្លាម ក៏បានត្រូវបានប្រើប្រាស់ ឬមានឥទ្ធិពលដល់សម័យទំនើបផងដែរ។ វិធីសាស្រ្តនេះទាក់ទងនឹងការវិភាគ អំពីសាសនា សង្គម និងសម័យបច្ចុប្បន្ន។

Al-Ghazali បានចាត់ទុកការដាក់វ៉ះផ្សព្វផ្សាយ ជាបញ្ហាសំខាន់មួយ ដែលទាមទារនូវវិធីសាស្រ្តពហុមុខងារ និងពហុជំនាញ ជាចម្បង ដោយសារតែគាត់បានផ្សាភ្ជាប់វាទៅនឹងតម្រូវការរបស់មនុស្សជាតិសម្រាប់ជំនឿលើព្រះជាម្ចាស់ នៅជាចំណុចទីមួយ និងឧបករណ៍វាស់ស្ទង់នូវការធ្លាក់ចុះទូទៅនៃការគិតខាងវិញ្ញាណស្មារតីរបស់មូស្លីមនៅចំណុចទីពីរ។

ការសិក្សាដូច្នេះវាពិនិត្យមើលលើក្របខណ្ឌនៃគំនិតរបស់ Al-Ghazali លើការងារដាក់វ៉ះ រួមទាំងគោលគំនិត និងលក្ខណៈរបស់វា ព្រមទាំងការងារដាក់វ៉ះរបស់ព្យាការី ដូចដែលបានពិពណ៌នានៅក្នុងគម្ពីរអាល់គួរអាន ជា(fitrah) និងសម្រាប់ការងារដាក់វ៉ះជាសកល។ វាក៏បានពិនិត្យមើលលើឥទ្ធិពលនៃសង្គម និងវប្បធម៌ទៅលើការងារដាក់វ៉ះ ពីរបៀបដែល Al-Ghazali បានយល់ ពីវិធីសាស្រ្តដាក់វ៉ះផលប៉ះពាល់ និងឥទ្ធិពលនៃកត្តាសេដ្ឋកិច្ចសង្គម និងនយោបាយដែលទាក់ទងនឹងការអភិវឌ្ឍលើការងារដាក់វ៉ះផងដែរ។

ការរិះគន់យ៉ាងមុតស្រួចរបស់ Al-Ghazali លើទូអាត (អ្នកដែលដាក់វ៉ះផ្សព្វផ្សាយពីសាសនាអ៊ីស្លាម) និងការអនុវត្តការងារដាក់វ៉ះត្រូវបានលើកយកមកបង្ហាញ។ ក្នុងការបង្ហាញដូច្នេះ អ្នកនិពន្ធបានពិនិត្យមើលលើវិធីសាស្រ្តរបស់ Al-Ghazali និងដំណោះស្រាយនានាដែលមាន។ ការឆ្លើយតបទៅនឹងទស្សនៈរបស់គាត់ ទៅលើវិធីសាស្រ្តរបស់អ្នកទូអាត លើការងារដាក់វ៉ះ និងភាពសំខាន់បំផុតនៃគំនិតរបស់ Al-Ghazali អំពី ហ្វិក អាត់ដាក់វ៉ះ (វិធីសាស្រ្តច្បាប់ទាក់ទងនឹង ការងារដាក់វ៉ះ) ដែលវាជាប់ទាក់ទងនឹងអាទិភាពនៃ ការងារដាក់វ៉ះសហសម័យនៅក្នុងពន្លឺនៃការយល់ដឹងរបស់ Al-Ghazali អំពីផលប្រយោ ជន៍ដ៏ល្អបំផុតនៃការងារដាក់វ៉ះ (maṣlaḥah al-dawah) ។

គំនិតរបស់ Al-Ghazali បន្តទាក់ទាញអ្នកស្រាវជ្រាវជាច្រើននាពេលបច្ចុប្បន្ននេះ និងផ្តល់ជាគំនិតបន្តសម្រាប់អ្នកធ្វើការងារឈាក់វ៉ះនៃសម័យទំនើបនេះ។

---

**ការបោះពុម្ពស្នាដៃសៀវភៅសង្ខេបពីប្រភពដើមនៃស្នាដៃរបស់ Benaouda Bensaid**
*នៃសៀវភៅការបម្រើព្រះជាម្ចាស់ និងមនុស្សជាតិកេរដំណែល*
*Shaykh Muhammad al-Ghazali*
ISBN: 979-8-89193-328-6
2024

# ការណែនាំ

ប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ការរិះគន់របស់លោកខាងលិចអំពីទំនើបកម្មបានបំផុសគំនិតបញ្ញវន្ត មូស្លីម ដើម្បីបង្កើតគំនិតថ្មី រូបភាព លក្ខខណ្ឌថ្មី និងគោលគំនិតដែលបង្ហាញពីជំហររបស់ពួកគេឆ្ពោះទៅរកទំនោរនៃភាពទំនើបខាងលោកិយ ការផ្លាស់ប្តូរ និងផលវិបាករបស់វា។ ភាពទំនើបជាធម្មតាត្រូវបានសមមាត្រជាមួយនឹងឧត្តមគតិដ៏ខ្ពង់ខ្ពស់នៃការយល់ដឹងដ៏ឧត្តុងឧត្តម ជាពិសេសការសន្យាពីធម្មជាតិ ហេតុផល និងវឌ្ឍនភាពដើម្បីបង្កើតប្រព័ន្ធសមហេតុផល និងវឌ្ឍនភាពរបស់វា។

វិស័យនៃការសិក្សាអំពីការងារឌាក់វ៉ះនាសម័យទំនើប ជាញឹកញាប់បានគូសបញ្ជាក់ពីគំរូ ដែលមានស្រាប់របស់ការងារឌាក់វ៉ះ ដោយគំរូនីមួយៗឆ្លុះបញ្ចាំងពីប្រវត្តិសាស្រ្ត ទស្សនវិជ្ជា និងវិធីសាស្រ្តរៀងៗខ្លួន ដូចជាក្រុមស៊ូហ្វី តាប់លៀហ្គ ឬអាស់លី ហាទីស។ ទោះបីជាយ៉ាងណាក៏ដោយ ទោះបីជាមានមូលដ្ឋានគ្រឹះរួមគ្នា និងទោះបីជាមានការរួមចំណែកផ្សេងៗគ្នាក៏ដោយ គំរូលើការងារឌាក់វ៉ះទាំងនេះបានធ្វើឲ្យមានការជជែកដេញដោលជាបន្តលើគំរូមួយក្នុងចំណោមគំរូទាំងនេះ ដែលមានប្រសិទ្ធភាពបំផុតលើការជម្រុញឲ្យមានការយល់ដឹងពីសាសនាអ៊ីស្លាម និងថាតើពួកគេអាចបង្កើតការសំយោគរវាងបទដ្ឋានសាសនា និងបញ្ហាប្រឈមដ៏ស្មុគស្មាញនៃសម័យទំនើបយ៉ាងដូចម្តេច។ អាស្រ័យហេតុនេះ មិនត្រឹមតែត្រូវមានការយល់ដឹងឲ្យបានស៊ីជម្រៅអំពីទ្រឹស្តីអ៊ីស្លាមលើការងារឌាក់វ៉ះប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ត្រូវការផងដែរ លើការវិភាគដ៏សំខាន់ចំពោះការអនុវត្តការងារឌាក់វ៉ះ នៅក្នុងបរិបទសង្គមវប្បធម៌នៃប្រជាជនម៉ូស្លីម និងវិធីសម្រាប់ឌាក់វ៉ះ ដើម្បីឆ្លើយតបបានល្អបំផុតចំពោះបញ្ហាប្រឈមនៅក្នុងសម័យទំនើប ស្របពេលដែលយើងត្រូវប្រកាន់ឲ្យបានខ្ជាប់នូវគោលការណ៍គ្រឹះនៃសាសនាអ៊ីស្លាមផងដែរ។ នៅក្នុងការដោះស្រាយបញ្ហានេះ អ្នកប្រាជ្ញ និងជាអ្នកផ្សព្វផ្សាយឌាក់វ៉ះ លោក Muhammad al-Ghazali បានដឹកនាំ លើការអភិវឌ្ឍទស្សនៈថ្មីលើប្រធានបទការងារឌាក់វ៉ះ។ ក្នុងមួយជីវិតរបស់គាត់ គាត់បាននិពន្ធសៀវភៅជិត៦០ក្បាល ដែលភាគច្រើនទាក់ទិននឹងការឌាក់វ៉ះសម្រាប់សម័យទំនើប ដែលមានការលើកឡើងពីការរិះគន់ និងអំពីវិធីសាស្រ្តខុសពីធម្មតាពីមុន។

ការពិភាក្សា ការលើកឡើងយ៉ាងទូលំទូលាយរបស់ Al-Ghazali អំពីការឌាក់វ៉ះ បានឆ្លុះបញ្ចាំងពីការគិត និងបទពិសោធន៍របស់គាត់។ ទាំងនេះវាកើតចេញពីបទពិសោធន៍របស់គាត់នៅតំបន់ជនបទប្រទេសអេហ្ស៊ីប ការបណ្តុះបណ្តាលនៅក្នុងក្រុម Muslim Brotherhood (1937-1953) ការសិក្សារៀនសូត្ររបស់គាត់ និងតួនាទីមុខតំណែងនៅក្នុងរដ្ឋាភិបាលដែលគាត់បានធ្វើការ (1971-1981) ក៏ដូចជាសមាជិកភាពដ៏សកម្មរបស់គាត់នៅក្នុងសាសនា អង្គការអ៊ីស្លាម និងអង្គការសប្បុរសធម៌ជាច្រើន និងសូម្បីតែរឿងផ្ទាល់ខ្លួន និងការធ្វើដំណើរក៏ដោយក៏មានផងដែរ។ គាត់បានរស់នៅទាន់ និងបានឃើញលទ្ធផលនៃការរំលាយចក្រភពអូតូម៉ង់នៅក្នុងឆ្នាំ1922 និងបានឃើញពីការធ្លាក់ចុះ និងការដួលរលំនៃប្រទេសមូស្លីមផ្សេងៗ។ ដូច្នេះការគិតរបស់គាត់បានឆ្លុះបញ្ចាំងពីវិសាលភាពដ៏ធំទូលំទូលាយនៃបទពិសោធន៍សង្គម ប្រវត្តិសាស្រ្ត ដែលជាកម្មសិទ្ធិនយោបាយផ្សេងៗគ្នា និងបានឆ្លុះបញ្ចាំងពីការវិវត្តក្នុងតំបន់ និងពិភពលោកនាសម័យនោះ។ ស្នាដៃអក្សរសាស្រ្តរបស់គាត់ផ្តល់នូវការវិភាគទូលំទូលាយនៃគំនិតអ៊ីស្លាមសម័យទំនើប ក៏ដូចជាសង្គម និងវប្បធម៌មូស្លីម នៅក្នុងគោល

បំណងដើម្បីដាក់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់ការអនុវត្តការងារឌាក់វ៉ះប្រកបទៅដោយភាពជោគជ័យ។

ការងារនេះព្យាយាមពិនិត្យមើលសំណួរដែលទាក់ទងគ្នាជាបន្តបន្ទាប់។ សំណួរសំខាន់ដែលខ្ញុំស្វែងរកចម្លើយគឺ៖ តើគំរូនៃការងារឌាក់វ៉ះណាដែល al-Ghazali បានបង្កើតសម្រាប់អ៊ីស្លាមនាសម័យទំនើបនៅក្នុងការដោះស្រាយបញ្ហានេះ ខ្ញុំបានលើកឡើងនូវបញ្ហាសំខាន់ៗមួយចំនួនទៀត៖ តើអ្វីជាការយល់ដឹងរបស់ al- Ghazali អំពីទីតាំងនៃធម្មជាតិរបស់មនុស្ស (fitrah)លើការងារឌាក់វ៉ះ? តើអ្វីជាផលប៉ះពាល់នៃវប្បធម៌សង្គមលើការអភិវឌ្ឍលើការងារឌាក់វ៉ះ និងតើអ្វីទៅជាតួនាទីលើការលើកខ្ញុំក៏បានធ្វើការពិភាក្សាអំពីឥទ្ធិពលនៃ ?កម្ពស់ការឌាក់វ៉ះចំពោះសេរីភាព និងពហុនិយមខាងសាសនាគំរូនៅក្នុងដំណើរការនៃការឈានទៅមុខ លើការងារឌាក់វ៉ះ ដូចជាសំណួរពាក់ព័ន្ធផ្សេងទៀត ដូចជាការផ្សព្វផ្សាយ សន្តិភាព និងភាពជាសកលនៃការងារឌាក់វ៉ះ។ ជាចុងក្រោយ ខ្ញុំក៏ស្វែងរកការយល់ដឹងអំពីប្រភពដើមនៃគំនិតរបស់ al-Ghazali និងកត្តាសំខាន់ៗដែលរួមចំណែកដល់បញ្ញាញាណរបស់គាត់។

## ជំពូកទី១
## ជីវិត ប្រវត្តិអប់រំ និងការរួមចំណែក
## របស់ Muhammad al-Ghazali:
## កំណែទម្រង់អ៊ីស្លាម (1917-1996)

នៅក្នុងការស្វែងរកនូវការយល់ដឹងពីការបង្កើតគំនិតរបស់គាត់នៅកុមារភាព និងប្រវត្តិអប់រំរបស់ al-Ghazali វាត្រូវបានពិនិត្យ ដោយមានការស្វែងយល់បន្ថែមអំពីភាពស្មុគ្រស្មាញនៃបុគ្គលិកលក្ខណៈរបស់គាត់។ វាត្រូវបានសិក្សាផងដែរ អំពីរបៀបដែលទំនាក់ទំនងរបស់គាត់ជាមួយក្រុមភាតរភាពមូស្លីមដោយបានបង្កើតនូវគំនិត និងរបៀបដែលគាត់ស្វែងរកនូវភាពខុសគ្នានៃក្រុមនីមួយៗ។ ជំពូកនេះបានសិក្សាអំពីការគិត និងការរួមចំណែករបស់ al-Ghazali ដល់អ៊ីស្លាមចំណេះដឹងដែលបំពេញ ដោយការមើលឃើញជារួមនៅក្នុងដំណើរប្រកបដោយវិជ្ជាជីវៈ និងបញ្ញាញាណរបស់គាត់។

### ប្រវត្តិកុមារភាព និងការអប់រំរបស់ Al-Ghazali

Muhammad al-Ghazali al-Saqqa កើតនៅថ្ងៃទី 22 ខែកញ្ញា ឆ្នាំ 1917 នៅក្នុងភូមិ Niklā al-Inab ស្ថិតនៅក្នុងខេត្ត al-Buḥayrah(អេហ្ស៊ីបខាងជើង)។[2] ឪពុករបស់គាត់ឈ្មោះ Ahmad al-Saqqa គឺជាបុរសដែលមានចំណេះដឹងសាសនាអ៊ីស្លាម ដែលជាអ្នកបង្កើតក្តីសង្ឃឹមដ៏អស្ចារ្យសម្រាប់អនាគតរបស់ al-Ghazali។ ទោះបីជាមានការអះអាងផ្សេងទៀតធ្វើឡើង ដោយអ្នកប្រាជ្ញ al-Ghazali ត្រូវបានគេដាក់ឈ្មោះតាមអ្នកប្រាជ្ញសាសនវិទូដ៏អស្ចារ្យ Abū Ḥāmid al-Ghazālī នៃទីក្រុងបាដាត (450-505AH/1058-1111គ.ស)។ មុនពេលរៀបការឪពុករបស់គាត់អះអាងថាមាន

មានការសម្គាល់មួយ ដែល Abū Hāmid al-Ghazālī ឱ្យគាត់ដាក់ឈ្មោះអនាគតកូនប្រុសរបស់គាត់តាមឈ្មោះរបស់គាត់។

ខណៈពេលដែលឈ្មោះរបស់ al-Ghazali ប្រហែលជាមិនប៉ះពាល់ដល់គាត់ខ្លាំងដូចដែលមនុស្សមួយចំនួនចង់ឱ្យយើងជឿនោះទេ វាច្បាស់ណាស់ថាកន្លែងកំណើតរបស់គាត់។ Al-Ghazali ធំធាត់នៅ Niklā al-Inab ជាកន្លែងនៃសាសនាអ៊ីស្លាមដែលមានឥទ្ធិពលដល់អាកប្បកិរិយាជាប្រចាំថ្ងៃ ហើយបានបន្តដល់ពេលគាត់ធំពេញវ័យដែលទាក់ទងយ៉ាងធំដល់សង្គម។[3] ស្នាដៃអត្ថបទរបស់ Al-Ghazali ចង្អុលទៅការអភិរក្សសាសនានៃសហគមន៍នៅមូលដ្ឋានរបស់គាត់ ដោយមានការចាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងការទន្ទេញគម្ពីរអាល់គួរអាន ភាពប៉ិនប្រសប់ ក្នុងការរៀនសូត្រពីអ៊ីស្លាម និងសមត្ថភាពក្នុងការបណ្តុះ បញ្ញវន្ត។ វាអាចនិយាយបានថា ការចងចាំរបស់ al-Ghazali អំពីស្រុកកំណើតរបស់គាត់បានជះឥទ្ធិពលយ៉ាងធំលើការបណ្តុះបណ្តាល និងកម្រិតនៃការអភិវឌ្ឍចរិតរបស់គាត់។ ការចងចាំដ៏សំខាន់បំផុតមួយរបស់ al-Ghazali អំពីភូមិរបស់គាត់ទាក់ទងនឹងការបះបោរប្រឆាំងនឹងអ្នកដឹកនាំ (1919) ។ លោកបានរំឭកអ្នកភូមិដែលបះបោរដោយការកាត់ខ្សែទូរស័ព្ទ ហើយកាន់តែច្បាស់ជាងនេះទៅទៀតគឺការទៅកាន់កាប់ទាហានដែលនៅជុំវិញវិហារអ៊ីស្លាម និងការសម្លាប់កសិករម្នាក់ដែលមិនព្រមគោរពច្បាប់អាជ្ញាសឹក។[4]

លក្ខខណ្ឌសេដ្ឋកិច្ចជុំវិញទីកន្លែងកំណើតរបស់ al-Ghazali អាចត្រូវបានពិពណ៌នាថាជាការលំបាកខ្លាំងណាស់។ Al-Ghazali ធំឡើងនៅក្នុងសង្កាត់ដែលមានការកេងប្រវ័ញ្ច និងជាតំបន់ជនបទដែលទទួលរងនូវការគៀបសង្កត់ ដោយពួកហ្ពាស្ហះ និងព្រះអង្គម្ចាស់នៃតំបន់នោះ។ ភាពអយុត្តិធម៌ និងការកេងប្រវ័ញ្ចនៅក្នុងដៃរបស់ម្ចាស់ដី មានច្រើនសម្បុរបែបដូចការរំលោភបំពានកសិករ ដែលពួកគេទទួលបានផលតិចតួចណាស់ សម្រាប់ភាពលំបាកនឿយហត់របស់ពួកគេ។[5] មិនគួរឱ្យភ្ញាក់ផ្អើលទេ ភាពអយុត្តិធម៌សង្គមទាំងនេះបានបង្កឱ្យមានវណ្ណៈសង្គម ដែលមានគម្លាតដ៏ធំរវាងអ្នកមាននៅក្នុងប្រទេសអេហ្ស៊ីប ជាមួយនឹងវិសមភាពនៃប្រាក់ចំណូល ដូចជាអ្នកខ្លះដាំស្រូវ តែហូបមិនឆ្អែត ដាំកប្បាស តែស្លៀកពាក់មិនស្អាត និងសង់អគារខ្ពស់ៗ តែរស់នៅក្នុងភាពក្រីក្រ។ លក្ខខណ្ឌទាំងនេះបានធ្វើឱ្យ al-Ghazali យល់យ៉ាងខ្លាំងចំពោះការឈឺចាប់ ការកេងប្រវ័ញ្ច និងការធ្វើបាបប្រជាជនទូទៅ។[6]

នៅឆ្នាំ 1914 ម្ចាស់ដីតូចៗតំណាងមានជាង 90ភាគរយនៃម្ចាស់ដីទាំងអស់ ហើយមានកម្មសិទ្ធិតែមួយភាគបួននៃទំហំដីប៉ុណ្ណោះ។ ម្ចាស់ដីធំៗបានបង្កើតក្រុមមួយដែលមានផលប្រយោជន៍រួម ហើយបានផ្តល់ឱ្យពួកគេនូវមុខតំណែងដែលមានឯកសិទ្ធិនៅស្ថាប័នកំពូលៗនៃសង្គមអេហ្ស៊ីប។ នៅឆ្នាំ 1966 ដង់ស៊ីតេប្រជាជនបានកើនឡើងដល់ 845 សម្រាប់មួយគីឡូម៉ែត្រការ៉េ។ ការកើនឡើងនៃសមាមាត្រមនុស្សទៅនឹងទំហំដីនេះ បានជះឥទ្ធិពលអាក្រក់ទៅលើប្រាក់ចំណូលជាមធ្យម ហើយប្រាក់ចំណូលទាបបានរារាំងអ្នកភូមិអេហ្ស៊ីបពីការពង្រីកដីបន្ថែម។ ដីកសិកម្មមានតម្លៃថ្លៃយ៉ាងខ្លាំងក្នុងការទិញលក់។ កសិករនៅផ្នែកខាងក្រោមនៃសង្គមបន្តរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយភាពក្រីក្រ និងកង្វះ

អាហារូបត្ថម្ភ។ ស្ថានភាពសេដ្ឋកិច្ចសង្គមបែបនេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការគិតរបស់ al-Ghazal ដែលនាំឱ្យគាត់សន្និដ្ឋានថាសាសនាមិនអាចរីកចម្រើនក្នុងភាពខ្មៅងងឹត ស្ថានភាពនៃភាពក្រីក្រ ជំងឺ និងភាពល្ងង់ខ្លៅបែបនេះបានឡើយ។[7] របៀបរស់នៅដ៏លំបាកនេះក៏បាននាំឱ្យគាត់មានភាពមមាញឹកនឹងគំនិតទាក់ទងទៅនឹងទំនាក់ទំនងរវាងវឌ្ឍនភាពសាសនា បរិស្ថាន និងរវាងការកែលម្អសេដ្ឋកិច្ច និងការងារឌាក់វ៉ះ។

ការអប់រំរបស់ Al-Ghazali បានរៀនសូត្រពីទីតាំងកន្លែងផ្សេងៗគ្នា ចាប់ពី Kuttāb រហូតដល់វិទ្យាស្ថានសាសនាអាឡិចសាន់ដ្រា និងសាកលវិទ្យាល័យអាល់អាស់ហៀ៊ត។ នៅអាយុ៥ឆ្នាំ al-Ghazali បានចុះឈ្មោះរៀននៅkuttābក្នុងស្រុកដើម្បីរៀនហាហ្វីសទន្ទេញចាំគម្ពីរអាល់គួរអាន។[8] ការរៀននៅក្នុងkuttāb សាលាហាហ្វីសបានធ្វើឱ្យគាត់មានការចេះដឹងលើអក្សរសាស្ត្រអារ៉ាប់ពីគម្ពីរអាល់គួរអាន និងតាមអត្ថន័យ និងអំណាចនៃវាក្យខណ្ឌដែលមាននៅក្នុងអាល់គួរអាន។ ជំនាញនៃការអាន និងការសរសេរតែងតែមានជាបន្តបន្ទាប់ នូវការចងចាំនូវបន្ទូលរបស់ព្រះជាម្ចាស់ដែលមាននៅក្នុងគម្ពីរអាល់គួរអាន តាមរយៈការអានជាប្រចាំថ្ងៃ និងពាក្យដដែលៗនៃវាក្យខណ្ឌនៅក្នុងគម្ពីរដ៏ពិសិដ្ឋនេះ។

នៅឆ្នាំ 1927 នៅអាយុ១០ឆ្នាំ al-Ghazali បានចូលវិទ្យាស្ថានសាសនាអាឡិចសាន់ដ្រា ជាកន្លែងដែលគាត់បានសិក្សារយៈពេល៩ឆ្នាំជាប់ៗគ្នា។[9] ថ្នាក់រៀនរួមមានទាំងសាសនា និងផ្នែកខាងលោកិយវិទ្យាសាស្ត្រ។ ក្នុងពេលជាមួយគ្នានោះ al-Ghazali បានទាញយកគុណប្រយោជន៍ពីហាងលក់សៀវភៅរបស់ឪពុកគាត់។[10] ឪពុករបស់គាត់តែងតែលើកទឹកចិត្តគាត់ឱ្យអានប៉ុន្តែគាត់បានរកឃើញថា ការសោកស្តាយរបស់គាត់ដែល al-Ghazali ចូលចិត្តប្រលោមលោកបរទេសជាងសៀវភៅសាសនា។ ហេតុផលមួយក្នុងចំណោមហេតុផលដែល al-Ghazali ចូលចិត្តជាងនេះ គឺថាសៀវភៅផ្សេងទៀតពោរពេញទៅដោយហាទីសមិនពិត ដែលមិនមានការផ្ទៀងផ្ទាត់ឲ្យបានត្រឹមត្រូវ និងរឿងដែលមិនសមហេតុផល។[11]

នៅឆ្នាំ 1937 al-Ghazali បានចុះឈ្មោះចូលរៀននៅសាកលវិទ្យាល័យអាល់អាស់ហៀ៊ត ។ បន្ទាប់ពីសិក្សារយៈពេល 4 ឆ្នាំ គាត់បានទទួលសញ្ញាបត្រ (Alamiyyah) និងបន្តការសិក្សាថ្នាក់អនុបណ្ឌិតរយៈពេលពីរឆ្នាំនៅជំនាញឌាក់វ៉ះ និងការណែនាំពីសាសនាអ៊ីស្លាម (al-Dawah wa al-Irshad)។ នៅក្នុងអំឡុងពេលសិក្សានៅមហាវិទ្យាល័យ al-Ghazali បានធ្វើការជាអ៊ីមុំានៅវិហារអ៊ីស្លាម al-Atabah al-Khaḍrā' ។ ពេញមួយរយៈពេលនៃការរៀនសូត្រនេះ al-Ghazali ត្រូវបានជះឥទ្ធិពលយ៉ាងខ្លាំងដោយអ្នកប្រាជ្ញសាសនវិទូដូចជា Abd al-Azim al-Zarqani ជាដើម។ គ្រូបង្រៀនដ៏មានឥទ្ធិពលពីរនាក់ទៀតគឺ Ibrahim Gharbawi និង Abd al-Aziz Bilal ។

Al-Ghazali ជារឿយៗបានគិតគូលើការអប់រំដំបូងរបស់គាត់ ពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងទៀតដើម្បីធ្វើឱ្យមានចំណុចដែលមានការកែលម្អចំពោះប្រព័ន្ធអប់រំ ដែលវាពិតជាមានសារៈសំខាន់ណាស់ ហើយតាមពិតទៅ គឺមិនអាចជៀសផុត ឬមិនអាចមិនមាននោះឡើយ ជាតម្រូវការដំបូងសម្រាប់កំណែ

ទម្រង់សង្គមអ៊ីស្លាមនៅក្នុងសម័យទំនើប។ គាត់ក៏បានប្រើបទពិសោធន៍អប់រំរបស់គាត់ដើម្បីវាយតម្លៃ និងចង្អុលបង្ហាញទៅលើបញ្ហាអប់រំរបស់ទូអាត ពោលគឺទំនាក់ទំនងដ៏សំខាន់ដែលមានរវាងការរៀនខាងសាសនា និងការឆាក់រ៉ះ បន្ថែមពីលើការផ្សារភ្ជាប់រវាងការអប់រំប្រកបដោយប្រសិទ្ធភាព និងវឌ្ឍនភាពសាសនា។ Al-Ghazali ជឿជាក់យ៉ាងមុតមាំថា អក្សរសិល្ប៍ផ្នែកសាសនាភាគច្រើនដែលប្រើប្រាស់ដោយសាធារណជន រួមទាំងសៀវភៅដែលចេញដោយសាលាAl-Azhar ខ្លួនវាផ្ទាល់ ពោលគឺសៀវភៅដែលមានប្រភពមិនច្បាស់លាស់ពីអ៊ីស្លាមពិតប្រាកដ គឺមានទាំងខ្លឹមសារ និងរចនាបថមិនល្អ ហើយបានធ្វើឱ្យវប្បធម៌មូស្លីមធ្លាក់ចុះយ៉ាងខ្លាំង។[12] សម្រាប់ al-Ghazali, kuttāb សាលាបង្រៀនមូលដ្ឋាន បានបង្អាក់សកម្មភាពរបស់កុមារ និងរារាំងភាពរីករាយរបស់ពួកគេ ដោយទុកឱ្យពួកគេមានបញ្ហាផ្លូវចិត្ត។[13] លើសពីនេះ លោក al-Ghazali បានចាត់ទុកការប្រើប្រាស់ដំបងវាយសិស្ស ជាការបំផ្លាញដល់សិស្ស ព្រោះការអប់រំរបស់កុមារទាមទារការអាណិតអាសូរការអត់ធ្មត់ ការអត់ឱន និងភាពតឹងរ៉ឹងដោយគ្មានភាពឃោរឃៅនោះឡើយ។ គាត់ជឿថា ទោះបីជាមានចេតនាល្អក៏ដោយ ក៏ kuttābពោលសាលាបង្រៀនខ្លះផលិតបានច្រើនជាង ប្រៀបដូចតែ"ការថតខ្សែអាត់" ពោលចម្លងតគ្នាដែលវាជំនួសឱ្យគំរូដែលមានប្រសិទ្ធភាពទៅវិញ។ ទោះបីជាគាត់មិនសប្បាយចិត្តនឹងគំនិតរៀនសូត្រតែម្នាក់ឯងក៏ដោយ (ដែលប្រៀបដូចជាការថត ខ្សែអាត់ថត') al-Ghazali នៅតែជាអ្នកតស៊ូខិតខំប្រឹងប្រែងលើវិធីសាស្ត្របង្រៀនអាល់គួរអានដែលមានពីមុនមកដែលមានយ៉ាងទូលំទូលាយ។

នាសម័យកាលរបស់គាត់ ការរៀនសូត្រខាងសាសនាអ៊ីស្លាមបានធ្លាក់ចុះដល់កម្រិតទាបបំផុត និងគាត់មានអារម្មណ៍ថាពេលនោះវាមិនបានបម្រើដល់អ៊ីស្លាម ដោយវាមិនបានទាក់ទាញសិស្សដែលមានសមត្ថភាពផងដែរ។ Al-Ghazali មានការយកចិត្តទុកដាក់ចំពោះបញ្ហា៣ខាងក្រោមទាក់ទិននឹងការអប់រំសាសនា៖ ក) កង្វះបញ្ញាខាងផ្លូវអារម្មណ៍ និងបញ្ញាញាណចំពោះសាសនវិទូ[14] ខ) បញ្ហាខាងផ្នែកការសិក្សាវគ្គដំបូងមុនពេលទទួលបានមូលដ្ឋានចំណេះដឹងចាំបាច់សម្រាប់មនុស្ស និងវិទ្យាសាស្ត្រ[15] និង គ) ការយល់ដឹងខ្សោយពីមូលដ្ឋានគ្រឹះអ៊ីស្លាម និងការយកចិត្តទុកដាក់ហួសហេតុចំពោះបញ្ហាតូចតាច។[16]

ការសិក្សារបស់ Al-Ghazali អំពីស្ថានភាពគួរឱ្យអាណិតនៃការអប់រំសាសនាអ៊ីស្លាមបានឆ្លុះបញ្ចាំងពីចំណាប់អារម្មណ៍ដ៏ពិតប្រាកដនៅក្នុងទំនើបកម្មរបស់វាតាមរយៈការអប់រំនៅក្នុងសម័យកាលទំនើប។ សម្រាប់គាត់និស្សិត ដែលបញ្ចប់ការសិក្សាអ៊ីស្លាមគួរតែមិនត្រឹមតែទទួលបានចំណេះដឹងអ៊ីស្លាមតែមួយប៉ុណ្ណោះទេប៉ុន្តែ ក៏ត្រូវយល់ពីវិទ្យាសាស្ត្រទំនើបផងដែរ។ នេះនឹងជួយពួកគេឱ្យប្រើប្រាស់ទស្សនវិស័យ ចំណេះដឹងនៃសម័យទំនើប ដើម្បីផ្សព្វផ្សាយ ណែនាំសាសនាអ៊ីស្លាមនាពេលខាងមុខ ដោយឆាក់រ៉ះត្រូវធ្វើការឲ្យស្របជាមួយនឹងវឌ្ឍនភាពវិទ្យាសាស្ត្រ។ ការរៀនសូត្រហាក់ដូចជាត្រូវបានឲ្យតម្លៃនៅក្នុងលក្ខខណ្ឌនៃការធ្វើឱ្យប្រសើរឡើង នៅក្នុងជីវិតជាសាធារណៈ ជួយមនុស្សឱ្យបញ្ចូលតម្លៃសាសនាអ៊ីស្លាមទៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ឬជាការលើកកម្ពស់កំណែទម្រង់សង្គមដោយរលូនដែលជាតម្រូវការ។

## ការស្វែងយល់ពីបុគ្គលិកលក្ខណៈរបស់ al-Ghazali

នៅក្នុងការអង្កេតថាតើបុគ្គលិកលក្ខណៈរបស់ al-Ghazali មានកម្រិតណា ដែលជះឥទ្ធិពលលើការវាយតម្លៃបែបនេះ ខ្ញុំជឿថា បុគ្គលិកលក្ខណៈសំខាន់ៗដែលប្រហែលជាកំណត់យ៉ាងពិតប្រាកដ ពាក់ព័ន្ធនឹងទំនុកចិត្ត ការប្តេជ្ញាចិត្តចំពោះការពិត ការតស៊ូមតិលើភាពយុត្តិធម៌ សមភាព និងការតស៊ូដើម្បីសេរីភាពពីការកេងប្រវ័ញ្ច និងការអោនលំទោនបន្ទាបខ្លួនរបស់គាត់។ Al-Ghazali បានចាត់ទុកអាកប្បកិរិយា និងបានយកចិត្តទុកដាក់ជាពិសេសចំពោះភាពរីកចម្រើនរបស់មនុស្ស ហើយគាត់មិនចូលចិត្តភាពឈ្លើយ ភាពឆេវឆាវ ឬមនុស្សដែលមានចិត្តត្រជាក់នោះឡើយ។ ទោះបីជា al-Ghazali ចូលចិត្តការអត់ធ្មត់ និងភាពអត់ធ្មត់ក៏ដោយ ពេលខ្លះគាត់បាត់បង់ការគ្រប់គ្រងចិត្តខ្លួនឯង ជាពិសេសនៅពេលគាត់ឃើញមនុស្សល្ងង់និយាយរឿងជាសាធារណៈ ចេញសេចក្តីថ្លែងការណ៍ដែលខុសឆ្គងឬចូលរួមក្នុងការឈ្លោះប្រកែកគ្នាដោយឥតប្រយោជន៍។[17]

Al-Ghazali បានច្រានចោលនូវទង្វើអមនុស្សធម៌ គាត់បានបដិសេធមិនឲ្យមានសូម្បីតែមួយអាតូមតូចនៅក្នុងសេរីភាព និងបញ្ញាញាណរបស់គាត់។ វាជាជំនឿលើសេរីភាពដែលនាំឱ្យគាត់រិះគន់ពេលដើម្បីស្ថាបនាចំពោះវិធីសាស្ត្របង្រៀនចំណេះដឹងសាសនាក៏ដូចជាការផ្សព្វផ្សាយសាសនាអ៊ីស្លាម មានជាច្រើនទៀត ទាក់ទិននឹងជីវិតសង្គម-វប្បធម៌ ពេលនាសម័យកាលនោះ។ គាត់ក៏បានចាត់ទុកបញ្ញាញាណនៃការយល់ដឹងជាមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធសាសនាអ៊ីស្លាម ព្រោះយោងតាមបញ្ញាញាណនៃការយល់ដឹង វាមានទម្ងន់លើសលប់ និងគឺមានតែតាមរយៈបញ្ញាញាណអាកាល់តែប៉ុណ្ណោះដែល អាចធ្វើឲ្យមនុស្សស្គាល់ព្រះជាម្ចាស់ ស្គាល់សេចក្តីពិតនៃសារពីព្រះជាម្ចាស់ និងដឹងពីទំនួលខុសត្រូវរបស់មនុស្សក្នុងនៅថ្ងៃបរលោក។[18] វាច្បាស់ណាស់ថាសេរីភាពបញ្ញាញាណរបស់គាត់បាននាំឱ្យគាត់លើកឡើងនូវសំណួរដែលរិះគន់ជាច្រើនទាក់ទងនឹងជីវិតរបស់អ្នកមូស្លីម និងវិន័យរបស់សាសនាអ៊ីស្លាម ដូចជាជំនឿ វិស័យយុត្តិធម៌ និងប្រវត្តិសាស្ត្រ ពេលការអនុវត្តនាសម័យកាលនោះ។

វាក៏មានប្រយោជន៍ផងដែរក្នុងការពិនិត្យមើលលើបញ្ហារបស់ al-Ghazali ដែលមានដូចជាការប្រើភាសាអវិជ្ជមាន និងនៅពេលខ្លះមានទម្រង់ភាសាដែលមានសំដីអាក្រក់។ ដំណើរបញ្ញវន្តរបស់គាត់មិនថានៅក្នុងសាលលាមូលលដ្ឋាន ឬនៅសាកលវិទ្យាល័យអាល់អាស់ហ្សៀត វាក៏មិនបានផ្តល់ហេតុផលសម្រាប់ប្រតិកម្មដ៏អាក្រក់ ឬសំដីអវិជ្ជមានរបស់គាត់នោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការកើតឡើងនៃព្រឹត្តិការណ៍ធំៗ ហាក់ដូចជាបានជះឥទ្ធិពលដល់គាត់ មានដូចជាការដួលរលំនៃចក្រភពអូតូម៉ង់ ការកេងប្រវ័ញ្ចពីសំណាក់បរទេសលើពិភពអ៊ីស្លាម ការកាន់កាប់ប៉ាឡេស្ទីន និងស្ថានភាពនៅទ្រឹងដែលប៉ះពាល់ដល់សង្គមនៃពិភពមូស្លីម។ គាត់ក៏បានសុំទោសមិត្តអ្នកអានរបស់គាត់ផងដែរចំពោះភាពជូរចត់ និងកំហឹងរបស់គាត់ដែលមាននៅក្នុងសំណេរ មេរៀនដែលគាត់បានទាញចេញពីប្រវត្តិសាស្ត្រ ហើយភាសាខ្លាំងៗរបស់គាត់នោះ គឺកើតមាន នៅក្នុងសម័យកាលនៃការបរាជ័យរបស់អ្នកមូស្លីម។[19] ជាងនេះទៅទៀត ពេលខ្លះសេចក្តីថ្លែងការណ៍របស់ al-Ghazali ហាក់ដូចជាទុទិដ្ឋិនិយម ដោយមិនទុកឲ្យមានក្តីសង្ឃឹមសោះ។ មនោសញ្ចេតនា ឬកំហឹងរបស់គាត់បានកើតចេញពីការប្រៀបធៀបលក្ខ ខណ្ឌទូទៅរបស់ពិភពលោកមូស្លីមជាមួយប្រទេសដទៃទៀត និងភាពមិនពេញចិត្ត

ទាក់ទងទៅនឹងលក្ខខណ្ឌនៃភាពទុក្ខព្រួយ និងភាពអាម៉ាស់ ពោលដោយការធ្លាក់ចុះរបស់ពិភពមូស្លីម នាពេលនោះ។ អ្វីដែលអាចបណ្ដាលឱ្យ al-Ghazali គិតអវិជ្ជមាន ក្នុងវិធីសាស្ត្ររបស់គាត់ គឺវាជាការបង្កើនកម្រិតនៃកំហឹងនៅពេលមានភាពកាន់តែយ៉ាប់យ៉ឺនទៅនៃការពិតជាក់ស្ដែងសង្គម - វប្បធម៌របស់មូស្លីម ពោលនាសម័យកាលនោះ។

## Al-Ghazali និងក្រុមភាតរភាពមូស្លីម

Al-Ghazali បានស្គាល់ Hasan al-Banna មេដឹកនាំក្រុមភាតរភាពមូស្លីម កាលគាត់ជាសិស្សនៅវិទ្យាស្ថានសាសនាអាឡិចសាន់ដ្រាហើយក្រោយមកនៅអាយុ20ឆ្នាំ គាត់បានចូលរួមជាមួយក្រុមមូស្លីមភាតរភាព ជាសមាជិកសកម្មម្នាក់អស់រយៈពេល១៧ឆ្នាំ។[20] Al-Banna បានតែងតាំងគាត់ជាលេខាធិការរង Majallat al-Ikhwan al-Muslimin (ទិនានុប្បវត្តិនៃក្រុមភាតរភាពមូស្លីម)។ តាមពិតទេពកោសល្យសរសេររបស់ Al-Ghazali មានលក្ខណៈគ្រប់គ្រាន់សម្រាប់គាត់គោរមងារកិត្តិយស Adib al-Dawah (អ្នកនិពន្ធលើការងារឌាក់វ៉ះ)នៅក្នុងចំណោមក្រុមភាតរភាពមូស្លីម ហើយជំនាញអក្សរសាស្ត្រ និងសមត្ថភាពបញ្ញាញ្ញាណរបស់គាត់ត្រូវបានបង្ហាញនៅក្នុងស្នាដៃបោះពុម្ពរបស់ពួកគេ។[21] Al-Ghazali បានក្លាយជាសមាជិកសកម្មរបស់ស្ថាប័ន ហើយក៏ជាអ្នកប្រាជ្ញផ្លូវការនៅក្នុងក្រសួងវ៉ាកាហ្វផងដែរ។ ជាញឹកញាប់នៅក្នុងសំណេររបស់គាត់ al-Ghazali បានលើកឡើងថា al-Bannaជាគ្រូដំបូងនិងជាអ្នកណែនាំរបស់គាត់។[22] ភ្លាមៗបន្ទាប់ពីការធ្វើឃាតរបស់ al-Banna នៅឆ្នាំ 1948 បញ្ហានៅក្នុងអង្គការភាតរភាពមូស្លីមបានលេចឡើង។ លោក Al-Ghazaliការខ្វែងគំនិតជាមួយមេដឹកនាំថ្មីគឺលោក Husayn Hudaybi (១៨៩១-១៩៧៣គ.ស.) បណ្ដាលឱ្យមានការបណ្ដេញគាត់ចេញ និងនាំឱ្យមានការចោទប្រកាន់គ្នាទៅវិញទៅមក។[23] អ្វីដែលនាំឱ្យមានការបណ្ដេញលោក al-Ghazali គឺការមិនយល់ស្របលើការសម្រេចចិត្តរបស់ក្រុមភាតរភាពក្នុងការធ្វើពហិការជាមួយរដ្ឋាភិបាលរបស់លោក Jamal Abd al-Nasir។[24] ទោះជាយ៉ាងណាក៏ដោយ តាមការពិតជម្លោះរបស់ al-Ghazali ជាមួយក្រុមភាតរភាពមូស្លីម បានចាប់ផ្ដើមច្រើនពីមុនមកម្លេះ។ ប្រសិនបើ រក្សាទំនាក់ទំនងនយោបាយជាមួយក្រុមភាតរភាព ការរួមចំណែករបស់គាត់ប្រហែលជាមានទិសដៅផ្សេង។ ដូចដែលវាបានកើតឡើង ការផ្ដាច់ទំនាក់ទំនងផ្លូវការរបស់គាត់ពីរចនាសម្ព័ន្ធនៃចលនាភាតរភាពមូស្លីម បានផ្ដល់ឱ្យគាត់នូវសេរីភាពដែលចាំបាច់ដើម្បីដោះស្រាយលើការងារឌាក់វ៉ះដោយឯករាជ្យ ធ្វើការរិះគន់ស្ថាបនាកែលម្អ និងមានវិសាលភាពទូលំទូលាយ។

## សាលានៃគំនិត និងការរួមចំណែករបស់Al-Ghazali ចំពោះចំណេះដឹងអ៊ីស្លាម

ការគិតរបស់ Al-Ghazali បានផ្លាស់ប្ដូរ និងអភិវឌ្ឍក្នុងអំឡុងពេលនៃអាជីពការងាររបស់គាត់។ ការងាររបស់ Al-Ghazali គឺការរៀបចំ Dustūr al-Wiḥdah al-Thaqāfiyyah (ធម្មនុញ្ញនៃការឯកភាពវប្បធម៌) វាបានផ្ដល់សក្ខីកម្មបន្ថែមទៀតអំពីឯករាជ្យភាពដែលកំពុងកើនឡើងរបស់គាត់ ទាក់ទងនឹងវិស័យសំខាន់ៗចំពោះភាពទាក់ទិននឹង ក្ដីកង្វល់ចំពោះចលនាភាតរភាពមូស្លីម ដូចដែលបាន

រៀបរាប់នៅក្នុងគោលការណ៍ទាំង២០របស់ Hasan al-Banna ពោលគឺជាប្រមុខនៃក្រុមនេះ។[25] Al-Ghazaliបានបង្កើតគោលការណ៍ថ្មីចំនួន 10 ដែលជាតម្រូវការសម្រាប់ការអនុវត្តកំណែទម្រង់សម្រាប់សម័យទំនើប: 1) ស្ត្រី និងបុរសគឺជាដៃគូ (shaqā'iq); 2) គ្រួសារតំណាងឱ្យសីលធម៌ និងមូលដ្ឋានគ្រឹះនៃសង្គម (ការគាំទ្រ) ដល់សង្គម និងមជ្ឈមណ្ឌលជាធម្មជាតិស្វ័យប្រវត្តិសម្រាប់ការអប់រំមនុស្សជំនាន់ក្រោយ។ 3)សិទ្ធិខាងសីលធម៌ និងសេដ្ឋកិច្ច មនុស្សគួរតែត្រូវបានធានានិងការពារ 4) អ្នកគ្រប់គ្រង ជាស្តេច ឬប្រធានាធិបតី គឺជាភ្នាក់ងារដែលធ្វើសកម្មភាពជំនួសប្រទេសរៀងៗខ្លួន។ 5) ការពិគ្រោះយោបល់គ្នាទៅវិញទៅមក (shūrā) គឺជាមូលដ្ឋាននៃរដ្ឋាភិបាល គ្រប់ប្រជាជាតិត្រូវតែជ្រើសរើសវិធីសាស្ត្រដែលល្អបំផុតសក្តិសមសម្រាប់ផលប្រយោជន៍របស់ប្រទេស។ 6) លក្ខខណ្ឌ និងសិទ្ធិនៃកម្មសិទ្ធិឯកជនគួរតែត្រូវបានការពារ ជាតិប្រៀបដូចជារូបកាយតែមួយដែលមិនត្រូវអត់ឱនចំពោះការបំពាន ឬការបៀតបៀនណាមួយឡើយ។ 7) ប្រទេសម៉ូស្លីមទទួលខុសត្រូវចំពោះការងារឌាក់វ៉ះផ្សព្វផ្សាយអ៊ីស្លាម 8) ភាពខុសគ្នាខាងសាសនាមិនគួរបង្កឱ្យមានការទាស់ទែងគ្នា ឬការប្រយុទ្ធគ្នាឡើយ។ 9) ទំនាក់ទំនងរបស់មូស្លីមជាមួយសហគមន៍អន្តរជាតិគួរតែត្រូវបានដឹកនាំដោយកិច្ចព្រមព្រៀងនៃភាពជាបងប្អូនក្នុងនាមជាមនុស្សជាតិដូចគ្នា ប្រជាជនមូស្លីមគួរតែអនុវត្តន៍ការងារឌាក់វ៉ះ តាមរយៈការជជែកវែកញែក / ការបញ្ចុះបញ្ចូលធ្វើយ៉ាងណាឲ្យឆ្ងាយពីភាពគ្រោះថ្នាក់ណាមួយ និង 10) មូស្លីមត្រូវការរួមចំណែកគាំពារដល់សីលធម៌ និងសុខុមាលភាពនៃរូបរាងកាយរបស់មនុស្ស។[26]គោលការណ៍ទាំងនេះគឺសំដៅលើកំណែទម្រង់នៅក្នុងសាសនាពោលវិធីសាស្ត្រនៃការឌាក់វ៉ះនៅក្នុងសង្គមមូស្លីម។

កង្វល់ចម្បងមួយចំនួនរបស់ al-Ghazali រួមមានបញ្ហា ដូចជាការបែកបាក់សង្គមនៃសាសនាអ៊ីស្លាម ស្ថានភាពបច្ចុប្បន្ននៃវប្បធម៌មូស្លីម អាកប្បកិរិយាអវិជ្ជមានចំពោះជីវិត ការស្លាប់បាត់បង់ជីវិតរបស់ប្រជាជននៅក្នុងពិភពមូស្លីម ការយល់ខុសអំពីគោលការណ៍នៃបុព្វហេតុដើម ទំនៀមទម្លាប់នៃការផ្សព្វផ្សាយនៅក្នុងសង្គមមូស្លីម ស្ថានភាពរបស់ស្ត្រីក្នុងដំណាក់កាលនៃភាពទន់ខ្សោយ និងការធ្លាក់ចុះ នៃសង្គមមូស្លីម កម្រិតខ្សោយនៃអក្សរសិល្ប៍អារ៉ាប់ ការគ្រប់គ្រងទ្រព្យសម្បត្តិមិនត្រឹមត្រូវ និងអំពើពុករលួយនៅក្នុងនយោបាយ។[27] គាត់មិនត្រូវនឹងចលនាមូស្លីមណាមួយឡើយចំពោះការរិះគន់ឥតឈប់ឈររបស់គាត់ វាអាចត្រូវតែនៅក្នុងបរិយាកាសនៃសេរីភាព និងឯករាជ្យប៉ុណ្ណោះ។ ការព្រួយបារម្ភរបស់គាត់គឺដើម្បីពិនិត្យមើលឡើងវិញ និងលុបបំបាត់ការយល់ដឹងអំពីប្រភពនៃការបកស្រាយរបស់មូស្លីម ដើម្បីឱ្យប្រជាជនមូស្លីមអាចទទួលបានតំណែងរបស់ពួកគេក្នុងសង្គមមនុស្សជាតិឡើងវិញ ពោលក្នុងនាមជាមហាអំណាចពិភពលោកដូចសម័យមុន។

Al-Ghazali ជឿជាក់លើស្នាដៃការងាររបស់គាត់ ដើម្បីឆ្លុះបញ្ចាំងអំពីការពិត។ ពួកគេមានគោលបំណងជម្រុញមនសិការដែលមាននៅក្នុងដួងចិត្តអ្នកមានជំនឿ និងដើម្បីផ្តល់គន្លឹះទៅកាន់អត្ថន័យផ្សេងៗដែលមិនអាចកាត់ថ្លៃបានដល់ប្រជាជនមូស្លីម។[28] ស្នាដៃអត្ថបទរបស់គាត់ឆ្លើយតបនឹងតម្រូវការបញ្ញាញាណ និងអារម្មណ៍របស់បុគ្គល និងសង្គម។[29] ស្នាដៃអត្ថបទរបស់គាត់ក៏ផ្តល់នូវការបង្ហាញពីភាពយ៉ាងច្បាស់ និងភាពមិនច្បាស់លាស់នៃគំនិត និងអារម្មណ៍ ដែលភាគច្រើនរងឥទ្ធិពលដោយអារម្មណ៍ងប់ងល់និងភាពសប្បាយរីករាយ។[30]

**ជីវិតប្រកបដោយវិជ្ជាជីវៈ និងបញ្ញាញាណរបស់ Al-Ghazali**

Al-Ghazali បានងើបឡើងបន្តិចម្តងៗ នៅក្នុងឋានានុក្រមរដ្ឋបាលនៃនាយកដ្ឋានផ្សព្វផ្សាយសាសនាអ៊ីស្លាម នៅក្នុងក្រសួងវ៉ាកាហ្វនៃប្រទេសអេហ្ស៊ីប។ គាត់ត្រូវបានតែងតាំងជាអ្នកមើលការខុសត្រូវនៃវិហារអ៊ីស្លាម និងជាខតីបនៅអាល់អាស់ហ្សើត ជានាយកវិហារអ៊ីស្លាម និងជាប្រធានដឹកនាំវគ្គបណ្តុះបណ្តាលនានា ហើយចុងក្រោយជានាយកនៃស្ថាប័នផ្សព្វផ្សាយឌាក់វ៉ះអ៊ីស្លាម al-Dawah wa al-Irshad។ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧១ លោក Abd al-Aziz Kamil ដែលជារដ្ឋមន្ត្រីនៃក្រសួងវ៉ាកាហ្វ និងកិច្ចការអាល់អាស់ហ្សើត បានតែងតាំងគាត់ជាអនុរដ្ឋលេខាធិការនៅក្រសួងវ៉ាកាហ្វ។ នៅខែមីនា ឆ្នាំ១៩៨១ លោក Anwar al-Sadat ប្រធានាធិបតីអេហ្ស៊ីប (១៩៧0-១៩៨១) បានតែងតាំងគាត់ជាអនុរដ្ឋលេខាធិការទទួលបន្ទុកលើការងារឌាក់វ៉ះនៅក្នុងក្រសួងវ៉ាកាហ្វ។ តាមរយៈការសរសេរ សុន្ទរកថា ធម្មទេសនា ការបង្រៀន ការផ្សាយតាមវិទ្យុ និងទូរទស្សន៍ Al-Ghazali ត្រូវបានគេស្គាល់ថា គាត់បានបន្សល់ទុកនូវឥទ្ធិពលជាក់ស្តែងលើចិត្តរបស់ប្រជាជនមូស្លីមនៅក្នុងប្រទេសអេហ្ស៊ីប និងកន្លែងផ្សេងទៀត។ នៅក្នុងចំណោមគំនិតផ្តួចផ្តើមជាច្រើនដែលគាត់បានគាំទ្រ Al- Ghazali បានជានាដល់ការចូលរួមរបស់ស្ត្រីនៅក្នុងវិហារអ៊ីស្លាមជាច្រើន។

ការបង្រៀន និងការបោះពុម្ពផ្សាយរបស់ Al-Ghazali ដែលមានការរិះគន់យ៉ាងខ្លាំងចំពោះលក្ខខណ្ឌនៅក្នុងប្រទេសអេហ្ស៊ីប និងបានបង្ហាញពីការឃុបឃិតប្រឆាំងនឹងសាសនាអ៊ីស្លាម និងសង្គមមូស្លីមបានធ្វើឱ្យអាជ្ញាធរអេហ្ស៊ីបខកចិត្ត។ ហើយនេះបាននាំឱ្យមានការហាមប្រាមលើសកម្ម ភាពសាសនារបស់គាត់ ហើយគាត់ត្រូវបានដាក់ក្នុងបញ្ជីខ្មៅដោយរដ្ឋាភិបាលអេហ្ស៊ីប នៅក្នុងឆ្នាំ ១៩៧៤។ [31] បន្ទាប់ពីការព្យួររបស់គាត់ពីការអនុញ្ញាតិឲ្យឡើងខុតហ្ពះ នៅក្នុងវិហារ Amru ibn al-CĀṣ សៀហ្គ Al-Ghazali បានទទួលតួនាទីនៅសាកលវិទ្យាល័យ King Abd al-Aziz ទីក្រុងជុទ្ធះ និងក្រោយមកនៅសាកលវិទ្យាល័យUmmal-Qura,នៅទីក្រុងម៉ាកាស់អារ៉ាប៊ីសាអូឌីត។ នៅទីនោះគាត់បានបន្តធ្វើការនូវការងារឌាក់វ៉ះ របស់គាត់តាមរយៈកម្មវិធីផ្សព្វផ្សាយទូរទស្សន៍ និងកាសែត ខណៈពេលដែលការបង្រៀន និងការងារត្រួតពិនិត្យនិស្សិតនាពេលបញ្ចប់ការសិក្សាផងដែរ គាត់បានបម្រើការនៅក្រុមប្រឹក្សាសិក្សាផ្សេងៗទៀត នៅក្នុងសាកលវិទ្យាល័យអ៊ីស្លាមនានា និងបានចូលរួមក្នុងបម្រើការងារនៅទីភ្នាក់ងារផ្សព្វផ្សាយការងារឌាក់វ៉ះ។ ជាឧទាហរណ៍ នៅប្រទេសកាតា Al-Ghazali បានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍមហាវិទ្យាល័យសារីអះច្បាប់អ៊ីស្លាមនៃសាកលវិទ្យាល័យប្រទេសកាតា និងការផ្សព្វផ្សាយការយល់ដឹងអំពីសាសនាអ៊ីស្លាម តាមរយៈប្រព័ន្ធផ្សព្វផ្សាយ វិហារអ៊ីស្លាម និងសមាគមនានា។ នៅឆ្នាំ 1984 al-Ghazali ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាសិក្សាធិការនៃសាកលវិទ្យាល័យ El-Emir Abdelkadir នៅទីក្រុង Constantine ប្រទេសអាល់ហ្សេរី។ នៅឆ្នាំ1989 និងបន្ទាប់៧ឆ្នាំនៅអាល់ហ្សេរី al-Ghazali បានត្រឡប់ទៅអេហ្ស៊ីប។

នៅក្នុងអំឡុងពេលរស់នៅចុងក្រោយរបស់គាត់នៅក្នុងប្រទេសអេហ្ស៊ីប al-Ghazali បានធ្វើការងារស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់លើវិធីសាស្ត្រនៃការសិក្សាគម្ពីរអាល់គួរអាន ដែលជាស៊ុនណះ មរតកបញ្ញាញាណសម្រាប់អ្នកមូស្លីម និងជាបញ្ញាញាណសម្រាប់ជនមូស្លីមនាសម័យទំនើប។ ទោះបីយ៉ាង

ណាក៏ដោយពេញមួយអាជីពសិក្សារបស់គាត់។ Al-Ghazali រក្សាបាននូវចំណាប់អារម្មណ៍យ៉ាងខ្ជាប់ខ្ជួនចំពោះការងារឌាក់វ៉ះ។ ស្នាដៃសិក្សាលើការងារឌាក់វ៉ះ របស់ Al-Ghazaliបានផ្តល់នូវទស្សនវិស័យ ដែលនិយាយលើកឡើងអំពីមនុស្សជាច្រើននូវទិដ្ឋភាពជីវិតបញ្ញវន្ត វប្បធម៌ និងសង្គមនយោបាយរបស់មូស្លីម និងក៏ពិនិត្យមើលមូលហេតុនៃបញ្ហានៅវិស័យសាសនា និងសង្គមផងដែរ។ ការរួមចំណែករបស់ Al-Ghazali មិនថាតាមរយៈ ចលនាភាតរភាពមូស្លីម សាកលវិទ្យាល័យមូស្លីម ឬនៅក្នុងក្រសួងវ៉ាកាហ្វត្រូវបានធ្វើឡើង ក្នុងរបៀបនៃអ្នកកាន់សាសនាអ៊ីស្លាមមានលក្ខណៈជាប្រពៃណីពីមុនមក។ ទោះបីជាយ៉ាងនេះក្តី វិធីសាស្ត្របែបប្រពៃណីរបស់គាត់ បានតស៊ូមតិបង្កើតទស្សនៈថ្មីគាំទ្រដល់ការផ្លាស់ប្តូរសម្រាប់សម័យទំនើប ដោយការមិនសង្កត់ធ្ងន់លើបែបបទសាសនា និងបានរិះគន់ពីរបៀបរបបឌាក់វ៉ះផ្សព្វផ្សាយអ៊ីស្លាមនៅសម័យទំនើប។ ស្នាដៃរបស់គាត់ពណ៌នាអំពីបញ្ហានៃសង្គម និងវប្បធម៌ ព្យាយាមវិនិច្ឆ័យលើភាពទន់ខ្សោយ និងការបរាជ័យដែលមានស្រាប់ និងបង្ហាញពីទំនួលខុសត្រូវ និងបញ្ហាប្រឈមសម្រាប់ការងារឌាក់វ៉ះ។ សាវតាបញ្ញាដ៏ទូលំទូលាយ និងបទពិសោធន៍ចម្រុះរបស់គាត់ក៏ត្រូវបាននាំចូលទៅក្នុងការអភិវឌ្ឍគំនិត លើការងារឌាក់វ៉ះ សិក្សាពីឧបសគ្គខាងវប្បធម៌ដល់ការងារឌាក់វ៉ះ ពិនិត្យឡើងវិញនូវផលប៉ះពាល់លើផ្លូវច្បាប់តាមប្រទេសលើការងារឌាក់វ៉ះ និងរិះគន់ដើម្បីស្ថាបនានៅក្នុងសម័យបច្ចុប្បន្ន ដោយសារការមិនបានបង្ហាត់បង្រៀន មិនបានត្រៀមខ្លួន និងមានចិត្តចង្អៀតចំពោះដាអ៊ី អ្នកធ្វើការងារឌាក់វ៉ះមួយចំនួន។ ការងាររបស់គាត់ក៏បង្កើតផងដែរនូវទំនាក់ទំនងផ្នែកពិតជាក់ស្តែង រវាងភាពពិសិដ្ឋក្នុងសាសនាអ៊ីស្លាម និងរឿងពិតក្នុងលោកិយ ដែលមានក្នុងសាសនា និងសម័យទំនើប និងជីវិតរបស់មនុស្សលោក។

គំនិតរបស់គាត់បានបកប្រែគំនិតសំខាន់ៗនៃកំណែទម្រង់អ៊ីស្លាមសហសម័យ រួមទាំងទស្សនៈរបស់គ្រូរបស់គាត់គឺ Hasan al-Banna ទាក់ទងនឹងធម្មជាតិដ៏ទូលំទូលាយនៃសាសនាអ៊ីស្លាម ដែលស្ថិតនៅរវាងពិភពសាសនា និងពិភពលោក។ ប៉ុន្តែជំនួសឱ្យការនិយាយក្នុងន័យសាសនាទូលំទូលាយ Al-Ghazali បានជ្រើសរើសផ្លាស់ប្តូរការយកចិត្តទុកដាក់ទៅលើទំនាក់ទំនងជាមូលដ្ឋានថ្មីរវាង ការងារឌាក់វ៉ះ និងជីវិត ហេតុដូច្នេះហើយវាត្រូវបានគាត់ដាក់បញ្ហាប្រឈមលើការងារឌាក់វ៉ះនៅក្នុងសម័យទំនើបនៅចំកណ្តាលស្នាដៃនិក្ខេបបទស្តីពីការងារឌាក់វ៉ះផ្សព្វផ្សាយអ៊ីស្លាមរបស់គាត់តែម្តង។

## ជំពូកទី២
## ការវិភាគទ្រឹស្តីនៃការងារឌាក់វ៉ះ

វាត្រូវបានបញ្ជាក់ថា វាជាក្របខ័ណ្ឌគោលគំនិត Al-Ghazali បានដាក់ចេញសម្រាប់ការបន្លិចអំពីការឌាក់វ៉ះ និងគូសបញ្ជាក់អំពីបរិបទសាសនា វប្បធម៌ និងសេដ្ឋកិច្ចសង្គម។ Al-Ghazali បានផ្សារភ្ជាប់ទៅនឹងគំនិតសំខាន់ៗចំនួន២។ ទី១ ធម្មជាតិរបស់មនុស្សដំបូងបង្អស់ក្នុងការព្យាយាម និងស្វែងរកវិធីសាស្ត្រ ដើម្បីអនុវត្តន៍ការងារឌាក់វ៉ះឲ្យស្របតាមធម្មជាតិរបស់មនុស្ស។ ទី២ សេដ្ឋកិច្ច សង្គម និងបរិបទវប្បធម៌នៃការងារឌាក់វ៉ះ ដែលមិនត្រឹមតែរួមបញ្ចូលការពិភាក្សាអំពីបញ្ហាសង្គម និងសេដ្ឋកិច្ចដែលវារារាំងលើការងារឌាក់វ៉ះនាពេលបច្ចុប្បន្នប៉ុណ្ណោះនោះទេ ប៉ុន្តែក៏មានការរួមផ្សំគ្នារវាងតួអង្គជា

មូលដ្ឋាននៃការងារឃោសនា ជាមួយធម្មជាតិ និងតម្រូវការរបស់សង្គមដែលតែងតែផ្លាស់ប្តូរជានិច្ច។ នៅក្នុងបរិបទនេះ សំណួរសំខាន់ៗត្រូវបានលើកឡើងទាក់ទងនឹងទំនាក់ទំនងរវាង ការងារឃោសនា និងសេរីភាព និងវិសាលភាពនៃការអភិវឌ្ឍរបស់ Al-Ghazali លើការងារឃោសនាជាសាកល វាបានអនុញ្ញាតឱ្យគាត់ពិនិត្យមើលការងារឃោសនា ឲ្យហួសពីព្រំដែនភូមិសាស្ត្រនៃពិភពមូស្លីម។

## ក្របខណ្ឌគំនិតរបស់ Al-Ghazali

នៅក្នុងការតាមដានក្របខណ្ឌគំនិតរបស់ Al-Ghazali និងការរួមចំណែកអំពីវិធីសាស្ត្ររបស់គាត់ចំពោះការសិក្សារបស់ការងារឃោសនា វាជាការសំខាន់ក្នុងការកត់សម្គាល់ថាA-Ghazali បានចាត់ទុកគម្ពីរអាល់គួរអានថាជាការបង្ហាញពីខ្លឹមសារលើការងារឃោសនាដ៏ទូលំទូលាយនៃវឌ្ឍនភាពរបស់វា និងក៏បានលើកឡើង អំពីភាពលំបាកដែលបានស៊ូទ្រាំពុះពារក្នុងការងារឃោសនាផ្សព្វផ្សាយសារពីព្រះអល់ឡោះជាម្ចាស់ទៅកាន់មនុស្សលោក។ គាត់បានគូសបន្ថែមទៀតលើគំរូការងារឃោសនា ដែលកំណត់ដោយព្យាការីមុនៗ។ ដំណើររឿងរបស់គម្ពីរអាល់គួរអាន ទាក់ទងនឹងការងារឃោសនា ដែលទាក់ទងនឹងព្យាការី បានបង្ហាញថា ពេញមួយជីវិតនៃការងាររបស់ព្យាការីក្នុងការនាំយកសារពីអល់ឡោះជាម្ចាស់ ទៅកាន់មនុស្សលោក នោះគឺបន្តសង្កត់ធ្ងន់លើគោលការណ៍មួយ ពោលគឺ ថាគ្មានការផ្តល់ជូនសំណងខាងសម្ភារៈ ឬរង្វាន់ពេលប្រាក់កម្រៃណាមួយត្រូវបានផ្តល់ជូនព្យាការីនោះឡើយចំពោះការងារផ្សព្វផ្សាយឃោសនាអ៊ីស្លាមរបស់ពួកគាត់។ ព្យាការីមិនមែនជាអ្នកលក់ពាក្យសម្តី ឬអ្នកទាមទារកិត្តិនាមឡើយ។ ពួកគេបានឲ្យតែមិនយកវិញ និងជ្រើសរើសរើសយកការលះបង់ដោយមិនស្វែងរកផលប្រយោជន៍ ឬផលតបស្នងឡើយ។ [32] សម្រាប់ Al-Ghazali ឧទាហរណ៍ទាំងនេះបានបង្ហាញឱ្យឃើញថា ការអនុវត្តការងារឃោសនាគួរតែគ្មានគោលបំណងខាងលោកិយពោលក្នុងការងារដ៏មានតម្លៃនេះឡើយ។

លើសពីនេះទៀត ការងារឃោសនា គឺមានភាពត្រង់ សាមញ្ញ អាចយល់បាន មានភាពស្មោះត្រង់ និងមេត្តាករុណា។[33] តម្លាភាពដែលមាននៅក្នុងការងារឃោសនា ត្រូវបានបង្ហាញនៅក្នុងសារដែលច្បាស់លាស់ និងសារដែលមានអត្ថន័យបង្កប់យ៉ាងជ្រាលជ្រៅ។ [34] ព្យាការីបានជួបមនុស្សទាំងអស់មិត្ត ឬសត្រូវ ដោយមិនគិតពីបុគ្គលនោះឡើយ និងមិនបានឃាត់ទុកនូវឯកសារនៃសាសនាណាមួយរបស់ពួកគេដែរ។ [35] ដូច្នេះការងារឃោសនា គឺបើកចំហ និងតម្លាភាព សំណួរជាមូលដ្ឋាន ឬបន្ទាប់ត្រូវបានគ្រប់គ្នា សាធារណជន ឬមហាជន និងឥស្សរជនដឹង និងបានស្គាល់ដូចគ្នា។ ការងារឃោសនា មិនគួរបិទបាំងសំណួរសម្ងាត់ណាមួយ ឬលាក់បាំងទិដ្ឋភាពជាក់លាក់ណាមួយឡើយ និងត្រូវបញ្ចេញឱ្យដឹងទៅអ្នកផ្សេងទៀតផងដែរ។[36] លើសពីនេះ Al-Ghazali ជឿថា ភាពអស្ចារ្យនៃសារអល់ឡោះជាម្ចាស់ត្រូវបានបង្ហាញដោយគុណតម្លៃរបស់វា។ ការប្រើបញ្ញាធ្វើការបដិសេធ ឬសន្និដ្ឋាន និងការសង្ស័យ ពោលមិនត្រូវមានឡើយចំពោះសាររបស់អល់ឡោះជាម្ចាស់ ប៉ុន្តែចាំបាច់ត្រូវការនូវការប្រកាន់ខ្ជាប់លើភាពប្រាកដប្រជា និងការពិតរបស់សារនោះវិញ ពោលទើបជារឿងត្រឹមត្រូវ។ អោ អ្នកមានជំនឿទាំងលាយ ចំណេះដឹងពីសាររបស់ព្រះជាម្ចាស់មិនសាបសូន្យនូវបញ្ញាដោយសេចក្តីមិន

ប្រមាថ ហើយក៏មិនជ្រួតជ្រាបក្នុងពិភពនៃការស្រមើស្រមៃនោះដែរ។ [37] វាប្រហែលជាផ្អែកលើការបញ្ចុះបញ្ចូលខាងទ្រឹស្តីទាំងនេះ ដែល Al-Ghazali បន្តស្វែងរកដើម្បីភ្ជាប់ដួងវិញ្ញាណលើការងារឌាក់វ៉ះ ជាមួយនឹងចំណេះដឹងនៃវិទ្យាសាស្ត្រ ដើម្បីពង្រឹងការយល់ដឹង និងការបកស្រាយសាសនាបន្ថែមទៀត ខណៈពេលដែលចូលរួម លើការងារឌាក់វ៉ះ នៅក្នុងផ្នែកនៃការស្រាវជ្រាវវិទ្យាសាស្ត្រ។ តាមពិតទៅ Al-Ghazali បានលើកឡើងថា ស្ពានរវាងសាសនា និងវិទ្យាសាស្ត្រគឺសំខាន់ណាស់ ព្រោះសាសនានឹងបាត់បង់ភាពរីកចម្រើន របស់វានៅពេលដែលវាមើលរំលងវិទ្យាសាស្ត្រ រំលងលើការបង្ហាញហេតុផល ឬរួមបញ្ចូលសាសនាជាមួយនឹងពិភពពិភពលោក។[38]

វិធីសាស្ត្ររបស់ Al-Ghazali ចំពោះសាសនា វាបានចង្អុលបង្ហាញទៅគោលដៅដែលមានស្រាប់ និងគោលដៅបន្ទាប់ដែលស្ថិតនៅក្រោមបន្តបន្ទាប់។ គោលគំនិតនៃសារពីអល់ឡោះជាម្ចាស់នៅក្នុងសាសនា ត្រូវរក្សានៅជួរមុខ ដោយប្រើមធ្យោបាយនៃការផ្សព្វផ្សាយអំពីសេចក្តីល្អ ការតស៊ូមតិនៃសេចក្តីសុចរិត ការការពារសេចក្តីជំនឿ និងបង្ហាញអំពីគុណធម៌ [39] បន្ថែមពីលើការបញ្ជូនបន្ថែមនៃអត្ថន័យដ៏អស្ចារ្យនៃសារពីព្រះជាម្ចាស់ទៅកាន់ប្រជាជាតិនានាស្ថិតនៅក្នុងភាពត្រូវការ។ សារពីព្រះជាម្ចាស់នៅក្នុងសាសនាស្វែងរកនិរន្តរភាពយុត្តិធម៌ និងសេរីភាពសម្រាប់ប្រទេសដែលត្រូវបានគេសង្កត់សង្កិន និងដកហូតសិទ្ធិ ដោយ ផ្តល់នូវសិទ្ធិសេរីភាព ភាពប្រាកដប្រជា និងភាពស្មោះត្រង់តាមរយៈការលើកទឹកចិត្ត និងការណែនាំ[40] ភ្ញាក់រលឹកឡើងវិញ ដួងចិត្តដែលភ្លេចព្រះជាម្ចាស់ និងត្រូវមានចិត្តនឹកគិតឡើងវិញ និង[41] ដោយផ្អែកលើការពិពណ៌នាអំពីសាសនានេះ Al-Ghazaliពិពណ៌នាបន្ថែមទៀតថាការងារឌាក់វ៉ះអ៊ីស្លាមថា វាកើតមកព្រមជាមួយនឹងកំណើតនៃសេចក្តីជំនឿ។ វាគឺកើតមកព្រមគ្នារវាងជំនឿនៃសាសនាអ៊ីស្លាមនិងសីលធម៌។ [42] ការងារឌាក់វ៉ះសម្រាប់គាត់គឺជាការណែនាំដល់សេចក្តីពិតដ៏មានតម្លៃបំផុតនៅក្នុងសកលលោក ដែលជាការតម្រង់ទិសទៅរកភាពល្អ និងជាសេចក្តីសង្គ្រោះពីការបំផ្លិចបំផ្លាញ។ [43] Al-Ghazali បានប្រកែកថាការកាត់បន្ថយវិសាលភាពនៃការងារឌាក់វ៉ះទៅជាសកម្មភាពដាច់ដោយឡែកតែឯង គឺមិនសមហេតុផលទេ។[44] ជាលទ្ធផល គាត់បានរិះគន់អ្នកដែលយល់ ការងារឌាក់វ៉ះ ថាជាការទេសនាធម្មតាអំពីផ្លូវចិត្ត។[45] ការនិយាយធម្មតា ការនិយាយបញ្ជិតបញ្ជៀង ឬសូម្បីតែការអធិប្បាយគឺជាទិដ្ឋភាពតែមួយនៅក្នុងការចូលរួមឲ្យសាសនាមានភាពដ៏ទូលំទូលាយ។ [46]ជាមួយនឹងទស្សនៈនេះនៅក្នុងចិត្ត Al-Ghazali មិនយល់ព្រមក្នុងការផ្តល់ងារជា ដាអ៊ី ដល់ត្រឹមគ្រូបង្រៀនអ៊ីស្លាម ឬអ៊ីម៉ាមតែប៉ុណ្ណោះនោះទ។ [47]ទូអាត អ្នកផ្សព្វផ្សាយអ៊ីស្លាម សម្រាប់គាត់គឺមានរួមបញ្ចូលទាំងអ្នកគ្រប់គ្រងដ៏មានសុចរិត មេធាវី អ្នកដែលមានសមត្ថកិច្ច ឬអ្នកបង្កើតច្បាប់ អ្នកនិពន្ធ អ្នកអធិប្បាយដ៏ស្មោះត្រង់ និងផ្សេងទៀត។ [48] បុគ្គលម្នាក់ៗអាចចូលរួមចំណែកផងដែរ ជាបុគ្គល ឬជាសមូហភាពចំពោះសាសនា ក្នុងជីវិតនៃសង្គម វប្បធម៌ ឬនយោបាយ។ [49] ឌាក់វ៉ះ គឺជាឧបករណ៍យុទ្ធសាស្ត្រនៃកំណែទម្រង់ដែលមានចូលរួមគ្រប់ប្រភេទពីអ្នកមប្រើការងារ និងអ្នកស្ម័គ្រចិត្ត។ ការយល់ដឹងរបស់ Al-Ghazali អំពីការងារឌាក់វ៉ះមើលទៅមានលក្ខណៈទូលំទូលាយ និងឆ្លុះបញ្ចាំងពីវិធីសាស្ត្រទូលំទូលាយរបស់គាត់ចំពោះសាសនាអ៊ីស្លាមអំពីកំណែទម្រង់។

ទស្សនៈទូលំទូលាយរបស់គាត់អំពីការងារឆាក់វ៉ះ រួមបញ្ចូលយ៉ាងជិតស្និទ្ធ ទំនាក់ទំនងរវាង ឆាក់វ៉ះ និងសញ្ញាណនៃការផ្លាស់ប្តូរវិធីសាស្ត្រលើការងារនោះ។ ឆាក់វ៉ះ មិនត្រឹមតែពាក់ព័ន្ធនឹងការបញ្ជូនការបង្រៀនសាសនាប៉ុណ្ណោះទេ ឬការបកស្រាយគម្ពីរអាល់គួរអានទៅកាន់សហគមន៍មូស្លីមប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ជាការទទួលយកការរួមចំណែកយ៉ាងច្រើនរបស់អ្នកដែលចូលរួមកំណែទម្រង់សង្គមផងដែរ។ ការពង្រីករបស់គាត់អំពីសញ្ញាណលើការងារឆាក់វ៉ះ និងការពង្រីក និងវិសាលភាពរបស់គាត់ គឺដើម្បីទទួលយកសង្គមកាន់តែទូលំទូលាយ។ ការផ្លាស់ប្តូរគឺផ្អែកលើជំនឿរបស់គាត់លើលក្ខណៈទូលំទូលាយនៃសិក្ខាបទរបស់អ៊ីស្លាម និងផ្អែកលើការជឿជាក់របស់គាត់ថា ការយល់ដឹងអំពីសាសនាមិនគួរបែកខ្ញែកឬដាក់ឲ្យនៅដាច់ដោយឡែកនោះឡើយ។[50]

## Fitrah

គោលគំនិតនៃfitrah ដើរតួនាទីសំខាន់នៅក្នុងនិក្ខេបបទរបស់គាត់សម្រាប់ ហេតុផលដែល Al-Ghazali ប្រើវាដើម្បីកំណត់លើការងារឆាក់វ៉ះ នៅក្នុងក្របខ័ណ្ឌនៃ អាកប្បកិរិយារបស់មនុស្ស និងការឡើងទៅកាន់គុណតម្លៃនៃសារពីព្រះជាម្ចាស់។ Al-Ghazali បានព្យាយាមបង្កើតភាពជិតស្និទ្ធមួយ នូវទំនាក់ទំនងរវាងការងារឆាក់វ៉ះ និងលក្ខណៈនៃធម្មជាតិរបស់មនុស្សនៅលើដៃម្ខាង និងនៅលើដៃម្ខាងផ្សេងទៀតលើការអភិវឌ្ឍពិតប្រាកដនៃការអភិវឌ្ឍសាសនា។ ទោះបីជាយ៉ាងណាក៏ដោយការសន្មតជាមូលដ្ឋានគឺថាការងារឆាក់វ៉ះ សម្របសម្រួលបរិយាកាសគាំទ្រសម្រាប់តំឡើងឋានៈរបស់មនុស្សឆ្ពោះទៅរកភាពល្អឥតខ្ចោះខាងដួងវិញ្ញាណ ពេលជំនឿលើអ៊ីស្លាម សីលធម៌ និងសាសនាជាទូទៅ ខណៈពេលដែលផ្តល់នូវការបញ្ចប់ដល់ចំណេះដឹងដែលមានលក្ខណៈវិចារណញ្ញាណដែលមានស្រាប់ហើយ ដោយមិនចាំបាច់រួមចំណែកដល់ការបង្រៀនថ្មីណាមួយឡើយ ពោលគឺមានន័យថាសេចក្តីបង្រៀនរបស់អ៊ីស្លាមមិនត្រូវបានអនុញ្ញាតិឲ្យមានការបញ្ចូល ឬបង្កើតថ្មីណាមួយ ដោយប្រើនូវចំណេះដឹងរបស់មនុស្សនោះឡើយ។ Al-Ghazali បានព្យាយាមបង្កើតភាពជិតស្និទ្ធមួយរវាងទំនាក់ទំនងរវាងការងារឆាក់វ៉ះ និងលក្ខណៈនៃធម្មជាតិរបស់មនុស្សនៅលើដៃម្ខាង និងនៅលើដៃផ្សេងទៀតលើការអភិវឌ្ឍសមាមាត្រដ៏ពិតប្រាកដរវាងសាសនាការអភិវឌ្ឍនិងfitrah។ ទោះជាយ៉ាងណាក៏ដោយការសន្មតជាមូលដ្ឋាននោះគឺថា ការងារឆាក់វ៉ះជួយសម្រួលដល់បរិយាកាសគាំទ្រសម្រាប់ការឡើងឋានសួគ៌របស់មនុស្ស ឆ្ពោះទៅរកភាពល្អឥតខ្ចោះខាងដួងវិញ្ញាណ សីលធម៌ និងសាសនាជាទូទៅ ខណៈពេលដែលវាផ្តល់នូវការបញ្ចប់ដល់ចំណេះដឹងដែលមានលក្ខណៈវិចារណញ្ញាណ ពោលគឺចំណេះដឹងរបស់មនុស្សដែលមានព្រំខ្ទាត ដោយមិនចាំបាច់រួមចំណែកថ្មីណាមួយលើការបង្រៀនរបស់អ៊ីស្លាម ពោលគឺចំណេះដឹងអ៊ីស្លាមមិនអនុញ្ញាតឲ្យមនុស្សបង្កើតថ្មីណាមួយចំពោះច្បាប់អ៊ីស្លាមនោះឡើយ។

ទោះបីយ៉ាងណាក៏ដោយនៅកម្រិតមូលដ្ឋានបំផុត al-Ghazali បានចាត់ទុកសាសនាអ៊ីស្លាមសំខាន់ជាង fitrah ។ [51] យោងទៅតាម al-Ghazali, fitrahមានបញ្ញាល្អ និងបេះដូងបរិសុទ្ធ។ [52] គាត់បានប្រកែកនៅពេលដែលពាក្យ fitrah ត្រូវបានប្រើនៅក្នុងបរិបថនៃការងារឆាក់វ៉ះ ដោយកំណត់fitrahនៅដាច់ដោយឡែក។ [53] Al-Ghazali បានបដិសេធថា មនុស្សកើតមកមានព្រមដោយមាន

ហេតុផលត្រឹមត្រូវ ដែលនាំពួកគេទៅរកព្រះដែលជាអ្នកបង្កើត និងជាមួយនឹងការយល់ដឹងថា អំពើពុករលួយគឺជាអំពើអាក្រក់ និងគួរឱ្យអាម៉ាស់ ហើយត្រូវរក្សាខ្លួនឱ្យនៅឲ្យឆ្ងាយ។ [54]-Al-Ghazali បានរក្សាថាការប្តេជ្ញាចិត្តចំពោះអំពើសីលធម៌ ដោយនៅទីបំផុតបង្កប់ន័យការបដិសេធលើទស្សនវិជ្ជាសមហេតុផលអំពីសកម្មភាពរបស់មនុស្ស ដែលមិនយកចិត្តទុកដាក់ចំពោះសារពីព្រះជាម្ចាស់ ហើយវាគ្រាន់តែបណ្តាលឱ្យមានការយល់ព្រម ឬការបដិសេធដោយបំពានប៉ុណ្ណោះ។ [55] វាគឺនៅលើមូលដ្ឋាននេះដែលAl-Ghazali បានភ្ជាប់ ការងារខាក់វ៉ះ ជាមួយនឹងលក្ខណៈវិនិច្ឆ័យនៃការបែងចែកភាពល្អពីភាពអាក្រក់ ដូច្នេះដើម្បីធ្វើឱ្យមានការប្តេជ្ញាចិត្តខាងសីលធម៌នៃអំពើដែលជាលក្ខណៈធម្មជាតិនៃគំនិតការងារខាក់វ៉ះ។[56]

យោងទៅតាម Al Ghazali អារម្មណ៍មិនច្បាស់លាស់នៃទិសដៅខ្លួនឯង ចំពោះព្រះជាម្ចាស់ និងសីលធម៌ដ៏ល្អឥតខ្ចោះត្រូវបានបណ្តុះតាំងពីកំណើត។ សម្រាប់គាត់ កូនកើតមកត្រៀមខ្លួនដើម្បីអភិវឌ្ឍន៍ឆ្ពោះទៅរកសីលធម៌ដ៏ល្អឥតខ្ចោះ ប៉ុន្តែប្រៀបដូចជាផ្លែឈើ ដែលលូតលាស់មានរស់ជាតិផ្អែមនៅពេលដែលការថែទាំគ្រប់គ្រាន់ និងវាត្រូវបានយកចិត្តទុកដាក់ពីជំងឺនានា។ [57] នេះបញ្ជាក់ថាបានបន្សល់ទុកនូវជម្រើសផ្ទាល់ខ្លួនសម្រាប់មនុស្សនៅទីបំផុតដែលនឹងត្រូវបានណែនាំជឿទៅកាន់អ្នកបង្កើតពួកគេ ការស្វែងរកព្រះជាម្ចាស់ឲ្យបានពិតប្រាកដ ដោយការលើកទឹកចិត្តផ្នែកខាងក្នុងដែលបានបំផុសគំនិតឲ្យកើតឡើងមក ដូចជាចូលចិត្តរៀបការជាជាងអំពើសហាយស្មន់ រក្សាការកានឹងនរការប្រុងប្រយ័ត្នជាជាងការស្រវឹង ធ្វើសកម្មភាពដោយសប្បុរសជាជាងភាពអាត្មានិយម និងធ្វើសកម្មភាពដោយភាពស្មោះត្រង់ ជាជាងបោកបញ្ឆោត។ [58] វាជាគុណធម៌នៃfitra ដែលមនុស្សដឹងថាយុត្តិធម៌គឺល្អ អាក្រក់គឺអាក្រក់ ចំណេះដឹងជាកិត្តិយស ភាពល្ងង់ខ្លៅជាភាពអាម៉ាស់ ព្រហ្មចារីគឺជាភាពល្អឥតខ្ចោះ និងអសីលធម៌គឺជាអំពើអាក្រក់។ [59] Al-Ghazali លើកឡើងថាភាពបរិសុទ្ធនៃ fitrah ដឹកនាំមនុស្សឱ្យស្គាល់ព្រះជាម្ចាស់ និងទទួលស្គាល់សិទ្ធិរបស់ទ្រង់។[60] មនុស្សកើតមកមានការត្រៀមខ្លួន ពោលគឺមានចំណង់ចំណូលចិត្ត និង ការលើកទឹកចិត្ត ដើម្បីធ្វើតាមគន្លងនៃfitrah និងដើម្បីទទួលយកនិងធ្វើតាមជំនឿ និងគុណធម៌របស់អ៊ីស្លាម។ ព្រះបានផ្តល់ជូនដល់Fitra ដោយលក្ខណៈដើម្បីប្រឆាំងភាពមិនពិត។ ការមិនគោរពនូវគុណសម្បត្តិទាំងនោះ នឹងនាំឱ្យបរាជ័យទាំងនោះ លក្ខណៈរួមមាន សមត្ថភាពទប់ទល់ បដិសេធ ហើយជំទាស់នឹងការគិតអបិយជំនឿ ប្រកាន់យកការពិត បដិសេធអំពើអសីលធម៌ និងប្រព្រឹត្តដោយសប្បុរស និងសុចរិត។ [61] យោងទៅតាម Al-Ghazali អរិយធម៌ណាមួយដែលខិតទៅជិត fitrah ទទួលបានកាន់តែជិតទៅនឹងធម្មជាតិនៃសាសនាអ៊ីស្លាម។ [62] មិនត្រឹមតែប៉ុណ្ណោះទេប៉ុន្តែភាពទំនើបនៃអរិយធម៌លោកខាងលិចយោងទៅតាមគាត់ គឺមានភាពជិតស្និទ្ធនឹង fitrah ជាងការបង្រៀនខាងសាសនាដែលបង្ក្រាប ឬបន្ទាបខ្លួនរបស់មនុស្ស។ [63] ជាពិសេស ទំនៀមទំលាប់សម័យទំនើបរបស់បស្ចិមលោក ជាពិសេសក្នុងវិស័យនយោបាយ គឺកាន់តែជិតទៅនឹងសាសនាអ៊ីស្លាម។[64] Al-Ghazali បានលើកឡើងអំពីការយល់ដឹងអំពី fitrah វាហួសពីនិយមន័យក្នុងសាសនាធម្មតា ដើម្បីពិចារណាតម្លៃជាសកលបន្ថែមទៀតថា វាជាសូចនាករត្រឹមត្រូវនៃ fitrah។ សាសនាពិតនោះគឺមនុស្សជាតិនៅលើផ្លូវដ៏ត្រឹមត្រូវ (al-insāniyyah al-sahihah)

ដែលរាប់បញ្ចូលទាំងការប្តេជ្ញាចិត្តរបស់បញ្ញាអំពីការពិត តាមរយៈវិទ្យាសាស្ត្រប្រឆាំងតទល់នឹងទេវកថា និងអបិយជំនឿ។[65] ការពិភាក្សារបស់ Al-Ghazali អំពី fitrah បង្ហាញថាការរួមចំណែករបស់គាត់ស្ថិតនៅក្នុងទំនាក់ទំនងសមាមាត្ររវាងការរីកចម្រើនខាងសាសនាដែលមានសុខភាពល្អ និងវិបុលភាពសង្គម និងការព្យាយាមរបស់គាត់ក្នុងការបញ្ចូលជាតុផ្សំនៃ fitrah យ៉ាងខ្លាំងនៅក្នុងប្រព័ន្ធគំនិត លើការឆាក់វ៉ះ។

**ភាពជាសកលនៃការងារឆាក់វ៉ះ**

យោងតាម Al-Ghazali សាររបស់ព្យាការីមូហាំម៉ាត់ មានការរីកចម្រើនលើគំនិតជាសកលដោយផ្អែកលើជំនឿនោះ ដោយឆ្លងកាត់ពេលវេលានៃសាសនាមានតែមួយ ហើយជាព្យាការីគឺជាបងប្អូននឹងគ្នា ដែលណែនាំអ្នកបង្កើតមនុស្សលោក ហើយណែនាំមនុស្សឱ្យស្គាល់ទ្រង់។ [66] Al-Ghazali បានចូលទៅជិតភាពសកលនៃការងារឆាក់វ៉ះ មិនត្រឹមតែនៅក្នុងលក្ខខណ្ឌនៃតំបន់ភូមិសាស្ត្រដ៏ធំដែលវាដំណើរការប៉ុណ្ណោះនោះទេ ប៉ុន្តែ ជាពិសេសវាមាននៅក្នុងពន្លឺនៃការណែនាំ និងការបង្កើតនៃគម្ពីរអាល់គួរអាន និង ស៊ុនណះ ដែលនិយាយទៅកាន់មនុស្សជាតិទាំងអស់នៅគ្រប់ទីកន្លែង ដោយមិនគិតពីពេលវេលា ឬវិសាលភាព។ [67]

Al-Ghazali ក៏បានគូសបញ្ជាក់អំពីសារៈសំខាន់នៃកំណែទម្រង់ទូលំទូលាយ និងកិច្ចខិតខំប្រឹងប្រែងមនុស្សធម៌។ទស្សនៈបែបនេះស្វែងរកការទម្លុះរបាំងផ្លូវអារម្មណ៍ និងវប្បធម៌ជុំវិញសកលលោកនេះ និងបង្កើតស្ពានតភ្ជាប់វប្បធម៌ សហគមន៍ និងសង្គម សម្រាប់ Al-Ghazali ការផ្សព្វផ្សាយសេចក្តីល្អការការពារនូវការគោរពសក្ការៈ និងការតស៊ូប្រឆាំងនឹងអំពើអាក្រក់កាតព្វកិច្ចជាសកល។ នេះមានន័យថាការរីកសាយភាយ ក៏ដូចជាការការពារ ភាពល្អ ឬការតស៊ូប្រឆាំងនឹងអំពើអាក្រក់ មិនមែនជាកាតព្វកិច្ចក្នុងស្រុកទាំងអស់លើជនមូស្លីមដែលត្រូវទទួលខុសត្រូវនោះទេ ប៉ុន្តែតំណាងឱ្យកាតព្វកិច្ចជាសកលពោលសម្រាប់មនុស្សជាតិទូទៅ។[68] ភាពជាសកលទាក់ទងនឹងការងារឆាក់វ៉ះ ទាមទារការស្វែងយល់ពីពិភពលោកនៅជុំវិញយើង រួមទាំងសហគមន៍នៃសាសនាចម្រុះគ្នា។ ទូអាត អ្នកផ្សព្វផ្សាយអ៊ីស្លាមដែលរវល់ជាមួយការកែទម្រង់បញ្ញាញាណ និងអារម្មណ៍ចាំបាច់ត្រូវធ្វើការពិនិត្យ និងស្គាល់ខ្លួនឯងជាមុន ជាមួយនឹងគំនិតរបស់មនុស្សជាសកលនិងត្រូវស្វែងយល់ពីស្ថានភាពរបស់មនុស្សក្នុងគោលបំណងកែលម្អពួកគេ។ ដូច្នេះ អ្នកប្រាជ្ញមូស្លីមគួរតែពិនិត្យមើលយុទ្ធសាស្ត្រនៃការងារឆាក់វ៉ះក្នុងវិសាលភាពជា សកលថាតើនៅក្នុងលក្ខខណ្ឌនៃការបង្ហាញនៃសាសនាអ៊ីស្លាមទៅពិភពខាងក្រៅ ឬក្នុងការឆ្លើយតបរបស់ពួកគេចំពោះការសង្ស័យ។ [69] ដូច្នេះ មូស្លីមត្រូវការទំនាក់ទំនងវិជ្ជមានជាមួយអ្នកដទៃ។ ទោះបីយ៉ាងណាក៏ដោយនៅកម្រិតធំម៉ាក្រូជាសកលនៃការឆាក់វ៉ះដែលទាក់ទងនឹងការកែលម្អលក្ខខណ្ឌសីលធម៌ និងសេដ្ឋកិច្ចសម្រាប់សង្គមមូស្លីម ដូចដែលអ្នកដើរតាមព្យាការី ពោលសាហាហ្បាត់ ដោយពឹងផ្អែកលើចរិតលក្ខណៈដ៏ថ្លៃថ្នូរបស់ពួកគេ និងភាសាបញ្ចុះបញ្ចូលដើម្បីទំនាក់ទំនងផ្សព្វផ្សាយអ៊ីស្លាមជាមួយប្រជាជាតិផ្សេងៗ។[70]

ភាពជាសកលនៃសាសនាអ៊ីស្លាម ពោលការផ្សព្វផ្សាយអ៊ីស្លាមឲ្យបានទូទូលាយជាសកលសម្រាប់

 Al-Ghazali វាជាការសោកស្តាយ ក្នុងការបញ្ចេញមតិមួយ ដែលប្រជាជនម៉ូស្លីមនិយាយឡើងមក ពេលខ្លះវាហួសហេតុ និងដោយមិនទាន់បានគិតគូរអំពីផលប៉ះពាល់របស់វានោះឡើយនោះទេ។ ប្រជាជនមូស្លីមនាសម័យទំនើប មិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្ត ការងារឌាក់វ៉ះឲ្យមានភាពជាសកលនេះមានប្រសិទ្ធភាពនៅឡើយនោះទេ ដោយសារតែការយល់ដឹងមានទៅដោយភាពច្របូកច្របល់របស់ពួកគេ វប្បធម៌និងប្រព័ន្ធនយោបាយមិនល្អពេលនាសម័យថ្មី ស្ថានភាពបច្ចុប្បន្ននៃសង្គមមូស្លីម ថែមទាំងបង្កើនការសង្ស័យអំពីតម្លៃនៃសាសនាអ៊ីស្លាម និងទំហំដែលមនុស្សនឹងទទួលបានអត្ថប្រយោជន៍ពីវា។[71]

ការវាយតម្លៃរបស់ Al-Ghazali អំពីស្ថានភាពបច្ចុប្បន្នរបស់មូស្លីមបាននាំឱ្យគាត់សួរហេតុអ្វីបានជាពួកគេបានបម្រើការងារឌាក់វ៉ះឲ្យមានភាពជាសាកលយ៉ាងលំបាកដូច្នេះ ណែនាំ ការយល់ដឹងយ៉ាងទន់ភ្លន់អំពីសាសនាអ៊ីស្លាមនៅលើឆាកក្នុងស្រុក និងឆាកអន្តរជាតិ។ ហើយគាត់លើកហេតុផលថានេះមកពីផ្នែកខ្លះពីអ្នកកាន់សាសនាអ៊ីស្លាមសម័យដើម ដោយការការចាប់អារម្មណ៍នឹងទស្សនវិជ្ជាក្រិកនៅពេលដែលការពិតពួកគេគួរតែបានសង្កត់ធ្ងន់ និងបង្ហាញពីចំណេះដឹងនៃសាសនាអ៊ីស្លាមនិងចំណេះដឹងនៃគម្ពីរអាល់គួរអាននៅក្នុងមុខវិជ្ជាសិក្សាចម្រុះលើសីលធម៌ និងអាជីវកម្ម។[72] ការរក្សានូវគោលការណ៍ Al-Ghazali ចំពោះអ្នកគ្រប់គ្រងដែលជំនួសឱ្យការប្រកាន់ខ្ជាប់នូវកម្មវិធីនៃការបង្រៀន និងការណែនាំ បានក្លាយជាការស្រមើស្រមៃសម្រាប់ការគ្រប់គ្រង និងអំណាច។

## ការងារឌាក់វ៉ះ សង្គម និងវប្បធម៌

Al-Ghazali បានមើលផលប៉ះពាល់នៃលក្ខខណ្ឌសេដ្ឋកិច្ចជាមួយគ្នា ជាមួយនឹងកំណែទម្រង់សង្គមដែលជាធាតុផ្សំជាមូលដ្ឋាននៅក្នុងការអនុវត្តការងារឌាក់វ៉ះ ។ សម្រាប់ Al-Ghazali សង្គម និងវប្បធម៌មានឥទ្ធិពលលើបរិយាសផ្សព្វផ្សាយលើការងារសាសនា ក៏ដូចជាបុគ្គល និងសីលធម៌ អាកប្បកិរិយា វាគឺមិនអាចប្រកែកបាន។ [73] ដូច្នេះហើយ ឥទ្ធិពលដ៏ច្រើនលើបរិយាកាសសីលធម៌ និងសង្គមគឺសម្រាប់គាត់ជាតម្រូវការជាមុនសម្រាប់ការចែកចាយសារសាសនាប្រកបដោយជោគជ័យ។ សម្រាប់គាត់ ឧក្រិដ្ឋកម្មខាងសីលធម៌ និងអនុភាពច្រើនតែកើត និងរីកចម្រើននៅក្នុងសង្គមដែលរងផលប៉ះពាល់ដោយតម្រូវការខាងសេដ្ឋកិច្ច។[74]នេះគាត់ប្រកែកគឺដោយសារតែបរិយាកាសមិនល្អ ការបំភ្លៃលក្ខណៈរបស់ fitrah ហើយឆ្លងវាដូចជាជំងឺ។[75] មនុស្សកើតមកក្នុងស្ថានភាពនៃជំនឿ ហើយត្រូវបានរៀបចំដើម្បីភ្ជាប់ជាមួយសាសនា និងការបង្រៀនរបស់វាភ្លាមៗនៅពេលដែលពួកគេទទួលបានការយល់ដឹងហើយឥទ្ធិពលនៃការអនុវត្តអវិជ្ជមានត្រូវបានដកចេញ។[76]

Al-Ghazali ក៏មើលឃើញទំនាក់ទំនងរវាងការងារឌាក់វ៉ះ និងភាពក្រីក្រផងដែរ។ ដូច្នេះលោកបានលើកឡើងថា តម្រូវការមូលដ្ឋានរបស់មនុស្សគួរតែធានាបានជាមុនសិនពេលនោះគេរំពឹងថានឹងមានជំនឿ។ [77]ភាគច្រើននៃការរិះគន់របស់គាត់អំពីអ្នកទូអាត ពាក់ព័ន្ធនឹងរបៀបដែល ការងារឌាក់វ៉ះ មានប្រសិទ្ធភាពក្នុងលក្ខខណ្ឌនៃភាពក្រីក្រ។ Al-Ghazali បានពិពណ៌នាអំពីរបៀបដែល ទោះបីជាមាន

ការប៉ុនប៉ងជាច្រើនដងក៏ដោយ ក៏ការងារឌាក់វ៉ះ មិនទាន់រកឃើញបរិយាកាសត្រឹមត្រូវ ក្នុងការបញ្ចូលជំនឿ សីលធម៌ ឬអំពើល្អនៅក្នុងសង្គមដែលមានកម្រិតក្រីក្រនៅឡើយ។[78]

ស្ថានភាពនេះបើយោងតាម Al-Ghazali ទាមទារអ្នកអាតផ្តល់ដំណោះស្រាយចំពោះបញ្ហាសីលធម៌ និងសេដ្ឋកិច្ច។ [79] មុននឹងដឹកនាំមនុស្សទៅរកអ្នកបង្កើត ពេលគឺអល់ឡោះ កំណែទម្រង់សេដ្ឋកិច្ចទ្រង់ទ្រាយធំគឺត្រូវបានទាមទារ សម្រាប់ការងារទាំងនេះគឺជៀសមិនរួច ប្រសិនបើឧក្រិដ្ឋកម្ម និងសីលធម៌កើតមាន ត្រូវប្រយុទ្ធតតាំងក្នុងនាមអ៊ីស្លាម។Al-Ghazali បានចាត់ទុកការកែលម្អលក្ខខណ្ឌសេដ្ឋកិច្ចថាមានសារៈសំខាន់ចំពោះ ការងារឌាក់វ៉ះ និងជឿជាក់លើប្រភេទនៃទំនាក់ទំនងសមាមាត្ររបស់វា ដើម្បីឱ្យមានរវាងការអភិវឌ្ឍសេដ្ឋកិច្ចនៃសង្គមមូស្លីម និងការងារផ្សព្វផ្សាយឌាក់វ៉ះអ៊ីស្លាម។[80] ហេតុដូច្នេះហើយ Al-Ghazali បានអប់រំអ្នកទូអាត ដើម្បីរួមបញ្ចូលបរិបទសេដ្ឋកិច្ចសង្គមទៅក្នុងការយល់ដឹង និងការអនុវត្តរបស់ការងារឌាក់វ៉ះ ហើយក្នុងពេលដំណាលគ្នាអំពាវនាវដល់ស្ថាប័ននានាឱ្យដំណើរការកម្មវិធីកំណែទម្រង់ ជាមធ្យោបាយសំខាន់សម្រាប់ការអប់រំសាសនា និងតម្រូវការជាមុនដើម្បីធ្វើសកម្មភាពការងារឌាក់វ៉ះ និងកំណែទម្រង់អ៊ីស្លាមជាទូទៅ។

យោងទៅតាម Al-Ghazali ប្រពៃណីដ៏គួរឱ្យសោកស្តាយបន្តគ្រប់គ្រងជីវិតមូស្លីមក្នុងនាមសាសនា។[81] ម្យ៉ាងទៀត ការបង្រៀនរបស់សាសនាអ៊ីស្លាមបានដកខ្លួនចេញពីជីវិតនយោបាយ សេដ្ឋកិច្ច និងសង្គម ដោយការគោរពប្រណិប័តន៍សាសនាពលតែមួយផ្នែកដាច់ដោយឡែកបានបន្សល់ទុកដោយភាពគ្មានដួងវិញ្ញាណ ហើយប្រែទៅជាពិធីដែលគ្មានន័យ។ Al-Ghazali បានបដិសេធថា ការងារឌាក់វ៉ះពេលនាសម័យកាលនោះកំពុងបង្គ្រោះថ្នាក់ដល់សាររបស់ខ្លួន និងបង្កើតជាបញ្ហាដោយការបញ្ជូនគោលការណ៍អ៊ីស្លាម ដែលត្រូវបានបំភាន់ខុសជាមួយនឹងជាតុផ្សំពីមជ្ឈិមសម័យ និងសម័យទំនើប។[82] Al-Ghazali ដាស់តឿនប្រជាជនមូស្លីមឱ្យបោះបង់ទំនៀមទម្លាប់ដែលមានឫសគល់នៅក្នុងសម័យកាលដំបូងនៃភាពល្ងង់ខ្លៅរបស់អារ៉ាប់ (al-jāhiliyyah al-'ūlā)។ឧទាហរណ៍ទាំងនេះ រួមមានការគាបសង្កត់លើស្ត្រី ក្នុងទម្រង់ជារឿងផ្សេងទៀត ការមិនយកចិត្តទុកដាក់លើការអប់រំរបស់ពួកគេ ការរារាំងមិនឲ្យពួកគេចូលវិហារអ៊ីស្លាម ការបំបាក់ទឹកចិត្តពួកគេពីការប្រព្រឹត្តល្អ លើការហាមឃាត់អំពើអាក្រក់ និងលើការបង្កើនការដាក់ទណ្ឌកម្មរបស់ពួកគេចំពោះអំពើបាបដែលបានប្រព្រឹត្ត។ សម្រាប់គាត់ កង្វះការយល់ដឹងត្រឹមត្រូវអំពីសាសនាអ៊ីស្លាមបានដឹកនាំទំនៀមទម្លាប់ពនេចរមួយចំនួនដើម្បីជ្រៀតចូលក្នុងប្រព័ន្ធច្បាប់របស់មូស្លីម។[83]

### ការងារឌាក់វ៉ះ និងសេរីភាព

Al-Ghazali បានចាត់ទុកសេរីភាពនៃបញ្ញា និងមនសិការជា មូលដ្ឋានគ្រឹះនៃសាសនា[84] និង

បរិយាកាសសំខាន់ៗធ្វើឲ្យសាសនាលេចឡើង រីកចម្រើន និងរីកសាយ។[85] យោងតាម Al-Ghazali សេរីភាពបញ្ញាបង្កើតជាមូលដ្ឋានគ្រឹះនៃការងារខាក់វ៉ះ, និងជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់មួយសម្រាប់ផ្ទៃាន់ និងការដាក់ទណ្ឌកម្មពីអល់ឡោះជាម្ចាស់។ សេរីភាពនៃការបញ្ចេញមតិពាក់ព័ន្ធនឹងការរិះគន់ក្នុងន័យស្ថាបនា ការប្រកួតប្រជែងមុខតំណែងបញ្ញា តាមរយៈការជជែកវែកញែកប្រកបដោយការយល់ដឹងមិនមែនជាការប្រមាថ ឬការគំរាមកំហែងនោះឡើយ។ នេះបើយោងតាម al-Ghazali សារនៃសាសនាអ៊ីស្លាមបានយល់ព្រមនូវសេរីភាពខាងសតិបញ្ញាដើម្បីចូលរួមក្នុងកិច្ចសន្ទនាដែលប្រសើរឡើងដោយបង្ហាញពីការមិនបង្ខិតបង្ខំប្រឆាំងនឹងជំនឿរបស់ប្រជាជន។ [86] ឧទាហរណ៍ សាសនាអ៊ីស្លាម ស្វែងរកការបង្កើតបរិយាកាសនៃការអត់ឱន ដោយមិនមានការស្អប់ខ្ពើម និងការគាបសង្កត់ [87]ក្នុងគោលបំណងបញ្ចុះបញ្ចូលដោយភាពទន់ភ្លន់ក្នុងបរិយាកាសសន្តិភាព។ ដូច្នេះ ជំនឿត្រូវបានគេមើលឃើញថាជាអ្វីដែលចាក់ឫសនៅក្នុងចិត្ត ក៏ដូចជាលទ្ធផលនៃសេរីភាពបញ្ញា ដោយគ្មាន ងាកទៅរកការប្រើប្រាស់អព្ភូតហេតុ (ការបង្ក្រាបសមត្ថភាពបញ្ញា, ឬសម្ពាធណាមួយដែលដាក់លើបញ្ញា ឬធន្ទៈ)របស់មនុស្សនោះឡើយ។

Al-Ghazali រាប់បញ្ចូលប្រហែល១០០វាក្យខណ្ឌពីគម្ពីរអាល់គួរអាន ក្នុងគោលបំណងដើម្បីបញ្ជាក់ថាជំនឿគឺជាលទ្ធផលចុងក្រោយនៃការគិតដោយសេរី ឆន្ទៈ និងសតិសម្បជញ្ញៈ ដែលជាលទ្ធផលចុងក្រោយនៃបញ្ញា និងការបញ្ចុះបញ្ចូលដែលទាមទារឱ្យដកចេញនូវការបង្ខិតបង្ខំពីការងារខាក់វ៉ះ។ Al-Ghazali បន្ថែមនូវប្រភេទផ្សេងៗនៃសេរីភាព ដូចជា សេរីភាពនៃការបញ្ចេញមតិ សេរីភាពខាងសាសនា សេរីភាពក្នុងការបំពេញចិត្ត តម្រូវការជាមូលដ្ឋាន និងសេរីភាពរួចផុតពីការបៀតបៀន។[88]

សម្រាប់ al-Ghazali ការបញ្ចុះបញ្ចូល និងការពិភាក្សា [89] ភាពពិតប្រាកដតែមួយគត់កំណត់ថានៅពេលនិយាយអំពីសាសនា ទម្រង់នៃការបង្ខិតបង្ខំណាមួយនឹងរុញច្រានមនុស្សចេញ ហើយជំនួសឱ្យការបណ្ដុះជំនឿនឹងជម្រុញឱ្យមានគំនិតខុសឆ្គងចំពោះសាសនានោះ។ មនុស្សដែលត្រូវបានបង្ខំឱ្យប្រកាន់ខ្ជាប់សាសនាមិនត្រូវបានចាត់ទុកថាជាសាសនាទេ សូម្បីតែនៅពេលដែលស្ថិតនៅក្រោមការប្រតិបត្តិតាមសាសនាដ៏តឹងរ៉ឹងក៏ដោយ ពោលអ៊ីស្លាមតម្រូវឲ្យអ្នកមានជំនឿត្រូវជឿដោយស្មោះចេញពីចិត្តដោយគ្មានការបង្ខិតបង្ខំឡើយ។ [90] ការបង្ខិតបង្ខំក្នុងសាសនាអ៊ីស្លាមត្រូវបានចាត់ទុកថាជាការបំពានបញ្ញាមិនមានការគាំទ្រនៅក្នុងជីវិតរបស់ព្យាការីមហាំម៉ាត ឬខលីហ្វះអ្នកដឹកនាំបន្តពីលោកនោះឡើយ។ ដូច្នេះ Al-Ghazali ដាស់តឿនអ្នកទូអាតឱ្យខ្វល់ខ្វាយជាមួយណែនាំមនុស្ស និងមិនត្រូវប្រមូលផលប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ ដូចជាចោរដែលធ្វើការលួចនោះឡើយ។ [91] យោងទៅតាម Al-Ghazali ព្យាការីគឺជាបងប្អូនដែលមានដួងចិត្តភាពស្និទ្ធស្នាលបង្រួបបង្រួមមនុស្សឱ្យភ្ជាក់នៅក្នុងអារម្មណ៍របស់ពួកគេ មានកិច្ចសហប្រតិបត្តិការ និងការអាណិតអាសូរ ជាជាងទុកឱ្យពួកគេបែកបាក់និងខ្វាត់ខ្វាយគ្នា។ ក្នុងចំណោមគោលការណ៍ទាំង១០ Al-Ghazali បានប្រកាសគោលការណ៍៤ត្រូវបានលះបង់ទាំងស្រុង និងកិច្ចសហប្រតិបត្តិការខាងសាសនា ខណៈពេលដែលគោលការណ៍៨និយាយអំពីភាពខុសគ្នាខាងសាសនា និងរបៀបដែលពួកគេគួរការពារកុំឲ្យមានសត្រូវ ឬភាពមិនអនុគ្រោះរវាងគ្នា។ [92] យោងទៅតាម Al-Ghazali មនុស្សជាតិគឺជាគ្រួសារតែមួយដែលកើតចេញពី

ប្រភពតែមួយ ដោយមិនមានការពេញចិត្តអ្វីពីគ្នាទៅវិញទៅមកទាក់ទងនឹងការបង្កើត ឬជីវិតរបស់មនុស្សនោះឡើយ។[93]

សរុបមក ការងារឌាក់វ៉ះរបស់ Al-Ghazali នៅឆ្ងាយពីគ្រប់ទម្រង់ទាំងអស់ការរំលោភបំពាន អំពើហឹង្សា និងការកេងប្រវ័ញ្ច។ ទាំងអ្នកជាអ៊ីផ្សព្វផ្សាយអ៊ីស្លាម (da^ciyah) និង បានអំពាវនាវដល់ (ma^cdū) ទទួលបានសេរីភាពស្មើគ្នា។ ទស្សនវិស័យលើសេរីភាពក្នុងការងាររបស់ Al-Ghazali ហួសអំពីនយោបាយសង្គម បទពិសោធន៍របស់គាត់ ហើយភាគច្រើនអាស្រ័យលើការបញ្ចុះបញ្ចូល និងជម្រើស។ ទស្សនវិស័យនេះត្រូវបានបង្ហាញភាពដើមនៃមនុស្សនិយម ប្រាកដនិយម និងការសិក្សាសាសនាពីអ៊ីស្លាម។ នៅក្នុងស្នាដៃរបស់ Al-Ghazali ការងារឌាក់វ៉ះត្រូវបានបង្ហាញថាវាជាដំណើរការផ្លាស់ប្តូរដោយបើកចំហ និងអត់ធ្មត់ ដោយចំណាយច្រើនសន្ទឹកសន្ធាប់ការយកចិត្តទុកដាក់លើអារម្មណ៍ និងបញ្ហារបស់មនុស្ស។ វាសមហេតុផលលើតម្លៃនៃអ្វីដែលគាត់ហៅថាអ៊ីស្លាមជាសាសនាធម្មជាតិ (Al-din al-tabi^ci)ដោយមិនប្រឈមមុខនឹងតម្លៃសកលនោះឡើយ។

## ជំពូកទី៣
## ទូអាត(អ្នកផ្សព្វផ្សាយអ៊ីស្លាម)

ទស្សនៈរបស់ Al-Ghazali លើទំនួលខុសត្រូវរបស់ទូអាតខាងដួងវិញ្ញាណរបស់ពួកគេលើសីលធម៌ និងគុណវុឌ្ឍិនៃការអប់រំដែលត្រូវបានពិនិត្យ ក៏ដូចជាបញ្ហា និងបញ្ហាប្រឈមដែលទាក់ទិននឹងការងារឌាក់វ៉ះរបស់ពួកគេ។ វាត្រូវបានពិនិត្យផងដែរនោះគឺការរិះគន់របស់ al-Ghazali លើទស្សនៈរបស់ពួកគេ។ នេះវាជួយយើងយល់កាន់តែច្បាស់អំពីធម្មជាតិ និងឥទ្ធិពលលើការងារនៃការងារឌាក់វ៉ះ និងសារៈសំខាន់នៃគំរូរបស់ Al-Ghazali នៃការងារឌាក់វ៉ះ ដោយបានដាក់នៅលើចរិតលក្ខណៈខាងដួងវិញ្ញាណ និងសីលធម៌។ វាក៏អនុញ្ញាតឱ្យយើងកំណត់មូលហេតុដែលនាំឱ្យគាត់ចាត់ទុកគុណវុឌ្ឍិទាំងនេះថាជាកាតព្វកិច្ចសម្រាប់ការអនុវត្តការងារឌាក់វ៉ះ និងដោយគ្មានអ្វីដែលមិនច្បាស់ថា អ្នកទូអាតនឹងមិនទទួលបានជោគជ័យនោះឡើយ។ ការពិភាក្សាអំពីគុណវុឌ្ឍិទាំងនេះក៏បង្ហាញពីជំហររបស់ Al-Ghazali ទាក់ទងនឹងការយល់ឃើញបច្ចុប្បន្ននៃស្តង់ដារអប់រំរបស់ទូអាត និងតម្រូវការជាមុនផ្សេងទៀតដែលទាមទារសម្រាប់ការអនុវត្តការងារឌាក់វ៉ះ។

### ទំនួលខុសត្រូវរបស់ទូអាត

យោងតាម Al-Ghazali សាសនាអ៊ីស្លាមគឺស្ថិតនៅក្នុងខ្លឹមសារសំខាន់ដែលផ្តោតលើការងារឌាក់វ៉ះ ។ វាជាស់តឿនជនមូស្លីមឲ្យរៀន និងបង្រៀន ដើម្បីក្លាយជាអ្នកបញ្ចុះបញ្ចូល និងផ្សព្វផ្សាយដល់អ្នកដទៃ។ [94] សាសនាអ៊ីស្លាមបានផ្តល់ចំណេះដឹងលម្អិតអំពីអ្នកបង្កើត ផ្តល់ភាពប្រាកដប្រជាសម្រាប់អ្នកដែលសង្ស័យ និងបង្ហាញការគោរពចំពោះមនុស្សទាំងអស់។ វាក៏ស្វែងរកការផ្លាស់ប្តូរខ្លួនឯង និងសង្គមរបស់មនុស្ស ប្រឈមមុខនឹងអំពើពុករលួយ និងភាពអយុត្តិធម៌ បោះចោលទំនៀមទម្លាប់ និងច្បាប់អវិជ្ជមាន ហើយគាំទ្រប្រពៃណី និងការអនុវត្តប្រកបដោយគុណធម៌ជំនួសវិញ។ នេះគឺជាសារនៃសាសនា។ គោលដៅរបស់ការងារឌាក់វ៉ះ បន្ទាប់មកគឺការអភិវឌ្ឍន៍មនុស្សប្រកបដោយប្រសិទ្ធភាព

និងការវិវត្តន៍របស់ប្រជាជនម៉ូស្លីមតាមរយៈជំនឿ ការលះបង់ការសឡាតថ្វាយបង្គំ ភាពស្មោះត្រង់ និងសេចក្តីស្រឡាញ់ចំពោះព្រះអល់ឡោះជាម្ចាស់ និងរ៉ស៊ូលរបស់ទ្រង់ និងឧត្តមភាពនៅក្នុងជីវិតលោកិយ។[95]

យោងទៅតាមគម្ពីរអាល់គួរអាន ការងារទូអាតដែលត្រូវធ្វើមានដូចជា សូត្រវាក្យខណ្ឌគម្ពីររបស់ខ្លួន ទទួលបានការបន្សុទ្ធខាងដួងចិត្ត និងអប់រំមនុស្សលោក។ ភារកិច្ចទាំងនេះដែលត្រូវបានលើកឡើងដោយព្យាការីតំណាងឱ្យសមាសធាតុសំខាន់ៗនៃការងារដាក់វ៉ះ ។ ទោះបីយ៉ាងណាក៏ដោយ ភ្លាមៗនោះ វិស័យការងារចម្បងរបស់ទូកាត គឺខ្លួនឯង និងក្រុមរបស់ពួកគេ។ តាមរយៈការធ្វើជាគំរូដ៏ល្អ ពួកគេបានដើរតួជាគំរូដោយបំផុសគំនិតអ្នកដទៃឱ្យមានជំនឿលើព្រះអល់ឡោះជាម្ចាស់ ក៏ដូចជាការអប់រំទាំងអ្នកកាន់សាសនាអ៊ីស្លាម និងមិនមែនមូស្លីមទាក់ទងនឹងសាសនា និងសារពីអល់ឡោះជាម្ចាស់ ការសាកល្បងទំនាក់ទំនងរបស់ពួកគេជាមួយនឹងគម្ពីរអាល់គួរអាន។ ទូអាតត្រូវបង្ហាញការពិត កុំលាក់បាំង និងបង្ហាញការពិតអំពីសារលើការមានជំនឿ ដោយគ្មានឥទ្ធិពលពីជីវិតលោកីយនោះឡើយ។ នៅកម្រិតសង្គម និងធ្វើតាមការបង្ហាញរបស់គម្ពីរអាល់គួរអាន ដាអ៊ីត្រូវធ្វើការងារដាក់វ៉ះដោយមានបំណងប្រាថ្នាត្រឹមត្រូវ និងមិនមានការលោភលន់ ត្រូវមានទំនាក់ទំនងលើការងារអ៊ីស្លាមដោយមិនគិតពីការចំណេញពេលផ្ទាល់ខ្លួននោះឡើយ។

ទំនួលខុសត្រូវរបស់ដាអ៊ីម្នាក់ ក៏ពាក់ព័ន្ធនឹងការងារផ្ទាល់ខ្លួនរបស់គាត់ ការអភិវឌ្ឍសង្គម និងសមត្ថភាពក្នុងការដោះស្រាយសាសនា និងពិភពលោករួមគ្នាផងដែរ។ ទំនួលខុសត្រូវទាំងនេះមិនសាមញ្ញនោះទេ វាឆ្លុះបញ្ចាំងពីកាតព្វកិច្ចប្រពៃណីរបស់គ្រូបង្រៀនសាសនាអ៊ីស្លាម អ្នកអធិប្បាយ ឬអ្នកប្រាជ្ញអ៊ីស្លាម ប៉ុន្តែ ជាជាងនឹងទស្សនវិស័យលើការងារដាក់វ៉ះថ្មី ដោយទូអាតរួមចំណែកដល់កំណែទម្រង់អ៊ីស្លាម និងដើរតួជាភ្នាក់ងារដ៏វិជ្ជមាននៃការផ្លាស់ប្តូរ។ នេះបង្ហាញពីរបៀបដែលA-Ghazali ការយល់ដឹងទូលំទូលាយអំពីការងារដាក់វ៉ះមានទិទ្ធពលដល់ការយល់ដឹងរបស់គាត់អំពីទំនួលខុសត្រូវរបស់ទូអាត។ ទំនួលខុសត្រូវដ៏ធំទូលាយបែបនេះ ទោះបីជាយ៉ាងណាក៏ដោយ ធ្វើឱ្យកិច្ចការរបស់អ្នកដាអ៊ី មានច្រើនមុខ ស្មុគស្មាញ និងពិបាក និងបង្ហាញការវាយតម្លៃអំពីវឌ្ឍនភាព និងការរួមចំណែករបស់ពួកគេដែលមានការលំបាកបន្តិចបន្តួច។ ទំនួលខុសត្រូវទាំងនេះក៏បង្ហាញផងដែរ នូវការផ្លាស់ប្តូរតិចតួចទៅជារចនាបថចម្រុះ និងថាមវន្តនៃទំនួលខុសត្រូវលើការងារដាក់វ៉ះ ។ នេះពង្រីកការយកចិត្តទុកដាក់របស់ ទូអាតធ្វើឱ្យការងារដាក់វ៉ះ ក្លាយជាមធ្យោបាយដ៏សំខាន់ក្នុងកំណែទម្រង់អ៊ីស្លាមទូទៅ និងថែមទាំងបញ្ជាក់ពីភាពខុសគ្នារវាងកំណែទម្រង់អ៊ីស្លាម និងការដាក់វ៉ះផងដែរ។

Al-Ghazali ក៏បានដាក់ចេញនូវទំនួលខុសត្រូវើការងារដាក់វ៉ះ សម្រាប់បុគ្គល និងក្រុមដែលចូលរួមក្នុងកំណែទម្រង់អ៊ីស្លាមប្រកបដោយសន្តិភាព និងវិជ្ជមានការកែលម្អជីវិតក្នុងស្រុក និងពិភពលោក។ ទាំងនេះពាក់ព័ន្ធគ្រូអធិប្បាយ បញ្ញវន្តអ៊ីស្លាម និងសមាជិកនៃចលនាកំណែទម្រង់អ៊ីស្លាម។ ការ រិះគន់របស់គាត់ភាគច្រើនគឺសំដៅទៅលើទូអាត ដោយចាត់ទុកថាជាអ្នកអធិប្បាយ និងជាអ្នកប្រាជ្ញសាសនាអ៊ីស្លាម។ Al-Ghazaliរក្សាប្រភេទអ្នកទាំងពីរនៅក្នុងចិត្តប៉ុន្តែមិនបានបែងចែកការទទួលខុសត្រូវរបស់គ្នានោះទេ។

## គុណវុឌ្ឍិខាងដួងចិត្ត និងសីលធម៌របស់ទូអាត

Al-Ghazali ជឿថាអ្នកទូអាតត្រូវការច្រើនបំផុតលើការអប់រំខ្លួនឯង [96] និងត្រូវការដើម្បីអនុវត្តន៍នៅក្នុងខ្លួនពួកគេនូវកម្រិតនៃសីលធម៌ និងសីលធម៌ធំជាងមនុស្សទូទៅ។ ឧទាហរណ៍ អ្នកទូអាត គួរតែទទួលបានកម្រិតខ្ពស់នៃជំនឿ និងភាពប្រាកដប្រជា ភាពរីករាយ និងគុណធម៌។ នេះតម្រូវឱ្យធ្វើដោយយកចិត្តទុកដាក់ចំពោះស្ថានភាពសីលធម៌ និងផ្លូវចិត្តរបស់ពួកគេ ការធ្វើវិនិច្ឆ័យដោយខ្លួនឯងដើម្បីកែប្រែការខ្វះខាត ឬព្យាលបាលជំងឺខាងដួងចិត្ត។ ពួកគេក៏មិនត្រូវសន្មត់ថាការបង្រៀន ការណែនាំរបស់ពួកគេត្រូវបានអនុវត្តន៍ចំពោះអ្នកដែលត្រូវបានណែនាំរបស់ពួកគេ និងមិនមែនសម្រាប់តែខ្លួនឯងពួកគេនោះដែរ។

សម្រាប់ Al-Ghazali ការលោភលន់ និងសម្ភារៈនិយមគឺមិនស៊ីសង្វាក់គ្នាជាមួយការងារឌាក់វ៉ះនោះឡើយ។ អ្នកទូអាតធ្វើការងាររបស់ខ្លួនហើយ មិនគួរស្វែងរករង្វាន់ផលប្រយោជន៍ជាសម្ភារៈត្រឡប់ទៅលើការងាររបស់ពួកគេនោះឡើយ។ [97] សម្រាប់ Al-Ghazali ការលះបង់ដែលមិនគិតតែពីប្រយោជន៍ផ្ទាល់ខ្លួននេះដែលមាននៅក្នុងការងាររបស់ទូអាត មិនមែនជារឿងចៃដន្យនោះទេ ព្រោះមូលដ្ឋានគ្រឹះនៃសីលធម៌របស់ជាអ៊ី ស្ថិតនៅក្នុងទំនាក់ទំនងខាងដួងចិត្តរបស់គាត់ជាមួយនឹងអល់ឡោះជាម្ចាស់។ នៅក្នុងការទទួលយកការងារដ៏មានតម្លៃនេះ ត្រូវស្វែងរកការពេញចិត្តពីព្រះ អល់ឡោះជាម្ចាស់ មិនមែនជាការពេញចិត្តខ្លួនឯងនោះឡើយ និងបំណងរបស់គេគួរតែផ្តោតលើការពិតដែលគេកំពុងធ្វើ គឺគេធ្វើដើម្បីអល់ឡោះជាម្ចាស់ ហើយនេះមិនអាចធ្វើទៅបានដោយមិនមានចិត្តស្មោះ និងមិនមានទំនាក់ទំនងវិជ្ជមានជាមួយអល់ឡោះជាម្ចាស់នោះឡើយ។[98]ភាពជោគជ័យអ្នកទូអាត គឺជាអ្នកដែលណែនាំមនុស្សតាមរយៈឧទាហរណ៍, ការដើរតួជាគំរូ បង្ហាញចរិកលក្ខណៈរបស់ព្យាការីដល់មនុស្ស អ្នកទូអាតត្រូវប្រកាន់ខ្ជាប់នូវការសឡាត ថ្វាយបង្គំ ការប្រព្រឹត្តអំពើល្អ និងការតស៊ូខិតខំលើការងារ។ ជារួមទូអាត គឺដើម្បីប្រកាន់ខ្ជាប់ទៅនឹងការបង្រៀនរបស់សាសនាអ៊ីស្លាមនៅក្នុងវិធីសាស្រ្តរបស់ពួកគេ និងរចនាបថនៃការងារឌាក់វ៉ះ និងជៀសវាងពីការបោកបញ្ឆោត ដើម្បីបញ្ចូលជំនឿអ៊ីស្លាមឲ្យដល់ដួងចិត្តរបស់មនុស្ស។[99]

លើសពីនេះទៀត ទូអាតគួរតែលើកកម្ពស់ខ្លួនឯងលើសីលធម៌ និងលើកម្រិតសិក្សារបស់ខ្លួន ពីព្រោះសង្គមជឿនលឿនមិនមានលក្ខណៈជាក់ស្តែង អំណោយផលចំពោះអ្នកទូអាតដែលមានចំណេះដឹងទាប មានភាពអន់ខ្សោយនៅក្នុងវិស័យការងារនៃភាពជាអ្នកដឹកនាំខាងបញ្ញាញាណ វិទ្យាសាស្រ្ត និងសីលធម៌នោះឡើយ និងទូអាតគួរតែរួមចែករំលែកទុក្ខលំបាករបស់ប្រជាពលរដ្ឋ ជូនពរឱ្យពួកគាត់មានសុខភាពល្អ និងជាសះស្បើយឡើងវិញ ជួយពួកគេក្នុងពេលបរាជ័យ លំបាក យកចិត្តទុកដាក់ចំពោះទុក្ខព្រួយ ការពារពួកគេប្រឆាំងនឹងភាពអយុត្តិធម៌ និងចូលរួមជាមួយក្រុមមនុស្សដែលមិនបានប្រព្រឹត្ត និងបំពានមនុស្ស។ ទូអាតគឺត្រូវភ្ជាប់ទំនាក់ទំនងជាមួយនឹងមនុស្ស មិនត្រូវបានបំបែកខ្លួនគេពីពួកគេនោះឡើយ ដើម្បីចែករំលែកដំណឹងល្អ ជំនួសការឱ្យមនុស្សទៅឆ្ងាយពីពួកគេ។ នៅក្នុងរឿងទាំងអស់នេះ ទូអាត គឺត្រូវដើរចេញពីលើជម្លោះផ្ទាល់ខ្លួន និងមិនត្រូវមានជម្លោះជាមួយមនុស្ស

នោះឡើយ។[100]

សរុបមក ការងារពាក់ព័ន្ធចម្បងរបស់អ្នកទូអាតផ្សព្វផ្សាយអ៊ីស្លាម គឺការបង្រៀន រំលឹក និងណែនាំមនុស្ស និងផ្ដល់ឱកាសនៃក្ដីសង្ឃឹមរហូតដល់ពួកគេត្រឡប់ទៅរកអ្នកបង្កើតរបស់ពួកគេវិញ ពោលគឺអល់ឡោះជាម្ចាស់។ ទូអាតត្រូវលើកទឹកចិត្តអ្នកដទៃ និងសង្ឃឹមសម្រាប់សេចក្ដីល្អរបស់ពួកគេ គឺពេញចិត្តប្រសិនបើគោលដៅរបស់ការងារឌាក់វ៉ះ ត្រូវបានសម្រេច និងជៀសវាងការអស់សង្ឃឹម ជាពិសេសប្រសិនបើលក្ខខណ្ឌជុំវិញមិនគាំទ្រលើការងារឌាក់វ៉ះ។[101]

## គុណភាពអប់រំរបស់ទូអាត

Al-Ghazali ជឿថានៅក្នុងពន្លឺនៃគម្ពីរអាល់គួរអាន ជម្រើសរបស់អល់ឡោះជាម្ចាស់ចំពោះប្រជាជាតិគឺអាស្រ័យលើគុណសម្បត្តិបញ្ញា និងសីលធម៌របស់ពួកគេដែលមានប្រយោជន៍សម្រាប់មនុស្សជាតិ និងមិនអាស្រ័យលើជាតិសាសន៍ ឬភូមិសាស្ត្រណាមួយឡើយ។[102] សម្រាប់ Al-Ghazali ភាពជោគជ័យរបស់ទូអាត អ្នកផ្សព្វផ្សាយអ៊ិស្លាមគឺអាស្រ័យលើការប្ដេជ្ញាចិត្តរបស់ពួកគេក្នុងការសិក្សាយ៉ាងទូលំទូលាយ និងស៊ីជម្រៅ។ ទូអាត ត្រូវអានពីគ្រប់ប្រភេទនៃអក្សរសិល្ប៍ និងនិន្នាការនៅក្នុងគំនិតរបស់មនុស្ស ដើម្បីយល់ពីជីវិត និងឥទ្ធិពលជុំវិញ ពួកគេត្រូវអានអំពីជំនឿផ្សេង ពីក្រុមមិនជឿលើសាសនាទស្សនវិជ្ជាផ្សេងៗ និងស៊ុនណះនៃលំអានរបស់ព្យាការីមហាំម៉ាត់ [103] និងជៀសវាងការអានសៀវភៅអត្ថបទដែលនិពន្ធក្នុងយុគសម័យអន់ថយ។ យោងទៅតាម Al-Ghazali ការងារឌាក់វ៉ះត្រូវការចំណេះដឹងអំពីគម្ពីរអាល់គួរអាន និង ស៊ុនណះផងដែរ។ វាមានសារៈសំខាន់ដូចគ្នាសម្រាប់តុអាតក្នុងការស្វែងយល់ពីប្រវត្តិសាស្ត្រនៃខលីហ្វះអ្នកដឹកនាំមូស្លីម និងការពិនិត្យមើលឲ្យបានទូលំទូលាយលើលក្ខខណ្ឌសហសម័យ។[104]

Al-Ghazali បានគូសបញ្ជាក់តួនាទីរបស់ភាសាអារ៉ាប់ និងអក្សរសិល្ប៍ជាតម្រូវការជាមុនសម្រាប់ការឌាក់វ៉ះ ដែលមានប្រសិទ្ធភាព។ការរៀនភាសាអារ៉ាប់ជួយមនុស្សឱ្យរៀនអំពីអ៊ីស្លាម ជម្រុញពួកគេឱ្យយល់ពីវិវរណៈ និងគាំទ្រការផ្សព្វផ្សាយជំនឿអ៊ីស្លាម។ ការបង្កើតបញ្ញាញាណរបស់ទូអាត ក៏រួមបញ្ចូលការសិក្សាអំពីវិទ្យាសាស្ត្ររបស់មនុស្ស រួមទាំងសីលធម៌ សង្គម និងទស្សនវិជ្ជានយោបាយ។ ពួកគេក៏ត្រូវយល់ដឹងអំពីនិន្នាការនៃគំនិតពីសម័យទំនើបផងដែរ។[105] ការងារឌាក់វ៉ះ ដែលមានប្រសិទ្ធភាពក៏ទាមទារចំណេះដឹងអំពីសង្គមវិទ្យា សេដ្ឋកិច្ច ការអប់រំ និងចិត្តវិទ្យាផងដែរ។ ដូច្នោះហើយអ្នកទូអាតត្រូវចូលទៅជិតវិទ្យាសាស្ត្រ ពីផ្នែកនៃទស្សនៈអ៊ីស្លាម ជាចុងក្រោយ ការបង្កើតបញ្ញា ពោលចំណេះដឹងសម្រាប់អ្នកទូអាតគឺដើម្បីរួមបញ្ចូលការសិក្សាអំពីវិទ្យាសាស្ត្រដែលមានលក្ខណៈជាធម្មជាតិ មានពីកំណើតមកម្លេះ។ អ្នកទូអាតត្រូវយល់ដឹងពីវិទ្យាសាស្ត្ររូបវិទ្យា រួមទាំងគីមីវិទ្យា ជីវវិទ្យា និងតារាសាស្ត្រ ហើយត្រូវស្គាល់ភូមិសាស្ត្រ រុក្ខសាស្ត្រ និងវិទ្យាសាស្ត្រសត្វផងដែរ។ [106] វិទ្យាសាស្ត្រដែលបានរៀបរាប់គឺសម្រាប់ Al-Ghazali សំខាន់ដើម្បីធ្វើការឌាក់វ៉ះ ដោយសារតែពួកគេជួយការងារឌាក់វ៉ះកែតម្រូវគំនិតរបស់មនុស្ស សម្របសម្រួលទំនាក់ទំនងរបស់ពួកគេជាមួយពិភពរូបវន្ត និងផ្ដល់ដល់មនុស្សនូវការណែនាំដ៏ស៊ីជម្រៅ។[107]

សរុបមក Al-Ghazali ព្យាយាមបង្ហាញមហិច្ឆិតាគំរូនៃការងារឌាក់វ៉ះ ដែលទូអាតត្រូវរៀន កត់សម្គាល់នូវបុគ្គលិកលក្ខណៈឲ្យបានស្ទាត់ជំនាញពីផ្នែកផ្សេងៗ។ ទោះបីជាយ៉ាងនេះក្តី គំរូរបស់គាត់ ទាមទារឱ្យមានជំនាញខាងសង្គម ជាមួយនឹងគំនិតសព្វវចនាធិប្បាយ ដែលអាចអនុវត្តន៍វិធីសាស្ត្រពហុវិន័យ ចំពោះផ្នែកនៃការស្រាវជ្រាវ ហេតុផល ឬប្រពៃណី ឬសីលធម៌របស់មនុស្ស។[108]

## បញ្ហានៃទូអាត

Al-Ghazali បានចង្អុលបង្ហាញពីបញ្ហា កត្តា ប្រឈមជាច្រើន និងការប៉ះពាល់ដល់ការងារឌាក់វ៉ះ។ ទាំងនេះរួមបញ្ចូលទាំងសំណួរនៃវប្បធម៌ និងទំនៀមទំលាប់។ ទូអាតជាគំរូមិនល្អបើសិនពួកគេខ្សោយលើការអនុវត្តកាតព្វកិច្ចអ៊ីស្លាម ការផ្តល់ឋានៈទាបដល់ស្ត្រី ប្រព័ន្ធអប់រំខ្សោយ ស្ថាប័នមានមិនគ្រប់គ្រាន់នៃការងារឌាក់វ៉ះ មូស្លីមមានការយល់ខុសអំពីជីវិតមនុស្ស ភាពខុសគ្នាខាងផ្លូវច្បាប់ ការមិនបានយល់លើអត្ថន័យនៅក្នុងគម្ពីរអាល់គួរអាន(al-naskh fi al-Qur'an) ការបរាជ័យក្នុងជីវិតលោកិយ និងវប្បធម៌បរទេសដ៏មានឥទ្ធិពលលើសង្គមអ្នកកាន់សាសនាអ៊ីស្លាម។ សម្រាប់ Al-Ghazali ទាំងអស់នេះបង្កើតជាបញ្ហាប្រឈមដ៏សំខាន់ ជាពិសេសនៅពេលដែលឌាក់វ៉ះ ទាមទារឱ្យមានការព្យាបាលដ៏ឆ្លាតវៃ និងទូលំទូលាយ ហើយស្ថានភាពនៃកិច្ចការដែលប្រឈមមុខនឹងប្រជាជនមូស្លីមគឺជាផ្នែកមួយនៃការថយក្រោយផ្នែកសេដ្ឋកិច្ច និងវិទ្យាសាស្ត្រដ៏គួរឱ្យព្រួយបារម្ភ។[109]

សម្រាប់ Al-Ghazali ភាពខុសគ្នាខាងបញ្ញាចេះដឹង និងនិកាយបានបង្កឡើង ការប្រេះស្រាំយ៉ាងជ្រៅក្នុងចំណោមប្រជាជនមូស្លីម ដែលបណ្តាលឱ្យមានការមិនយកចិត្តទុកដាក់សម្រាប់ទំនួលខុសត្រូវសង្គមទាំងក្នុងស្រុក និងក្រៅស្រុក។ ការមិនយកចិត្តទុកដាក់បែបនេះ គឺបណ្តាលមកពីការយកចិត្តទុកដាក់ខ្លាំងរបស់ប្រជាជនមូស្លីមលើផ្នែកខាងខាងក្រៅនៃសាសនាអ៊ីស្លាមជាជាងភាពពិតរបស់វា។[110] មានមូលហេតុនៃការធ្លាក់ចុះ មិនថាបញ្ញាស្មារី សង្គម ឬនយោបាយនោះទេ ហើយឥទ្ធិពលវប្បធម៌កេងប្រវ័ញ្ចមានលើបុគ្គលិកលក្ខណៈជនមូស្លីម។ ភាពល្ងង់ខ្លៅយូរអង្វែងបានធ្វើឱ្យមានការខ្វះខាតលើការស្រាវជ្រាវ និងការតាមដានទៅលើការងារឌាក់វ៉ះ និងបានអនុញ្ញាតឱ្យវប្បធម៌ពុករលួយ និងចលនានយោបាយដែលច្របូកច្របល់ បានឈានដល់ចំណុចហានិភ័យ។ ជាលទ្ធផល សារជាសកលរបស់សាសនាអ៊ីស្លាមបានធ្លាក់ចុះជាបណ្តើរៗ។ [111]

យោងទៅតាម Al-Ghazali ប្រជាជនមូស្លីមគួរតែធ្វើជាគំរូដ៏ល្អដើម្បីឆ្លុះបញ្ចាំងពីសារ ឬសេចក្តីបង្រៀនរបស់អ៊ីស្លាម និងដើរតួជាអ្នកទទួលការងារពិតប្រាកដនៃការបង្រៀន និងផ្សព្វផ្សាយសារដ៏មានតម្លៃ។ Al-Ghazali បានអះអាងថា ប្រទេសដែលមានសារ ពោលគឺប្រទេសកាន់សាសនាអ៊ីស្លាមមួយគួរតែបង្កើតប្រព័ន្ធជីវិតរបស់ខ្លួនស្របតាម។ ការធ្វើដូច្នេះ ភាពល្អរបស់ប្រជាជនម៉ូស្លីមនៅទីបំផុតនឹងអាចមើលឃើញនៅទូទាំងព្រំដែនប្រទេសរបស់ពួកគេ និងឈានដល់ពិភពលោកទាំងមូល។[112] គំរូមូស្លីមក៏អាចមកជារូបរាងដែរ ដូចជារដ្ឋាភិបាលប្រទេសមូស្លីមដែលតាមរយៈស្ថាប័នផ្សេងៗគួរតែយកចិត្តទុកដាក់ថែរក្សាប្រជាពលរដ្ឋ លើកតម្កើងយុត្តិធម៌ តស៊ូមតិដើម្បីសន្តិភាព និងប្រឆាំងនឹងភាពលោភលន់នឹងផលប្រយោជន៍ផ្ទាល់ខ្លួនAl-Ghazali រំពឹងថាប្រសិនបើសាសនាអ៊ីស្លាម ត្រូវបានយក

មកអនុវត្តន៍បានល្អជាគំរូមួយភាគរយខ្ពស់នៃប្រជាជនម៉ូស្លីមនឹងមានការអប់រំខ្លាំង។ សម្រាប់ Al-Ghazali ការងារឌាក់វ៉ះមិនរីកចម្រើននោះទេ ប្រសិនបើប្រជាជនមូស្លីមបរាជ័យក្នុងផ្នែកសំខាន់ៗនៃសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម ឬខ្វះការយល់ដឹងអំពីជីវិត និងវិទ្យាសាស្ត្ររបស់វា។ [113] ដូច្នេះហើយ ជំនឿនឹងមិនរីកចម្រើនដរាបណាស្ថានភាពបញ្ញា និងសេដ្ឋកិច្ចរបស់ប្រជាជនមូស្លីមនៅតែក្រីក្រក្សត់ខ្សោយ។

សម្រាប់ Al-Ghazali ស្ថានភាពសង្គមនៃប្រជាជនមូស្លីមនាពេលបច្ចុប្បន្ននេះមិនមានឥទ្ធិពលដល់ការរីកចម្រើនរបស់ការងារឌាក់វ៉ះប៉ុណ្ណោះនោះទេ ប៉ុន្តែក៏បង្កឱ្យមានការសង្ស័យផងដែរលើតម្លៃរបស់សាសនាអ៊ីស្លាម និងវិសាលភាពដែលមនុស្សជាតិនឹងអាចទទួលបានអត្ថប្រយោជន៍ពីវា។ [114] សម្រាប់គាត់ អាកប្បកិរិយាមូស្លីម និងការបែកបាក់សង្គមអាចងាយរារាំងមនុស្សពីជំនឿលើសាសនាអ៊ីស្លាម។ បច្ចុប្បន្ននេះ មូស្លីមមិនអាចណែនាំអ្នកដ៏ទៃបាននោះទេ ហើយអ្នកដឹកនាំសាសនារបស់ពួកគេក៏មិនអាចដៃរពោលនាសម័យរបស់លោក សង្គមអ្នកមូស្លីមស្ថិតក្នុងភាពអន់ខ្សោយយ៉ាងខ្លាំង។ នេះបើយោងតាមAl-Ghazal ប្រជាជនមូស្លីមបានបរាជ័យក្នុងការបញ្ចូលតម្លៃ និងការបង្រៀនរបស់សាសនាអ៊ីស្លាម មិនថានៅក្នុងការបង្កើតយុទ្ធសាស្ត្រការងារឌាក់វ៉ះ ឬបង្កើតវិធីសាស្ត្រនៃការផ្សព្វផ្សាយសាសនាអ៊ីស្លាម។ [115] ជាជាងការអភិវឌ្ឍមូលដ្ឋានសម្រាប់ចំណេះដឹងខាងសាសនា និងការរួមចំណែកខាងសីលធម៌ ក្នុងការបង្កើតជាមនុស្សដែលមានសមត្ថភាពលើការអនុវត្តនូវសេចក្តីបង្រៀនរបស់អ៊ីស្លាមនោះ វប្បធម៌មូស្លីម (thaqāfah) នេះបើយោងតាម al-Ghazali បាននាំបញ្ញាទៅរកភាពដាច់ដោយឡែកមួយ។[116] សម្រាប់គាត់ ទំនៀមទម្លាប់ភាគច្រើនគ្មានមូលដ្ឋាន ពេលរបស់អ្នកមូស្លីមនាសម័យកាលនោះ ហើយមានដើមកំណើតនៅសម័យកាលនៃការដើរថយក្រោយ។

លោក Al-Ghazali ក៏បានពិភាក្សាអំពីបញ្ហាមួយចំនួនដែលរួមគ្នាស្មើនឹងការដើរថយក្រោយយ៉ាងច្រើនសម្រាប់ការងារឌាក់វ៉ះ។ ទី១គាត់បានស្ទង់មតិលើប្រវត្តិសាស្ត្រមូស្លីម ហើយបានអះអាងថា ការអនុវត្តកាតព្វកិច្ចសាសនាអ៊ីស្លាមមិនបានល្អមាន វាបានរារាំងយ៉ាងខ្លាំងដល់ការរីកចម្រើនរបស់ការងារឌាក់វ៉ះ។ ទី២ បញ្ហារវាងជីវិតលោកិយនេះ និងបរលោក ពោលការមិនយល់របស់មនុស្សបានបណ្តាលឲ្យការងារឌាក់វ៉ះអន់ថយយ៉ាងខ្លាំង ហើយបណ្តាលឱ្យមានអយុត្តិធម៌ធំៗចំនួនពីរះ ការមិនយល់ ឬគាំទ្រការភ្ជាប់ជីវិតរបស់មនុស្ស និងការមិនយល់ពីការណែនាំពីសេចក្តីបង្រៀនរបស់អ៊ីស្លាម ឬការមិនយល់ពីការប្រតិបត្តិតាមបទបញ្ញានៃសាសនាអ៊ីស្លាម។ ទី៣គឺការយល់ច្រឡំលើការងារឌាក់វ៉ះ ពោលការមិនខ្វល់ខ្វាយ (al-naskh) ។ Al- Ghazali បានចាត់ទុកការមិនខ្វល់ខ្វាយ ការនិរាករណ៍ជាអវិជ្ជមាន ដោយមើលឃើញថាវាជាការធ្វើឱ្យខូចប្រយោជន៍ការងារឌាក់វ៉ះ និងបំផ្លាញភាពស្រស់ស្អាតនៃធម្មជាតិរបស់វា។ ទី៤គឺអ្នកទូអាត មានការប្រកាន់ខ្ជាប់ ឬយកចិត្តទុកដាក់ពេក ដូចជាការគិតមមៃជាមួយនឹងជម្លោះដ៏តូចតាច ។ ចុងក្រោយ អវត្តមាននៃស្ថាប័នការងារឌាក់វ៉ះ ដែលគួរជម្រុញឲ្យមានភាពល្អ ស្វែងយល់ពីវិស័យបញ្ញាថ្មីៗ និងតាមដានវឌ្ឍនភាពសមិទ្ធិផល ផ្ទៃក្នុង និង ខាងក្រៅប្រទេស។[117]

ដូចដែលភាពតានតឹងលើការអភិវឌ្ឍបញ្ញាញាណដែលបានបង្ហាញដោយ Al-Ghazali បានដាក់ការពិភាក្សាលើការកែលម្អការងារខាក់វ៉ះ នៅក្នុងក្របខ័ណ្ឌនៃការអប់រំអ៊ីស្លាម។ Al-Ghazali បានស្វែងរកដំណោះស្រាយរបស់ការងារខាក់វ៉ះរបស់រដ្ឋនៃអ្នកកាន់សាសនាអ៊ីស្លាមដែលកាន់តែយ៉ាប់យ៉ឺន និងជម្រុញការផ្សព្វផ្សាយវប្បធម៌សាសនាអ៊ីស្លាមតាមរបៀបដែលវាលើកកម្ពស់គំនិតខាក់វ៉ះ លាយបញ្ចូលគ្នារវាងការងារខាក់វ៉ះ ជាមួយនឹងធាតុផ្សំនៃកត្តាពេលវេលានៃការពិត ពោលភាពជាក់ស្តែងនៃសង្គមរបស់អ្នកមូស្លីម។ ដំណោះស្រាយណាមួយចំពោះបញ្ហារបស់តួអាតនឹងតំណាងឱ្យនៅក្នុងទស្សនៈរបស់ Al-Ghazali ដែលជាការរួមចំណែកក្នុងការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌទូទៅនៃសង្គមទាំងមូល។

## ការរិះគន់លើទូអាត

ការរិះគន់របស់ Al-Ghazali លើទូអាតផ្តោតលើបុគ្គលជាក់លាក់ ឬក្រុម ហើយគាត់អាចមានការរិះគន់លើបញ្ហាទូទៅផងដែរ។ ទោះបីយ៉ាងណាក៏ដោយ វាមានទៅដោយវិធីសាស្ត្រ និងគំនិតរបស់គាត់ដោយមិនមានបំណងញុះញង់ និងវាមានលក្ខណៈស្ថាបនា បន្ទាប់មកការរិះគន់របស់គាត់អាចមានប្រយោជន៍លើវិធីសាស្ត្រការងារខាក់វ៉ះ។ ការរិះគន់របស់ Al-Ghazali បានទទួលជោគជ័យក្នុងកម្រិតមួយ ព្រោះវាបានបង្កើត ឬបើកការពិភាក្សាលើបច្ចុប្បន្នស្តីអំពីការងារខាក់វ៉ះ បញ្ហាផ្លូវច្បាប់ផ្សេងៗដែលភ្ជាប់ជាមួយវានឹងគោលការណ៍នៃការងារខាក់វ៉ះ និងរបៀបដែលពួកគេត្រូវយល់ ឬត្រូវប្រើនៅក្នុងសង្គម។ ទោះជាយ៉ាងណាក៏ដោយ ការរិះគន់របស់ Al-Ghazali លើកឡើងពីបញ្ហាដែលវាមិនបានដោះស្រាយ មិននាំទៅរកវិធីសាស្ត្រជាប្រព័ន្ធណាមួយដែលឆ្លុះបញ្ចាំងពីឯកភាព វត្ថុបំណង ឬស្ថិរភាព និងបង្ហាញពីតម្រូវការសម្រាប់កិច្ចខិតខំប្រឹងប្រែងដោះស្រាយជាប្រព័ន្ធលើការងារខាក់វ៉ះនោះឡើយ ប៉ុន្តែវាជាខ្លឹមសារទូលំទូលាយនៅក្នុងការខាក់វ៉ះនាសម័យទំនើប ពោលវាមានប្រយោជន៍ច្រើន។

រូបភាពដ៏ល្អរបស់ Al-Ghazali នៃ ducātបង្កើនសំណួរការរិះគន់ជាបន្តបន្ទាប់។ ដំបូង "ទូអាត" ទាំងអស់នោះមានគំនិតរួមបញ្ចូលវិធីសាស្ត្របែបប្រពៃណីជាមួយទំនើបកម្ម និងប្រើជំនាញរបស់ពួកគេដោយពន្លឺនៃការយល់ដឹងរបស់ពួកគេជាមួយនឹងបរិបទសេដ្ឋកិច្ច សង្គម និងវប្បធម៌សម្រាប់ការងារខាក់វ៉ះរបស់ពួកគេ ។ ប្រសិនបើមានជាករណីបន្ទាប់ត្រូវយកមកពិភាក្សាណាមួយបន្ថែមទៀតគួរតែផ្តោតលើដំណើរការនៃការធ្វើសមាហរណកម្មនូវរឿងដែលត្រូវធ្វើ និងវិធីសាស្រអ្វីៗផ្សេងទៀតផងដែរដើម្បីទទួលបានចំណេះដឹងអ៊ីស្លាម និងវិធីសាស្ត្រនៃសម័យទំនើបតាមទស្សនៈរបស់ការងារខាក់វ៉ះ។ ការសង្កត់ធ្ងន់របស់ Al-Ghazali លើស្តង់ដារអប់រំរបស់ទូអាតបានចោទជាសំណួរថាតើស្ថាប័នអប់រំអ៊ីស្លាមប្រភេទណាដែលអាចជួយទូអាតទទួលបានជំនាញផ្សេងៗដែលបានលើកឡើង។ នេះជាថ្មីម្តងទៀតនាំឱ្យមានសំណួរនៃទស្សនវិស័យ កម្មវិធីសិក្សា និងបុគ្គលិក។ ច្បាស់ណាស់ការមិនយកចិត្តទុកដាក់របស់ Al-Ghazali ចំពោះវិធីដោះស្រាយបញ្ហាដែលគាត់និយាយបានពង្រឹងការពិតដែលថាគាត់មានការព្រួយបារម្ភជាធម្មតាជាមួយនឹងការលើកឡើងនូវសំណួររបស់ការងារខាក់វ៉ះ និងទូអាតនៅកម្រិតទូទៅដោយលោកមិនបង្កើតកម្មវិធីខាក់វ៉ះលម្អិតសម្រាប់ការអនុវត្តនោះឡើយ ពោលវិធីសាស្ត្រខាក់វ៉ះទាមទារការអនុវត្តឲ្យស្របតាមសម័យកាលដើម្បីឲ្យវាមានប្រសិទ្ធិភាព។

# ជំពូកទី៤

## ទស្សនៈរបស់ Al-Ghazali លើវិធីសាស្ត្រនៃការងារឌាក់វ៉ះ

វិធីសាស្ត្រការងារឌាក់វ៉ះរបស់ Al-Ghazali គឺជាប្រធានបទកណ្តាលនៅក្នុងជំពូកនេះ។ ដំបូងវាទាក់ទងនឹងវិធីសាស្ត្ររបស់គាត់ទៅការងារឌាក់វ៉ះនិងការយល់ដឹងរបស់គាត់អំពីអាទិភាពលើកិច្ចការឌាក់វ៉ះ និងទំនាក់ទំនងរបស់អ្នកទូអាត ទៅនឹងបញ្ញាស្មារតីដែលទទួលយក និងការអធិប្បាយបង្ហាញពីសាសនាអ៊ីស្លាម។ ទី២ ដំណោះស្រាយនៃទំនាក់ទំនងរបស់ការងារឌាក់វ៉ះ ទៅនឹងច្បាប់អ៊ីស្លាម។ ទី៣ ការទាក់ទងរវាងការងារឌាក់វ៉ះ នឹងស្ត្រី។ Al-Ghazali នៅចំណុចនេះបកស្រាយឡើងវិញនូវសំណួរផ្លូវច្បាប់ជាច្រើនទាក់ទងនឹងស្ត្រី ដើម្បីបង្កើតក្របខណ្ឌដែលផ្តល់ភាពស្របច្បាប់ដល់ការចូលរួមរបស់ស្ត្រីក្នុងជីវិតសង្គម និងនយោបាយ និងគាំទ្រគោលជំហររបស់គាត់ដែលថាស្ត្រី មិនមែនមានត្រឹមតែបុរសប៉ុណ្ណោះនោះទេ ដែលអាចរួមចំណែកជាវិជ្ជមានដល់ការងារឌាក់វ៉ះ និងកំណែទម្រង់សង្គមអ៊ីស្លាម។

### វិធីសាស្ត្រទៅលើការងារឌាក់វ៉ះ

វិធីសាស្ត្រលើការងារឌាក់វ៉ះ គឺជាអ្វីដែលបកប្រែចំណេះដឹងរបស់អ្នកទូអាត និងបទពិសោធន៍ចូលទៅក្នុងកិច្ចការនៃការផ្សព្វផ្សាយសាសនាអ៊ីស្លាម។ វាក៏ឆ្លុះបញ្ចាំងពីអាទិភាពនៃការងារឌាក់វ៉ះ ការយកចិត្តទុកដាក់របស់ទូអាតនិងការជាប់ពាក់ព័ន្ធការងារឌាក់វ៉ះសម្រាប់សង្គម។ យោងទៅតាម Al-Ghazali អ្នកកទូអាតគួរតែបង្ហាញជំនឿរបស់ពួកគេក្នុងការអនុលោម ពោលឲ្យស្របតាមវិធីសាស្ត្រដែលមាននៅក្នុងគម្ពីរអាល់គួរអាន [118] ដែលប្រកាន់ខ្ជាប់នូវរចនាបថជាក់លាក់មួយក្នុងការណែនាំអ្នកបង្កើតពោលគឺអល់ឡោះជាម្ចាស់ និងគុណលក្ខណៈដ៏មហាឧត្តុងឧត្តមរបស់ទ្រង់ដំមនុស្សលោក។ សម្រាប់គាត់ការឌាក់វ៉ះ គឺជាការផ្សព្វផ្សាយដ៏ស្មោះត្រង់នៃសេចក្តីពិតខាងសាសនាអ៊ីស្លាម និងការបកស្រាយពិតប្រាកដនៃជំនឿ និងច្បាប់អ៊ីស្លាម។ [119] យោងទៅតាម Al-Ghazali ការងារឌាក់វ៉ះត្រូវបានភ្ជាប់ជាមូលដ្ឋានជាមួយនឹងការបំភ្លឺនៃភាពឯកទេពនិយម ពោលគឺការគោរពសក្ការៈអល់ឡោះជាម្ចាស់តែមួយអង្គគត់ ជំនួសឱ្យការយល់ឃើញផ្នែកច្បាប់បន្ទាប់បន្សំ នេះនាំទៅរកភាពល្អ និងបង្រួបបង្រួមមនុស្សជុំវិញកិច្ចប្រតិបត្តិសាសនាដែលជាកាតព្វកិច្ច។ [120]

យ៉ាងណាក៏ដោយ Al-Ghazali ហាក់ដូចជារវល់ខ្លាំងពេកជាមួយនឹងឥទ្ធិពលនៃការខុសគ្នាផ្លូវច្បាប់ចំពោះការខិតខំដើម្បីការងារឌាក់វ៉ះ។ ដើម្បីរំដោះការងារឌាក់វ៉ះពីការក្តាប់ជាប់នៃភាពខុសគ្នាផ្នែកច្បាប់ ពោលភាពយល់មិនស្របគ្នាលើច្បាប់អ៊ីស្លាម គាត់បានស្នើនូវអ្វីដែលគាត់ហៅថា "ការលើកលែងនៅក្នុងច្បាប់អ៊ីស្លាម" ។ ការយកចិត្តទុកដាក់បែបនេះពង្រឹងឲ្យគាត់ ខិតខំលើការយល់ដឹងដ៏ត្រឹមត្រូវ និងការអនុវត្តច្បាប់នៅក្នុងការងារឌាក់វ៉ះ។យោងទៅតាម Al-Ghazali, ទូអាតចុះខ្សោយ ឬដឹកនាំសង្គមមូស្លីមមិនបានត្រឹមត្រូវ នៅពេលពួកគេបង្ហាញសាសនាអ៊ីស្លាមដោយផ្នែកច្បាប់បន្ទាប់បន្សំ ឬការពិភាក្សាខាងទ្រឹស្តីទស្សនៈពោលជាមុននោះ។[121]ទន្ទឹមនឹងទម្រង់ជាទម្លាប់នៃការ

ផ្សព្វផ្សាយសាសនាអ៊ីស្លាម ពោលគឺឧទាហរណ៍ខុតហ្វះថ្ងៃសុក្រ Al-Ghazali និយាយអំពីអ្វីដែលគាត់ហៅថា al-I'lām al-da'awi (ដំណឹងអំពីការឌាក់វ៉ះ) ។ នេះគឺជាការផ្សព្វផ្សាយសារអ៊ីស្លាមដោយស្មោះត្រង់ ដោយប្តេជ្ញាផ្សព្វផ្សាយការពិត និងការគាំទ្រដើម្បីសុខុមាលភាពរបស់មនុស្សជាតិ។[122] លើសពីនេះ Al-Ghazali ហាក់បីដូចជាមានការព្រួយបារម្ភកាន់តែខ្លាំងជាមួយនឹងឥទ្ធិពលនៃការអធិប្បាយទៅលើវិធីសាស្ត្រលើការងារឌាក់វ៉ះ ។ នៅក្នុងការសរសេររបស់គាត់ ភាពខុសប្លែកគ្នារវាងការឌាក់វ៉ះ ការអធិប្បាយ និងអាជីពវិជ្ជាជីវៈបានធ្វើឱ្យអ្នកកាន់សាសនាអ៊ីស្លាមមួយចំនួនយល់ថាការឌាក់វ៉ះ ត្រូវបានកំណត់ចំពោះការអធិប្បាយតាមសាសនា ការស្លៀកពាក់តាមរបៀបជាក់លាក់មួយ ឬធ្វើដំណើរស៊ីរ៉ាស់ចំនួនមួយថ្ងៃទៅកាន់ភូមិជិតខាងនោះ និងការយល់ឃើញនេះបាននាំឱ្យមានការផ្តាច់ចេញពីសង្គម សាលារៀន និងការសិក្សា។

ថាតើការយកចិត្តទុកដាក់ចំពោះគម្ពីរអាល់គួរអានជាក្របខ័ណ្ឌសម្រាប់កការងារឌាក់វ៉ះឬសម្លឹងមើលការអនុលោមតាមគារឌាក់វ៉ះ ជាមួយនឹងតម្រូវការនៃច្បាប់នេះ A-Ghazali បានបង្ហាញចំណាប់អារម្មណ៍ពិតប្រាកដនៅក្នុងការយល់ដឹង និងអនុវត្តន៍វិធីសាស្ត្រអ៊ីស្លាមប្រកបដោយប្រសិទ្ធភាពលើការឌាក់វ៉ះ។ វិធីសាស្ត្ររបស់គាត់ចំពោះការឌាក់វ៉ះ ពាក់ព័ន្ធនឹងតម្រូវការ និងអត្ថន័យនៃសេចក្តីបង្រៀនរបស់អ៊ីស្លាម ប៉ុន្តែមិនមែនគ្រាន់តែជាសំណុំនៃទ្រឹស្តីនោះទេ ផ្ទុយទៅវិញ វាពាក់ព័ន្ធនឹងការពង្រឹងចរិកលក្ខណៈនៃសីលធម៌របស់ទូអាត។ កង្វះសមត្ថភាពសីលធម៌ទាំងនោះវាផ្តល់ប៉ះពាល់ដល់ការងារឌាក់វ៉ះ និងបង្កឱ្យមានការសង្ស័យក្នុងចំណោមសហគមន៍ដែលផ្សព្វផ្សាយ។ សម្រាប់ Al-Ghazali វិធីសាស្ត្រលើការងារឌាក់វ៉ះ វាត្រូវបានផ្សារភ្ជាប់ផ្ទាល់ខ្លួនអ្នកទូអាត ហើយត្រូវបានតម្រង់ទៅបង្កើតការយល់ដឹងខាងសាសនាអ៊ីស្លាមដ៏ត្រឹមត្រូវ និងមានប្រសិទ្ធភាព។

**វិធីសាស្ត្រច្បាប់ឌាក់វ៉ះ (Fiqh al-Dawah)**

Al-Ghazali បានអនុវត្តន៍ហេតុផលទាក់ទងទាំង២រវាងការឌាក់វ៉ះ និងច្បាប់ ដំបូង ចូលទៅក្នុងបញ្ហានៃការឌាក់វ៉ះ និងរបៀបវគួរតែត្រូវបានយល់ ចូលទៅជិត និងអនុវត្តន៍វា និងទី២ ដោះស្រាយចំណោទសំណួរនៃច្បាប់ និងរបៀបដែលវាគួរធ្វើការបកស្រាយ និងអនុវត្តន៍ដើម្បីបម្រើផលប្រយោជន៍ដ៏ល្អបំផុតសម្រាប់ការងារឌាក់វ៉ះ ។លោក Al-Ghazali បានគូសបញ្ជាក់អំពីតម្រូវការក្នុងការអនុវត្តតាម និងទ្រទ្រង់គោលដៅរបស់ការងារឌាក់វ៉ះ ។ សម្រាប់រឿងនេះ គាត់ត្រូវពាក់មួកភ្លោះទាំងធ្វើជាអ្នកច្បាប់ និងអ្នកទ្រឹស្តីទាក់ទងនឹងការឌាក់វ៉ះ។

នៅក្នុងការពិនិត្យមើលឡើងវិញនូវយុត្តាធិការអ៊ីស្លាម បន្ទាប់មក Al-Ghazali បានស្វែងរកដំណោះស្រាយចំពោះបញ្ហាដែលតាមទស្សនៈរបស់គាត់បានបង្អាក់ការងារឌាក់វ៉ះ និងប៉ះពាល់អវិជ្ជមានដល់គំរូរបស់គាត់។ នេះបង្ហាញថាគាត់ការសិក្សាច្បាប់ទាក់ទងនឹងការងារឌាក់វ៉ះ ជាយុទ្ធសាស្ត្រជាក់ស្តែងដោយមានការយកចិត្តទុកដាក់តិចតួចចំពោះការបង្កើតវិធីសាស្ត្រជាប្រព័ន្ធនៃគំនិតការងារឌាក់វ៉ះ។ នេះគឺជាក់ស្តែងនៅក្នុងចំណង់ចំណូលចិត្តផ្នែកច្បាប់ជាច្រើនរបស់គាត់ ដែលមិនបានជោគជ័យសម្រាប់បម្រើការអនុវត្តច្បាប់ស្របគ្នា ឬវិធីសាស្ត្រជាប្រព័ន្ធលើចំណោទនៃការរួមបញ្ចូលជាមួយនឹងការងារឌាក់វ៉ះ។

ការព្រួយបារម្ភរបស់ Al-Ghazali គឺថា យុត្តាធិការអ៊ីស្លាមគួរតែយកមកបម្រើលើការងារឌាក់វ៉ះ និងថា សាលក្រមផ្លូវច្បាប់មិនគួរជំរុញអ្នកមិនមែនជាមូស្លីមឲ្យនៅឆ្ងាយពីសាសនាអ៊ីស្លាម ហើយក៏មិនបណ្តេញអ្នកធ្វើខុសឲ្យនៅឆ្ងាយពីការណែនាំផងដែរ។ Al-Ghazali បានដាក់ចេញនូវក្របខ័ណ្ឌទូលំទូលាយសម្រាប់ទំនាក់ទំនងរវាងច្បាប់ និងការងារឌាក់វ៉ះ ប៉ុន្តែតែងតែមានការយកចិត្តទុកដាក់យ៉ាងយកចិត្តទុកដាក់ចំពោះផលប្រយោជន៍ដ៏ល្អបំផុតរបស់ការងារឌាក់វ៉ះ។ ជាឧទាហរណ៍ លោកបានពិភាក្សាអំពីសេចក្តីសម្រេចផ្លូវច្បាប់ស្តីពីការហាមឃាត់តន្ត្រី ការជឿជាក់បែបនេះមិនគួររារាំងការធ្វើឲ្យមានលើជំនឿលើអល់ឡោះនោះឡើយ។គាត់មានអារម្មណ៍ថានេះជាការពិតជាពិសេសនៃសង្គមលោកខាងលិចទាក់ទងនឹងសំណួរនៃតន្ត្រី បទចម្រៀងឬការគ្របដណ្តប់មុខរបស់ស្ត្រីមិនគួរត្រូវបានលើកឡើងក្នុងវគ្គបបណ្តុះបណ្តាលឌាក់វ៉ះនោះទេ។ វិធីសាស្ត្រច្បាប់របស់ Al-Ghazali សម្រាប់ការឌាក់វ៉ះយ៉ាងណាក៏ដោយ វាបង្ហាញពីការចាប់អារម្មណ៍យ៉ាងខ្លាំងជាមួយនឹងប្រតិកម្មរបស់សង្គមលោកខាងលិច ធៀបនឹងការអនុវត្តរបស់មូស្លីម និងការព្រួយបារម្ភរបស់គាត់ទាក់ទងនឹងផលប្រយោជន៍របស់ឌាក់វ៉ះ និងក្តីសុបិន្តរបស់គាត់សម្រាប់ប្រតិកម្មវិជ្ជមានពីការផ្សព្វផ្សាយដល់មនុស្សបានធ្វើឱ្យគាត់ទទួលយកចំនួនរបាយការណ៍ដ៏ច្រើនសន្ធឹកសន្ធាប់( aḥādīth daᶜifah )។

ការងាររបស់ Al-Ghazali នៅតែផ្តល់នូវការស្វែងរកយ៉ាងក្លាហាននៃបញ្ហាសហសម័យដែលផ្តល់ការលំបាកដល់ការងារឌាក់វ៉ះ ទាំងខាងក្នុង និងខាងក្រៅ។ គេអាចសន្និដ្ឋានបានថា ការខិតខំប្រឹងប្រែងរបស់ Al-Ghazali ទោះបីជាស្ថិតក្នុងដំណាក់កាលប្រៀបដូចជាទារកក៏ដោយ ទោះបីជាយ៉ាងណាក៏ដោយ វាបានបំបែកភាពតានតឹង ភាពស្ងៀមស្ងាត់ដែលបានឡោមព័ទ្ធការងារឌាក់វ៉ះជាមួយនឹងច្បាប់ និងបានផ្តួចផ្តើមជាមូលដ្ឋានគ្រឹះនៃសុន្ទរកថាអត្ថបទអប់រំសម្រាប់សម័យទំនើបសម្រាប់ការងារឌាក់វ៉ះ ច្បាប់ និងវឌ្ឍនភាពអ៊ីស្លាម។

គាត់ក៏បានគូសបញ្ជាក់អំពីវិធីថ្មីនៃការវិភាគ ដែលដាស់តឿនប្រជាជនមូស្លីមឲ្យយកចិត្តទុកដាក់ចំពោះ ការបង្ហាញវប្បធម៌ និងសាសនាទាក់ទងនឹងសកម្មភាពឌាក់វ៉ះ ជាពិសេសនៅសង្គមលោកខាងលិច និងចំពោះការពិតនៃទំនាក់ទំនងនៃសង្គមមូស្លីមជាមួយនឹងមនុស្សជាតិជាទូទៅ។

## ស្ត្រីនិងការងារឌាក់វ៉ះ

Al-Ghazali បានពិនិត្យឡើងវិញនូវការសន្មត់ទ្រឹស្តីមួយចំនួនទាក់ទងនឹងស្ត្រី ដោយសារការយល់ឃើញ និងទំនៀមទម្លាប់វប្បធម៌ដែលរំខានដល់ទំនាក់ទំនងស្ត្រី វាបានជះឥទ្ធិពលអវិជ្ជមានដល់ស្ត្រី និងការចូលរួមចំណែកទាំងអស់ ក្នុងនាមសាសនាអ៊ីស្លាម។ Al-Ghazali បានពិភាក្សាម្តងហើយម្តងទៀតអំពីបញ្ហានៃការជ្រៀតចូលវប្បធម៌ចូលទៅក្នុងការបកស្រាយសាសនា ការបរាជ័យនៃអ្នកទូអាតនៅក្នុងវិធីសាស្ត្ររបស់ពួកគេចំពោះសំណួររបស់ស្ត្រី និងតម្រូវការដើម្បីពិនិត្យឡើងវិញនូវទស្សនៈផ្លូវច្បាប់ទាក់ទងនឹងសំណួរផ្សេងៗដែលពាក់ព័ន្ធនឹងស្ត្រី។ សម្រាប់ al-Ghazali ការយល់ដឹងពិតប្រាកដអំពីបញ្ហារបស់ស្ត្រីជានានូវវិធីសាស្ត្រត្រឹមត្រូវ ទាក់ទងនឹងការរួមចំណែករបស់ពួកគេចំពោះសង្គមសម័យទំនើប។

Al-Ghazali បានអះអាងថាការបង្រៀនរបស់គម្ពីរអាល់គួរអាន ទាក់ទងនឹងស្ត្រីត្រូវបានគេមិនអើពើទាំងស្រុង។ ស្ត្រីកម្រទទួលបានចំណែករបស់ពួកគេណាស់កម្រត្រូវបានពិគ្រោះជាមួយនឹងការគោរពពាក់ព័ន្ធទៅនឹងការរៀបការរបស់ពួកគេ. [123]ហើយមិនត្រូវបានយកចិត្តទុកដាក់ខ្លាំង និងបន្សល់ទុកដោយភាពល្ងង់ខ្លៅដោយអ្នកកាន់សាសនាអ៊ីស្លាមដែលមិនបានទទួលបានការអប់រំ។ ជាលទ្ធផល ពួកគេបានភ្លេចកាតព្វកិច្ច និងទំនួលខុសត្រូវខាងសាសនាអ៊ីស្លាមនៅក្នុងជីវិត។[124] យោងទៅតាម Al- Ghazali ទំនៀមទំលាប់សង្គម និងវប្បធម៌បែបនេះបានរួមចំណែកយ៉ាងសំខាន់ដល់ឋានៈទាបរបស់ស្ត្រី ពោលនៅក្នុងសង្គម ដែលជាគុពិតអ៊ីស្លាមលើកតម្កើងស្ត្រី ជាឧទាហរណ៍ ការបដិសេធស្ត្រីលើសិទ្ធិសេដ្ឋកិច្ចរបស់ពួកគេ។ [125] ជាងនេះទៅទៀត ទំនៀមទម្លាប់ និងការយល់ឃើញរបស់បុរសទាំងនេះបានបង្អាក់ការរួមចំណែករបស់ស្ត្រីក្នុងសង្គម ធ្វើឱ្យពួកគេមានភាពអសកម្មទាំងក្នុងជីវិត និងសាសនា ហើយក្នុងការធ្វើដូច្នេះរក្សាភាពងងឹតនៃភាពល្ងង់ខ្លៅ រំលោភលើការបង្រៀនរបស់សាសនាអ៊ីស្លាម និងនាំទៅរកការធ្លាក់ចុះនៃការអប់រំរបស់ស្ត្រី និងប្រជាជាតិទាំងមូល។សម្រាប់ Al-Ghazali ទំនៀមទំលាប់ទាំងនេះ ដោយការធ្លាក់ចុះខ្សោយនៃតួនាទីរបស់ស្ត្រី ដោយបង្ខាំងស្ត្រីឱ្យស្ថិតនៅក្នុងរង្វង់នៃការបម្រើការសប្បាយខាងរូបរាងកាយប៉ុណ្ណោះ ពោលដែលវាផ្ទុយពីច្បាប់អ៊ីស្លាម។ គោលជំហរសីលធម៌របស់ស្ត្រីត្រូវបានមើលតាមរយៈកញ្ចក់នៃកិត្តិយស ដូចជា អំពើខុសឆ្គងរបស់កូនប្រុសត្រូវបានចាត់ទុកថាជាភាពរីករាយរបស់យុវវ័យ ចំណែកឯទង្វើខុសឆ្គងរបស់ស្ត្រីត្រូវបានចាត់ទុកថាជាទង្វើខុសឆ្គង ភាពអាម៉ាស់ដែលផលប៉ះពាល់ដ៏ធ្ងន់ធ្ងរ។

យុទ្ធសាស្ត្ររបស់ Al-Ghazali គឺផ្តល់ការបកស្រាយច្បាប់ថ្មីៗជុំវិញស្ថានភាពរបស់ស្ត្រី។ គាត់បានអះអាង ជាឧទាហរណ៍ថាមិនមានច្បាប់អ៊ីស្លាមដែលអាចប្រកែកបានដែលទាមទារស្ត្រីដើម្បីបិទមុខរបស់ពួកគេជាដាច់ខាតទាំងមូលនោះឡើយ។ ដើម្បីបង្កើតឡើងវិញនូវមុខតំណែងតួនាទីរបស់ស្ត្រី Al-Ghazali បានពិចារណាការបកស្រាយផ្សេងៗដែលគាត់ជឿថានឹងបង្កើតការយល់ដឹងថ្មី ហើយដែលនឹងបញ្ចេញសក្តានុពល និងសមត្ថភាពរបស់ស្ត្រី។

## សរុបរួម

Al-Ghazali បានព្យាយាមបង្កើតគំរូការងារឌាក់វ៉ះទំនើបមួយនៅក្នុងវិសាលភាពដ៏ទូលំទូលាយនៃការផ្លាស់ប្តូរសង្គមអ៊ីស្លាម។ នៅក្នុងគំរូរបស់គាត់ ទូអាតមិនត្រឹមតែអ្នកបញ្ជូនការបង្រៀនសាសនាអ៊ីស្លាម ឬសីលធម៌ ប៉ុន្តែក៏ជាភ្នាក់ងារនៃការផ្លាស់ប្តូរដ៏វិជ្ជមានផងដែរ។ លើសពីនេះទៀតការឌាក់វ៉ះត្រូវបានចាត់ទុកមិនមែនជាកាតព្វកិច្ចរបស់ក្រុមជាក់លាក់ ជាក្រុមទូអាតទៀតនោះទេ ប៉ុន្តែជាទំនួលខុសត្រូវរួមនៅក្នុងសង្គម និងសមូហភាពដែលស្វែងរកមិនត្រឹមតែលើកកម្ពស់ជីវិតសាសនាអ៊ីស្លាម ប៉ុន្តែក៏ជាស្តង់ដារសេដ្ឋកិច្ចនៃសង្គមអ៊ីស្លាមផងដែរ។ លើសពីនេះទៀត ការឌាក់វ៉ះ មិនមែនត្រឹមតែមានឈ្មោះជាអ្នកអធិប្បាយ ជាមូហ្វទី និងអ្នកប្រាជ្ញសាសនាអ៊ីស្លាមប៉ុណ្ណោះនោះទេ ប៉ុន្តែលើសពីនេះទៀត អ្នកទាំងអស់នោះក៏ជាអ្នកដែលរួមចំណែកដល់ការផ្លាស់ប្តូរសង្គម និងសកលលោកផងដែរ ដូចជាក្រុមដែលរួមមានដូចជា តាប់លៀហ្គ ស៊ូហ្វី និងក្រុមសាឡាហ្វជាដើម។

សម្រាប់គាត់ ការឌាក់វ៉ះ មិនគ្រាន់តែបង្ហាញពីការទទួលខុសត្រូវលើការផ្សព្វផ្សាយ ការអធិប្បាយនូវសេចក្តីបង្រៀនតាមសាសនាអ៊ីស្លាមប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ឆ្លុះបញ្ចាំងពីដំណើរការនៃការផ្លាស់ប្តូរបញ្ញាញាណ និងកំណែទម្រង់សីលធម៌ផងដែរ។ ដំណើរការបែបនេះគឺបើកចំហរួម ទទួលយកភាពចម្រុះ និងពាក់ព័ន្ធនឹងចំណុចនៃទំនាក់ទំនងរវាងសាសនា និងសង្គម។ ដោយមើលឃើញពីលក្ខណៈចម្រុះនៃការងារឌាក់វ៉ះនេះ Al-Ghazali ស្វែងរកបរិបទប្រតិបត្តិការថ្មីមួយ ដែលឆ្លងកាត់ព្រំដែនវប្បធម៌ និងភូមិសាស្ត្រ ប្រកាន់ខ្ជាប់នូវការយល់ដឹងថ្មី និងសមហេតុផលនៃប្រពៃណីសាសនា និងត្រូវបានផ្តាច់ចេញពីការរួមចំណែកផ្តាច់មុខដោយចលនា និងក្រុមមូស្លីមណាមួយ ចំពោះការងារឌាក់វ៉ះនេះ ពោលវាជាការងាររួមរបស់សង្គម។ គំរូរបស់ Al-Ghazali នៃការឌាក់វ៉ះជាប់ពាក់ព័ន្ធនឹងសំណួរនៃការផ្លាស់ប្តូរសង្គមអ៊ីស្លាម ដើម្បីបង្កើតបរិយាកាសដែលអំណោយផលសម្រាប់ការងារឌាក់វ៉ះ ។ នៅក្នុងទិដ្ឋភាពនៃលក្ខណៈចំពោះការឌាក់វ៉ះ តម្រូវឱ្យមានការណែនាំពីសាសនាអ៊ីស្លាមដល់បុគ្គល និងប្រជាជាតិផ្សេងៗពីគ្នា។ គំរូរបស់ al-Ghazali ព្យាយាមបង្កើតស្ពាន ការប្រាស្រ័យទាក់ទង ការយល់ដឹង និងអន្តរកម្ម ជាពិសេសជាមួយលោកខាងលិចក៏ដូចជាការពង្រឹងបណ្តាញសកលនៃទំនាក់ទំនងនៅក្នុងសង្គមមូស្លីមខ្លួនឯង។ គំរូឌាក់វ៉ះ របស់ Al-Ghazali គាំទ្រនៅទីតាំងកណ្តាល ជាការពិត វាពិតជាលំបាកណាស់ក្នុងការយល់ឃើញថា ស្ថានភាពនៃការលើកឡើងអំពីការឌាក់វ៉ះ និងកំណែទម្រង់អ៊ីស្លាមនឹងគ្មានភាពលេចធ្លោនោះឡើយ បើយោងតាមគំនិតរបស់ Al-Ghazali លើការរួមចំណែកក្នុងន័យស្ថាបនានិងវិសាលភាពដ៏ទូលំទូលាយ។

ដំហរដ៏មានឥទ្ធិពលដែលគាត់បានប្រកាន់យកនូវសារៈសំខាន់នៃការអប់រំ ផ្តល់ទម្ងន់ដ៏សំខាន់ដែលគាត់បានផ្តល់ដល់សង្គមសេរី លើកកម្ពស់កម្រិតជីវភាពឲ្យបានសមរម្យសម្រាប់ជនក្រីក្រ គុណភាពនៃឧត្តមភាពផ្ទាល់ខ្លួនដែលគាត់បានអំពាវនាវ និងតួនាទីប្រកបដោយក្តីមេត្តា និងក្តីស្រលាញ់របស់គាត់ជាអ្នកអប់រំ និងជាបញ្ញវន្ត ដែលបានផ្តល់គំនិតរិះគន់ស្ថាបនាជាសាធារណៈទាំងអស់ បានរក្សាកេរ្តិ៍ឈ្មោះរបស់ Al-Ghazali សម្រាប់ជីវិតរបស់គាត់ និងសម្រាប់មនុស្សជំនាន់ក្រោយ ក្នុងនាមជាទស្សនវិទូមូស្លីមដែលមានបញ្ញាញាញដ៏សំខាន់បំផុតមួយក្នុងសតវត្សរ៍ និងក៏ជាអ្នកកែទម្រង់ផងដែរ។

## អ្នកនិពន្ធ

BENAOUDA BENSAID មានបរិញ្ញាបត្រផ្នែកសិក្សាអ៊ីស្លាម (University of El-Emir Abdel Kadir, Constantine, ប្រទេសអាល់ហ្សេរី) ថ្នាក់អនុបណ្ឌិតផ្នែក Islamic Revealed Knowledge (សាកលវិទ្យាល័យអ៊ីស្លាមអន្តរជាតិម៉ាឡេស៊ី) និងបណ្ឌិតផ្នែកសិក្សាអ៊ីស្លាម (សាកលវិទ្យាល័យ McGill ប្រទេសកាណាដា)។ បច្ចុប្បន្នគាត់ត្រូវបានផ្សាភ្ជាប់ជាមួយនឹងមហាវិទ្យាល័យសិល្បៈ និងវិទ្យាសាស្រ្ត នៃសាកលវិទ្យាល័យ Effat ទីក្រុងជុទ្ទះ ប្រទេសអារ៉ាប៊ីសាអូឌីត។

# កំណត់សម្គាល់

1 Ishaq Farhan, "Kalimah Jamʿiyyat al-Dirāsāt wa al-Buḥūth al-Islāmiyyah," in *Al-ʿAṭa' al-Fikrī li al-Shaykh al-Ghazālī*, p.20.

2 Muhammad Imarah, *Al-Shaykh Muḥammad al-Ghazālī wa al-Mawqiʿ al-Fikrī wa al-Maʿārik al-Fikriyyah* (Cairo: Dār al-Salām li al-Ṭibāʿah wa al-Nashr wa al-Tawzīʿ, 2009), p.29.

3 Muhammad al-Ghazali, *Jurʿāt Jadīdah min al-Ḥaqq al-Murr* (New Doses of the Bitter Truth) (Giza, Egypt: Nahḍat Miṣr li al-Ṭibāʿah wa al-Nashr wa al-Tawzīʿ, 2004), vol.6, p.44.

4 Muhammad al-Ghazali, "Qiṣṣat Ḥayāt al-Shaykh," (Excerpts from the Memories of al-Ghazali: A Life Story) *Islāmiyyat al-Maʿrifah*, 7 (1997), p.155.

5 Muhammad al-Ghazali *Ta'ammulāt fī al-Dīn wa al-Ḥayāt* (Reflections about Religion and Life) (Giza: Nahḍat Miṣr li al-Ṭibāʿah wa al-Nashr wa al-Tawzīʿ), pp.44-46.

6 Ahmad Assal, "Al-Jawānib al-Nafsiyyah wa al-Khuluqiyyah," in *Al-ʿAṭā' al-Fikrī li al-Shaykh al-Ghazālī*, p.28.

7 Al-Ghazali, *Al-Islām wa Awḍāʿunā al-Iqtiṣādiyyah* (Islam and our Economic Conditions)(Damascus: Dār al-Qalam, 2000), p.62.

8 Masud Fallussi, *Al-Shaykh Muḥammad al-Ghazālī Ghuṣn Bāsiq fī Shajarat al-Khulūd* (Al-Shaykh Muhammad al-Ghazali, A Lofty Branch in a Tree of Eternity)(Cairo:Maktabat Wahbah, 2003), p.24.

9 Fallussi, *Ghuṣn Bāsiq*, p.28.

10 See al-Ghazali, "Qiṣṣat Ḥayāt," p.158.

11 Ibid., p.159.

12 Ibid., pp.168-169.

13 Al-Ghazali, *Ta'ammulāt*, p.113.

14 Al-Ghazali, *Kayfa Nafham al-Islām?* (Understanding Islam) (Damascus: Dār al-Qalam, 2000), p.28.

15 Ibid., p.30.

16 Ibid., p.32.

17 Al-Ghazali, *Min Maqālāt al-Shaykh al-Ghazālī* (Essays by Shaykh al-Ghazali) (Giza: Nahḍat Miṣr li al-Ṭibāʿah wa al-Nashr wa al-Tawzīʿ, 2002), vol.2, p.110.

18 Al-Ghazali, *Ṣayḥat Tahdhīr min Duʿāt al-Tanṣīr*, 1st edn., (Damascus: Dār al-Qalam, 2000), p.33.

[19] Al-Ghazali, *Al-Islām wa al-Istibdād al-Siyāsī* (Damascus: Dār al-Qalam, 2003), p.207.

[20] Al-Ghazali, *Qadhā'if al-Ḥaqq* (Damascus: Dār al-Qalam, 2002), p.81; *Dustūr al-Wiḥdah al-Thaqāfiyyah*, p.9.

[21] Muhammad Imarah, *Al-Shaykh Muḥammad al-Ghazālī, al-Mawqiᶜ al-Fikrī wa al-Maᶜārik al-Fikriyyah* (The Intellectual Position of Muhammad al-Ghazali and the Intellectual Debates) (Egypt: Al-Hay'ah al-Miṣriyyah al-ᶜĀmmah li al-Kitāb, 1992), p.31.

[22] See al-Qaradawi, *Al-Shaykh al-Ghazālī kamā ᶜAraftuh*, *Riḥlat Niṣf Qarn* (Al-Shaykh al-Ghazali as I Knew Him, A Journey of Half of a Century) (Al-Manṣūrah, Egypt: Dār al-Wafā' li al-Ṭibāᶜah wa al-Nashr wa al-Tawzīᶜ, 1995), p.31.

[23] Al-Ghazali, "Qiṣṣat Ḥayāt," p.197.

[24] Al-Assal, "Al-Jawānib al-Fikriyyah," in *Al-ᶜAṭā' al-Fikrī li al-Shaykh al-Ghazālī*, p.54.

[25] See Said Hawwa, *Fī Āfāq al-Taᶜālīm* (Beirut, Lebanon: The Holy Qur'an Publishing House, 1980), pp.168-173.

[26] Al-Ghazali, *Dustūr al-Wiḥdah*, pp.236-237.

[27] Al-Ghazali, *Al-Daᶜwah al-Islāmiyyah Tastaqbil Qarnahā al-Khāmis ᶜAshar* (Damascus: Dār al-Qalam, 2001), pp.68-92.

[28] Al-Ghazali, *Al-Ḥaqq al-Murr,* vol.3, p.3.

[29] Halim Uways, *Al-Shaykh Muḥammad al-Ghazālī, Tārīkhuhu wa Juhuduhu wa Ārā'uhu,* pp.10-11.

[30] Al-Ghazali, *Ta'ammulāt*, p.209.

[31] Al-Ghazali, *Min Maᶜālim al-Ḥaqq fī Kifāḥinā al-Islāmī al-Ḥadīth* (Signposts from our Present Islamic Struggle) (Giza, Egypt: Nahḍat Miṣr li al-Ṭibāᶜah wa al-Nashr wa al-Tawzīᶜ, 2003), pp.95-96.

[32] Al-Ghazali, *Min Hunā Naᶜlam* (From Here we Know) (Giza, Egypt: Dār Nahḍat Miṣr li al-Ṭibāᶜah wa al-Nashr wa al-Tawzīᶜ, 2005), p.95.

[33] Al-Ghazali, *Maᶜa Allāh: Dirāsāt fī al-Daᶜwah wa al-Duᶜāt* (In the Company of God: A Study of *Daᶜwah* and *Duᶜāt*) (Damascus: Dār al-Qalam, 2003), p.92.

[34] Al-Ghazali, *Min Maqālāt*, vol.3, p.81.

[35] Ibid.

[36] Al-Ghazali, *Maᶜa Allāh*, pp.18-19.

[37] Al-Ghazali, *Qadhā'if al-Ḥaqq*, p.81.

[38] Al-Ghazali, *Rakā'iz al-'Īmān*, p.23.

[39] Al-Ghazali, *Sirr Ta'akhkhur al-ᶜArab wa al-Muslimīn* (The Causes of Backwardness of Arabs and Muslims) (Damascus: Dār al-Qalam, 2000), p.35.

[40] Al-Ghazali, *Ḥaqīqat al-Qawmiyyah al-ᶜArabiyyah* (The Reality of Arab Nationalism) (Giza: Nahḍat Miṣr li al-Ṭibāᶜah wa al-Nashr wa al-Tawzīᶜ, 2005), p.49.

41 Al-Ghazali, *Min Maᶜālim al-Ḥaqq*, p.148.

42 Al-Ghazali, *Al-Daᶜwah al-Islāmiyyah Tastaqbil*, p.7.

43 Al-Ghazali, *Maᶜa Allāh*, p.52.

44 Ibid., p.157.

45 Al-Ghazali, *ᶜIlal wa Adwiyah* (Diseases and Cures) (Damascus: Dār al-Qalam, 2003), p.250.

46 Ibid.

47 Al-Ghazali, *Maᶜa Allāh*, p.171.

48 Ibid.

49 Al-Ghazali, *Ḥuqūq al-Insān bayna Taᶜālīm al-Islām wa Iᶜlān Hay'at al-Umam* (Human Rights between the Teachings of Islam and the Declaration of the United Nation) (Giza, Egypt: Nahḍat Miṣr li Ṭibāᶜah wa al-Nashr wa al-Tawzīᶜ, 2004), p.218.

50 Al-Ghazali, *Min Maqālāt*, vol.3, p.90.

51 Ibid., vol.1, p.63.

52 Al-Ghazali, *Jaddid Ḥayātaka* (Damascus, Syria: Dār al-Qalam, 2004), p.59.

53 Al-Ghazali, *ᶜIlal wa Adwiyah* (Damascus, Syria: Dār al-Qalam, 2003), p.121.

54 Al-Ghazali, *Jurᶜāt Jadīdah*, vol.5, p.51.

55 Al-Ghazali, *Min Maqālāt*, vol.1, p.50.

56 Al-Ghazali, *Kayfa Nafham al-Islām*? p.142.

57 Al-Ghazali, *Jurᶜāt Jadīdah*, vol.5, p.51.

58 Al-Ghazali, *Min Maqālāt*, vol.1, p.63.

59 Al-Ghazali, *ᶜIlal wa Adwiyah*, p.59.

60 Al-Ghazali, *Jaddid Ḥayātaka*, p.8.

61 Al-Ghazali, *Mi'at Sū'āl* (One Hundred Questions) (Cairo: Dār al-Muqaṭṭam li al-Nashr wa al-Tawzīᶜ, 2004), p.139.

62 Al-Ghazali, *Ẓalām min al-Gharb* (Damascus: Dār al-Qalam, 1999), p.39.

63 Al-Ghazali, *Rakā'iz al-Īmān bayna al-ᶜAql wa al-Qalb* (Foundations of Faith between the Intellect and Heart), p.82.

64 Al-Ghazali, *ᶜIlal wa Adwiyah*, p.120.

65 Al-Ghazali, *Al-Ghazw al-Thaqāfī*, p.18.

66 Al-Ghazali, *Al-Daᶜwah al-Islāmiyyah*, p.168.

67 Al-Ghazali, *Sirr Ta'akhkhur*, p.148.

68 Al-Ghazali, *ᶜIlal wa Adwiyah*, p.237.

69 Al-Ghazali, *Sirr Ta'akhkhur*, pp.94-95.

70 Al-Ghazali, *Al-Daᶜwah al-Islāmiyyah*, pp.145-174.

71 Al-Ghazali, *Humūm Dāᶜiyah* (Concerns of a *Dāᶜiyah*) (Damascus: Dār al-Qalam, 2000), p.3.

72 Al-Ghazali, *Al-Maḥāwir al-Khamsah li al-Qur'ān al-Karīm* (The Five Themes of the Glorious Qur'an) (Damascus: Dār al-Qalam, 2000), p.57.

73 Al-Ghazali, *Kayfa Nafham al-Islām*?, p.15.

74 Al-Ghazali, *Al-Islām wa Awḍāᶜunā al-Iqtiṣādiyyah* (Islam and our Economic Conditions) (Damascus: Dār al-Qalam, 2000), pp.91-92.

[75] Al-Ghazali, *ʿAqīdat al-Muslim* (The Muslim Creed) (Dār al-Qalam, 1999), p.13.
[76] Al-Ghazali, *Min Maqālāt*, vol.1, p.63.
[77] Al-Ghazali, *Min Maqālāt*, vol.2, p.147.
[78] Al-Ghazali, *Al-Islām wa Awḍāʿunā*, p.61.
[79] Al-Ghazali, *Humūm Dāʿiyah*, p.129.
[80] Al-Ghazali, *Sirr Ta'akhkhur*, p.89.
[81] Al-Ghazali, *ʿIlal wa Adwiyah*, p.120.
[82] Al-Ghazali, *Sirr Ta'akhkhur*, p.33.
[83] Ibid., p.32.
[84] Al-Ghazali, *Al-Islām wa al-Istibdād al-Siyāsī*, p.92.
[85] Al-Ghazali, *Qadhā'if al-Ḥaqq*, p.235.
[86] Al-Ghazali, *Al-Islām wa al-Istibdād al-Siyāsī*, p.87.
[87] Al-Ghazali, *Mustaqbal al-Daʿwah* (The Future of *Daʿwah*) (Cairo: Dār al-Shurūq, 1997), p.15.
[88] Al-Ghazali, *Al-Sunnah al-Nabawiyyah bayna Ahl al-Fiqh wa-Ahl al-Ḥadīth* (The Sunnah of the Prophet between the Jurists and the Muhadddiths) (Cairo: Dār al-Shurūq, 2001), pp.74-75.
[89] Al-Ghazali, *Mi'at Sū'āl*, p.296.
[90] Al-Ghazali, *Ẓalām min al-Gharb*, p.89.
[91] Al-Ghazali, *Mi'at Sū'āl*, p.296.
[92] Al-Ghazali, *Hādhā Dīnunā* (This is our Religion) (Damascus: Dār al-Qalam, 1999), p.55.
[93] Al-Ghazali, *Ḥuqūq al-Insān*, p.14.
[94] Al-Ghazali, *Al-Sunnah al-Nabawiyyah*, pp.129-130.
[95] Al-Ghazali, *Ḥaṣād al-Ghurūr* (The Harvest of Pride) (Damascus: Dār al-Qalam, 2003), p.107.
[96] Al-Ghazali, *Maʿa Allāh*, p.186.
[97] Al-Ghazali, *Min Hunā Naʿlam*, p.95.
[98] Al-Ghazali, *Al-Daʿwah al-Islāmiyyah*, p.144.
[99] Al-Ghazali, *Sirr Ta'akhkhur*, p.40.
[100] Al-Ghazali, *Jihād al-Daʿwah bayna ʿAjz al-Dākhil wa Kayd al-Khārij* (The Struggle of Daʿwah between Internal Deficiencies and External Adversity) (Beirut: Al-Dār al-Shāmiyyah, 1999), p.64.
[101] Al-Ghazali, *Mushkilāt fī Ṭarīq al-Ḥayāt al-Islāmiyyah* (Problems on the Way to the Islamic Life) (Cairo: Nahḍat Miṣr li al-Ṭibāʿah wa al-Nashr wa al-Tawzīʿ, 2003), p.137.
[102] Al-Ghazali, *Ḥaṣād al-Ghurūr*, p.21.
[103] Al-Ghazali, *Min Maqālāt*, vol.3, p.165.
[104] Ghazali, *Maʿa Allāh*, p.193.
[105] Ibid., pp.216-217.
[106] Ibid., p.215.

107 Al-Ghazali, *Mushkilāt*, p.117.

108 Al-Ghazali, *Sirr Ta'akhkhur*, p.95.

109 Al-Ghazali, *Min Maqālāt*, vol.3, p.28.

110 Ibid., p.100.

111 Al-Ghazali, *Mustaqbal al-Islām*, pp.163-164.

112 Al-Ghazali, *Kayfa Nafham al-Islām*?, pp.79-80.

113 Al-Ghazali, *Rakā'iz al-Īmān*, p.159.

114 Al-Ghazali, *Humūm Dāʿiyah*, p.3.

115 Al-Ghazali, *Kayfa Nafham al-Islām*?, p.25.

116 Al-Ghazali, *Min Maqālāt*, 2, p.1.

117 Al-Ghazali, *Al-Daʿwah al-Islāmiyyah*, p.90.

118 Al-Ghazali, *Humūm Dāʿiyah*, p.129.

119 Al-Ghazali, *Qadhā'if al-Ḥaqq*, p.168.

120 Al-Ghazali, *Turāthunā al-Fikrī fī Mīzān al-Sharʿ wa al-ʿAql* (Our Intellectual Heritage in the Perspective of Reason and Revelation) (Cairo: Dār al-Shurūq, 2003), p.175.

121 Al-Ghazali, *Al-Daʿwah al-Islāmiyyah Tastaqbil*, p.147.

122 Al-Ghazali, *Al-Daʿwah al-Islāmiyyah Tastaqbil*, p.179.

123 Al-Ghazali, *Al-Sunnah al-Nabawiyyah*, p.54.

124 Al-Ghazali, *Al-Islām wa al-Ṭāqāt al-Muʿaṭallah*, p.96.

125 Al-Ghazali, *Dustūr al-Wiḥdah al-Thaqāfiyyah*, p.169.

IIIT Books-In-Brief Series គឺជាការប្រមូលដ៏មានតម្លៃនៃការបោះពុម្ពផ្សាយសំខាន់ៗរបស់វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ រៀបរៀងជាទម្រង់បង្រួម ផ្តល់ឱ្យអ្នកអាននូវការយល់ដឹងអំពីខ្លឹមសារសំខាន់ៗនៃសៀវភៅច្បាប់ដើម។

នៅក្នុងការលះបង់ដោយអស់ពីចិត្តចំពោះកិច្ចការផ្សព្វផ្សាយអញ្ជើញអ្នកដទៃមកកាន់សាសនាអ៊ីស្លាម។ Muhammad al-Ghazali (1917-1996) បានបង្ហាញអំពីមូស្លីមជាមួយនឹងការរិះគន់ដ៏ខ្លាំងមួយអំពីខ្លួនគេ មិនត្រឹមតែនៅក្នុងការបរាជ័យជាសកលរបស់ពួកគេក្នុងគម្រោងផ្សព្វផ្សាយសាសនាអ៊ីស្លាមនៅក្នុងពន្លឺដ៏ប្រសើរបំផុត និងសមហេតុផលបំផុតប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងស្ថិតនៅក្នុងភាពមិនត្រឹមត្រូវរបស់ពួកគេចំពោះគោលការណ៍នៃសេចក្តីបង្រៀនរបស់អាល់គួរអានដ៏ឧត្តុងឧត្តម និងលំអានកំណត់ដោយព្យាការីមហាំម៉ាត់ ។

ការងារនេះវិភាគលើការការរិះគន់របស់Al-Ghazali លើទូអាត (អ្នកដែលផ្សព្វផ្សាយសាសនាអ៊ីស្លាម) និងការអនុវត្តការងារឌាក់វ៉ះ (ការអំពាវនាវទៅកាន់សាសនាអ៊ីស្លាម) វាក៏ពិនិត្យមើលវិធីសាស្ត្ររបស់គាត់ ដំណោះស្រាយដែលបានស្នើឡើងផ្សេងៗ និងការឆ្លើយតបផ្នែកច្បាប់ចំពោះទស្សនៈរបស់គាត់។ ការវិវត្តនៃគំនិតរបស់ Al-Ghazali និងកត្តាដែលជះឥទ្ធិពលដល់គាត់គឺជាធាតុសំខាន់នៃការសិក្សា។ វាពិបាកនៅក្នុងការយល់ឃើញថា ស្ថានភាពនៃសុន្ទរកថាស្តីពីការងារឌាក់វ៉ះ និងកំណែទម្រង់អ៊ីស្លាមនឹងគ្មានការរួមចំណែកដ៏ឆ្នើមរបស់ Al-Ghazali ។ ជំហរដ៏មានឥទ្ធិពលដែលគាត់បានប្រកាន់យកនូវសារៈសំខាន់នៃការអប់រំ ទម្ងន់ដ៏សំខាន់ដែលគាត់បានផ្តល់ដល់សង្គមសេរី ការលើកកម្ពស់កម្រិតជីវភាពសមរម្យសម្រាប់ជនក្រីក្រ គុណសម្បត្តិនៃសីលធម៌ និងឧត្តមភាពផ្ទាល់ខ្លួនដែលគាត់បានអំពាវនាវ និងតួនាទីប្រកបដោយក្តីមេត្តា និងក្តីស្រលាញ់របស់គាត់។ ក្នុងនាមជាអ្នកអប់រំ ទាំងអស់នេះរក្សាកេរ្តិ៍ឈ្មោះរបស់ Al-Ghazali ទាំងក្នុងជីវិតរបស់គាត់ និងសម្រាប់មនុស្សជាច្រើនជំនាន់ក្រោយៗទៀត ក្នុងនាមជាអ្នកគិត និងអ្នកធ្វើកំណែទម្រង់ដ៏សំខាន់បំផុតមួយរបស់សតវត្សរ៍ទី20 ។ កេរដំណែលរបស់គាត់ត្រូវបានបង្កើតឡើងនៅលើការបម្រើការងារអស់មួយជីវិត។

Cambodia Office
IIIT Books-in-Brief

979-8-89193-328-6
9 798891 933286